ផ្នែក ខ

# ព័ត៌មានអំពី ការជួញដូរមនុស្ស និង ការធ្វើចំណាកស្រុក



# ៣ មេរៀនទី ៣ ៖ តើអ្វីជាការជួញដូរមនុស្ស? តើអ្វីជាការធ្វើចំណាកស្រុក?

## វត្ថុបំណង
អ្នកចូលរួម នឹងយល់អំពីនិយមន័យ នៃការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក និងអាច កំណត់និយមន័យ ទាំងពីរនេះដោយប្រើពាក្យសាមញ្ញបាន។

## ពេលវេលា
៨០ នាទី

## ការត្រៀម
កាត់រឿងនីមួយៗ ចេញពីសន្លឹក " IS ៣កៈ កាត់សំណាង"។ ត្រូវប្រាកដថា រឿង នីមួយៗ នៃការជួញដូរមនុស្ស មានការឆ្លើយតបទៅ នឹងការធ្វើចំណាកស្រុក ដោយកាត់កាត់តាម បណ្តោយបន្ទាត់។ បន្ទាប់មកដាក់កាត់ សំណាងទាំងអស់ចូលទៅក្នុងថង់ ឬមួកមួយ។

**សម្ភារៈ**

- ក្រដាស់វែងសម្រាប់លំហាត់ផ្សំពាក្យអំពីការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស
- ប៊ិច ឬខ្មៅដៃពណ៌
- ថតចម្លង "IS ៣: កាត់សំណាង" និងថង់ ឬមួកដើម្បីដាក់ ក្រដាសទាំងនេះចូល
- ឯកសារយោង "IS ៣ខ: តើអ្វីជាការជួញដូរមនុស្ស? អ្វីជាការធ្វើចំណាកស្រុក?"
- កូនសៀវភៅនាវិកវៃឆ្លាតសម្រាប់អ្នកចូលរួមម្នាក់ៗ

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើអ្នកមានកត់សម្គាល់ទេថា ប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់អ្នកមានគោលដៅដែរឬទេ? តើមានគោលដៅអ្វីខ្លះ?

**ចំណាំ ៖** មិនត្រូវធ្វើឲ្យអាម៉ាស់មុខដល់អ្នកចូលរួមដែលមិនចាំចម្លើយសំណួរទាំងនេះ។ វាជាការសំខាន់ណាស់ដែលអ្នកចូលរួមនឹងរីករាយជាមួយនឹង SNYC និងបន្តមកចូលរួមសាលា ជាប្រចាំ។

### និយមន័យនៃ ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក

សុំឲ្យអ្នកចូលរួមអង្គុយជារង្វង់

សុំឲ្យក្រុមគិតពីមធ្យោបាយ ដែលពិភពលោកបានប្រែប្រួលកាលពី ២០ ឆ្នាំមុន។ ប្រសិនបើ ពិបាកឆ្លើយខ្លាំង សុំឲ្យក្រុមបរិយាយអំពីអ្វីផ្សេងនៅក្នុងសហគមន៍ ក្នុងភូមិ ស្រុក ដែលបាន ប្រែប្រួលក្នុងអំឡុងពេល ៣ ឆ្នាំចុងក្រោយនេះ។ បន្ទាប់មកចង្អុលបង្ហាញទិដ្ឋភាពមួយដែល

ពិភពលោកមានការប្រែប្រួលគឺថា យុវជនកំពុងងាកទៅរកការងារច្រើនជាងកាលពីដើម។ សួរក្រុមថា តើមានស្គាល់នរណាម្នាក់ដែលបានចាកចេញពីភូមិនេះដើម្បីរកការងារធ្វើដែរ ឬទេ។
ពន្យល់ពាក្យថា "ការធ្វើចំណាកស្រុក" មានន័យថា ជាដំណើរការដែលមនុស្សម្នាក់ផ្លាស់ទីដើម្បី រកការងារធ្វើ។ "ជនចំណាកស្រុក" បរិយាយអំពីបុគ្គលដែលធ្វើចំណាកស្រុក។ សួរទៅសមាជិកក្រុមថា តើពួកគេគិតទៅដល់អ្វីនៅពេលដែលគេឮពាក្យថាការធ្វើចំណាកស្រុក ។ សរសេរពាក្យដែលអ្នកចូលរួមបានសរសេរលើក្រដាស ឬហៅអ្នកចូលរួមបង្ហាញរូបភាពដែលផ្សារភ្ជាប់ជាមួយនឹងការធ្វើចំណាកស្រុក។ ដាក់បង្ហាញពាក្យ និងរូបភាពនៅកន្លែងណាដែលអ្នកទាំងអស់គ្នាអាចមើលឃើញ។ វាអាចជាការល្អក្នុងការសរសេរនិយមន័យនៃពាក្យ ការធ្វើចំណាកស្រុក (ខាងលើ) ដែលអ្នកចូលរួមអាចមើលឃើញក្នុងពេលពួកគេកំពុងធ្វើលំហាត់នេះ។
ពន្យល់ថា ការធ្វើចំណាកស្រុក អាចជាការល្អ វាអាចជួយដល់យុវជនឲ្យរកការងារបានធ្វើ ឃើញកន្លែងថ្មី ឬទទួលបានការអប់រំ។ មានមនុស្សជាច្រើននៅក្នុងបន្ទប់នេះអាចនឹងកំពុងគិតពីការរកការងារធ្វើ ។ ប៉ុន្តែការធ្វើចំណាកស្រុកក៏អាចមានគ្រោះថ្នាក់ផងដែរ។ មានអ្នកដែល ចង់កេងចំណេញ ឬប្រើល្បិចបោកជនចំណាកស្រុកវ័យក្មេងដើម្បីបានប្រាក់។ ល្បិចទាំងនេះ អាចនាំឲ្យយុវជនធ្លាក់ចូលក្នុងបញ្ហាធ្ងន់ធ្ងរ ។
ពន្យល់ថា ប៉ុន្មានមេរៀនក្រោយៗទៀត នឹងនិយាយអំពីគ្រោះថ្នាក់ ដែលប្រឈមដោយជនចំណាក ស្រុកវ័យក្មេង។ បន្ទាប់មកទៀតនៅក្នុងសៀវភៅណែនាំនេះនឹងមានមេរៀនអំពីការធ្វើចំណាកស្រុកតាមមធ្យោបាយកាន់តែមានសុវត្ថិភាព និងកាន់តែឆ្លាតវៃ។
ពន្យល់ថា ពេលខ្លះជនចំណាកស្រុកវ័យក្មេងត្រូវបានគេជួញដូរ។
ការជួញដូរមនុស្ស គឺជាការឆបោក ឬបង្ខំឲ្យមនុស្សធ្លាក់ចូលទៅក្នុងទម្រង់ការងារដែលកេងប្រវ័ញ្ច ដែលបន្ទាប់មកទៀត ជនរងគ្រោះពិបាកក្នុងការចាកចេញ។ ការជួញដូរមនុស្សជាញឹកញាប់គឺជាការយកជនរងគ្រោះពីកន្លែងដែលគេរស់នៅទៅកាន់កន្លែងផ្សេងទៀតដោយការ បង្ខំ ឬការឆបោក ដើម្បី កេងប្រវ័ញ្ច លើពួកគាត់។ ប៉ុន្តែទោះជាយ៉ាងណា អាចនឹងមានការជួញដូរដោយមិនចាំបាច់ផ្លាស់ទីកន្លែងក៏មាន។
សួរអ្នកចូលរួមថា តើគេគិតដល់អ្វីនៅពេលដែលគេឮពាក្យថា ការជួញដូរមនុស្ស។ សរសេរពាក្យ ដែលអ្នកចូលរួមបានសរសេរលើក្រដាស ឬហៅឲ្យអ្នកចូលរួមធ្វើខ្លួនឯង និងបង្ហាញរូបគំនូរ ដែលពួកគេបានផ្សារភ្ជាប់ជាមួយនឹងការជួញដូរមនុស្ស។ ដាក់បង្ហាញពាក្យ និងរូបភាពនៅកន្លែងណា ដែលអ្នកទាំងអស់គ្នា អាចមើលឃើញ។ វាអាចជាការល្អ ក្នុងការសរសេរនិយមន័យ នៃពាក្យ ការជួញដូរមនុស្ស (ខាងលើ) ដែលអ្នកចូលរួមអាចមើលឃើញក្នុងពេលពួកគេកំពុងធ្វើលំហាត់នេះ។
*ការបង្ខំ* ពន្យល់ថា នៅពេលដែលមនុស្សត្រូវបានគេជួញដូរគឺគាត់ត្រូវបានគេបង្ខំក្នុងរូបភាពផ្សេងៗ។ អ្នកខ្លះត្រូវបានគេជួញដូរដោយប្រាប់ថា អ្នកនឹងទទួលបានការងារល្អនៅពេលដែលទៅដល់គោលដៅ បន្ទាប់មក ពួកគាត់ត្រូវបានបង្ខំឲ្យធ្វើការងារផ្សេងទៅវិញ។ អ្នកខ្លះទៀតត្រូវបានចាក់សោទុកនៅក្នុងរោងចក្រ ឬនៅលើទូក ហើយមិនអាចចាកចេញបានទេ។

អ្នកខ្លះទៀតគេគំរាមថា អ្នកជួញដូរនឹងធ្វើបាបគេ ឬគ្រួសារគេបើគេចាកចេញ។ ទាំងនេះគឺជាឧទាហរណ៍ខុសៗគ្នានៃការបង្ខំ

*ការបោកប្រាស់* ៖ ពន្យល់ថា ការបោកប្រាស់ បង្ហាញពីសកម្មភាពនៃការបិទបាំង ឬការនិយាយភូតកុហក់ខុសពីការពិត ឬភាពមិនស្មោះត្រង់។

*កេងប្រវ័ញ្ច* ៖ នៅពេលដែលនរណាម្នាក់ប្រើអ្នកដ៏ទៃ ជាធម្មតាគឺដើម្បីផលចំណេញ គឺជននោះកំពុង កេងប្រវ័ញ្ច គេហើយ។ នៅពេលដែលបុគ្គលណាម្នាក់ត្រូវបានគេជួញដូរនោះ គឺគេអាចនឹងត្រូវបានគេកេងប្រវ័ញ្ចដោយការបង្ខំឲ្យធ្វើការងារដែលគាត់មិនចង់ធ្វើ បង្ខំឲ្យធ្វើការងារបានកម្រៃតិចតួច ឬមិនមានកម្រៃតែម្តង បង្ខំឲ្យធ្វើការងារទាក់ទងនឹងផ្លូវភេទ ឬអាចនឹងត្រូវបានគេកាត់យកសរីរាង្គកាយដើម្បីលក់។

អ្នកជួញដូរគឺជាអ្នកដែលផ្សព្វផ្សាយឬផ្លាស់ប្តូរមនុស្សដូចជាទំនិញឬសេវានានាជាថ្នូរនឹងប្រាក់។ ប្រាប់ដល់អ្នកចូលរួមថា ជារឿយអ្នកជួញដូរនឹងផ្តល់ការងារខ្យល់ឲ្យយុវជនតែប៉ុណ្ណោះ ។ ជនចំណាកស្រុក ក្មេងៗដែលធ្វើដំណើរទៅរកការងារ អាចត្រូវបានគេបោកប្រាស់តែប៉ុណ្ណោះ។ យុវជន ទាំងនោះអាចនឹងចង់ត្រឡប់ទៅផ្ទះវិញនៅពេលដែលខ្លួនបានដឹងពីប្រភេទ ការងារហើយ ប៉ុន្តែគេមិនអាចធ្វើបានឡើយ។ ពេលខ្លះអ្នកជួញដូរមនុស្សចាក់សោបង្ខាំង ទុកជនចំណាកស្រុកនៅក្នុងរោងចក្រ ជាដើម។ ពេលខ្លះអ្នកជួញដូរនឹងប្រាប់ពួកគេថា ពួកគេមិន អាចទៅផ្ទះវិញបានទេ ពីព្រោះនៅជំពាក់ប្រាក់សម្រាប់សោហ៊ុយធ្វើដំណើរមកកាន់ទីនេះ។ ពេលខ្លះ អ្នកជួញដូរនឹងគំរាមកំហែងពួកគេ។ អ្នកជួញដូរនឹងប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីបង្ខំឲ្យ ពួកគាត់ធ្វើការងារ។ ហើយនៅពេលដែលជនចំណាកស្រុកធ្វើការងារ គឺគេធ្វើការងារក្នុងលក្ខខណ្ឌយ៉ាប់យ៉ឺន និងទទួលបានកម្រៃទាប ឬគ្មានកម្រៃក៏មាន។

ពន្យល់ថា ការជួញដូរមនុស្ស គឺខុសពីការរត់ពន្ធមនុស្ស។ មនុស្សជ្រើសរើសវិធីឲ្យគេរត់ពន្ធខ្លួន។ នៅពេលដែលបុគ្គលម្នាក់ត្រូវបានគេរត់ពន្ធ គឺគាត់ឲ្យប្រាក់ទៅអ្នករត់ពន្ធដើម្បី ឲ្យអ្នកនោះនាំគាត់ឆ្លងកាត់ព្រំដែនដោយខុសច្បាប់។ បើទោះបីជាជនត្រូវគេរត់ពន្ធខុស ច្បាប់បង់ប្រាក់ដើម្បីធ្វើដំណើរ ហើយអាចនឹងជំពាក់ប្រាក់គេនៅពេលធ្វើដំណើរដល់គោលដៅ ក៏ដោយគឺពួកគេមានសេរីភាពពេញលេញនៅពេលទៅដល់ប្រទេសគោលដៅ (ខុសពីអ្នក ដែលត្រូវគេជួញដូរ ដែលមិនមានសេរីភាពទេ)។ នេះមិនមែនមានន័យថា ការរត់ពន្ធមុស្សគឺជាមធ្យោបាយស្របច្បាប់នោះទេ។ ជនដែលត្រូវបានគេនាំរត់ពន្ធខុសច្បាប់ឆ្លងកាត់ព្រំដែន អន្តរជាតិគឺប្រឈមនឹងហានិភ័យខ្ពស់។ ពួកគេអាចនឹងរងការរំលោភបំពានពីអ្នករត់ពន្ធ ឬប្រាក់របស់គេត្រូវបានគេលួចយក។ នៅពេលទៅដល់គោលដៅ ពួកគេអាចមិនហ៊ានទៅរកអជ្ញាធរដើម្បីសុំជំនួយផ្នែកផ្លូវច្បាប់ទេ ព្រោះពួកគេចូលទៅក្នុងប្រទេសនោះដោយខុសច្បាប់។

សួរថា តើមាននរណាចង់សួរសំណួរដែរ ឬទេ ហើយប្រាប់អ្នកចូលរួមថា ពួកគេនឹងរៀនច្រើនបន្ថែមទៀតអំពីប្រធានបទនេះនៅក្នុងការប្រជុំក្លឹបថ្ងៃក្រោយ។

## សកម្មភាព កាក់សំណាង

ឲ្យអ្នកចូលរួមទះដៃ។ នៅពេលដែលគេទះដៃ ឲ្យគេហុចតគ្នានូវថង់ “ដាក់កាក់សំណាង”។ ពន្យល់ថា នៅពេលដែលអ្នកលើកដៃ ក្រុមទាំងមូលត្រូវឈប់ទះដៃ ហើយនរណាក៏ដោយ

ដែលកាន់ថង់កាក់នោះ ត្រូវតែបិទភ្នែកចាប់យកកាក់សំណាងចេញពីថង់ និងកាន់ទុក។ ជម្រើសមួយបែបទៀតគឺការចាក់ភ្លេង ហើយប្រាប់ថា នៅពេលអ្នកឈប់ចាក់ភ្លេង នរណាក៏ដោយ ដែលកាន់ថង់នោះត្រូវធ្វើដូចគ្នាដែរ។ នៅពេលដែលកាក់សំណាងទាំងអស់ត្រូវបានយកបានគ្រប់គ្នាហើយនោះ ត្រូវឲ្យអ្នកទាំងអស់គ្នាឈប់ទះដៃ ឬឈប់ចាក់ភ្លេងសុំឲ្យអ្នកដែលកាន់កាក់មួយក្នុងដៃ អានកាក់សំណាងឲ្យឮៗ។ ត្រូវប្រាកដថា ពួកគេមិនអានផ្នែកខាងលើបំផុតនៃកាក់ទេ ដែលសរសេរអំពី "ការជួញដូរមនុស្ស" ឬ "ការធ្វើចំណាកស្រុក"។ អំឡុងពេលអ្នកចូលរួមកំពុងអានកាក់សំណាងរបស់គេ សុំឲ្យក្រុមនីមួយពិភាក្សាថាតើផ្នែកនៃកាក់ខាងនេះរៀបរាប់អំពីអ្វីជាការជួញដូរ និងអ្វីជាការធ្វើចំណាកស្រុក និងសុំឲ្យពួកគេពន្យល់ពីមូលហេតុផងដែរ។ បន្ទាប់ពីការពិភាក្សា ឲ្យអ្នកចូលរួមត្រឡប់ អានកាក់ម្ខាងទៀត។ ឲ្យអ្នក ចូលរួមបកស្រាយថា តើម្ខាងទៀតមានភាពខុសគ្នាដូចម្ដេចខ្លះ។

## ការសិក្សាពីនិយមន័យ

ចែកកូនសៀវភៅនារីកវៃឆ្លាត។ ពន្យល់ថា កូនសៀវភៅទាំងនេះ មានព័ត៌មានសំខាន់ៗជាច្រើនសម្រាប់អ្នកចូលរួម។ ពេលនេះ អ្នកចូលរួមត្រូវសរសេរឈ្មោះរបស់ខ្លួន នៅលើកូនសៀវភៅ។ ប្រាប់សិស្សថាកូនសៀវភៅនេះត្រូវបានប្រើប្រាស់ផងដែរក្នុងអំឡុងពេលនៃការបណ្ដុះ បណ្ដាល ហើយអ្នកចូលរួម គួររក្សាកូនសៀវភៅនេះ ទុកនៅក្នុងប្រអប់ជាមួយនឹងសៀវភៅកំណត់ហេតុ ដើម្បីកុំឲ្យបាត់។ បន្ទាប់មកទៀត ក្រោយពេលបណ្ដុះបណ្ដាល អ្នកចូលរួមអាចយកកូនសៀវភៅនេះទៅផ្ទះបាន។

ពន្យល់ថា ច្បាប់ពាក់ព័ន្ធ ការជួញដូរកុមារ ខុសពីច្បាប់ពាក់ព័ន្ធនឹង ការជួញដូរមនុស្សធំ។ ប្រសិនបើកុមារត្រូវបានកេងប្រវ័ញ្ចលើកំលាំងពលកម្ម ផ្លូវភេទ ឬផ្នែកណាមួយនៃរាងកាយ ត្រូវចាត់ទុកថា ជាការជួញដូរ។ កុមារមិនចាំបាច់បង្ហាញថា គេត្រូវបានបង្ខំ ឬគ្រប់គ្រងឡើយ។ វាគ្រប់គ្រាន់ ហើយត្រឹមតែបង្ហាញថា មានសកម្មភាពរបស់នរណាម្នាក់ដាក់កុមារឲ្យស្ថិតក្នុងស្ថានភាពកេងប្រវ័ញ្ច។

ពន្យល់ថា បើទោះបីជាការជួញដូរភាគច្រើនពាក់ព័ន្ធនឹងការផ្លាស់ទីក៏ដោយ ក៏អាចមានជនណាម្នាក់ត្រូវបានគេជួញដូរដោយមិនបាច់ផ្លាស់ទីផងដែរ។

ឲ្យអ្នកចូលរួមបង្កើតក្រុមដែលមានគ្នាពីរនាក់។ឲ្យពួកគេបើកសៀវភៅត្រង់ចំណុចស្ដីពី"អ្វីជាការជួញដូរមនុស្ស?" "អ្វីជាការធ្វើចំណាកស្រុក?" នៅក្នុងកូនសៀភៅនារីកវៃឆ្លាត ទំព័រទី២ សុំអោយពួកគេអានទាំងអស់គ្នា និងកំណត់សំណួរដែលគេមាន។ តើពួកគេអាចជួយគ្នាក្នុងការប្រើប្រាស់កូនសៀវភៅជាមុនសិនបានដែរ ឬទេ? ប្រសិនបើមិនអាចទេ គេអាចសួរសំណួរ ទៅអ្នកបាន។

## កំណត់ហេតុ

ឲ្យក្រុមសរសេរ ឬគូរនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ របស់ខ្លួនអំពីមនុស្ស ដែលគេស្គាល់បានចាកចេញពីភូមិដើម្បីទៅរកការងារធ្វើនៅកន្លែងដែលគេបានទៅ និងការងារដែលគេ កំពុងធ្វើ។ ឲ្យអ្នកចូលរួមសរសេរផងដែរថា តើគេគិតថា អ្នកទាំងនោះ មានសុវត្ថិភាពដែរ ឬទេ។

១៥ នាទីបន្ទាប់ ប្រមូលសៀវភៅកំណត់ហេតុ ហើយចាក់សោទុកក្នុងប្រអប់។ មិនត្រូវ សុំឲ្យអ្នកចូលរួម ចែករំលែកពីព័ត៌មានដែលបានសរសេរចូលក្នុងសៀវភៅកំណត់ហេតុឡើយ។

**សេចក្តីសង្ខេបមេរៀន**

- ពាក្យថា ការធ្វើចំណាកស្រុក មានន័យថា ជាដំណើរដែលបុគ្គលម្នាក់ផ្លាស់ទីកន្លែង ដើម្បីរកការងារធ្វើ។ ពាក្យថា ជនចំណាកស្រុក សំដៅដល់មនុស្ស។ មិនមែន ជនចំណាកស្រុកទាំងអស់ សុទ្ធតែត្រូវបានជួញដូរនោះទេ។
- ការជួញដូរមនុស្សមានធាតុផ្សំបី ៖
  ១.សកម្មភាព៖ ការជ្រើសរើសចូលធ្វើការ ការដឹកជញ្ជូន ការផ្ទេរ ការឃុំឃាំងទុក ឬការទទួលយកមនុស្ស។
  ២.មធ្យោបាយ ៖ (មិនតម្រូវសំរាប់កុមារ ដែលមានអាយុក្រោម ១៨ ឆ្នាំ និងក្មេងជាងនេះទេ)៖ ការគំរាមកំហែង ឬប្រើការបង្ខំ ទម្រង់ផ្សេងៗនៃការគៀបសង្កត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភអំណាច។
  ៣.គោលបំណង៖ ការកេងប្រវ័ញ្ច (កំលាំងពលកម្មដោយបង្ខំ, ទាសភាព ពេស្យាកម្ម/ផ្លូវភេទ ការកាត់ យកសរីរាង្គកាយ)។
- ការជួញដូរកុមារ។ ប្រសិនបើកុមារត្រូវបានកេងប្រវ័ញ្ចដើម្បីការងារ ផ្លូវភេទ ឬសរីរាង្គកាយ នឹងត្រូវចាត់ទុកជាការជួញដូរ។ សម្រាប់កុមារដែលត្រូវបានជួញដូរ គឺគេមិនចាំបាច់ បង្ហាញថារូបគេត្រូវបានបង្ខំ ឬគ្រូតគ្រាលើនោះទេ។
- ការជួញដូរមនុស្សខុសប្លែកពី ការរត់ពន្ធមនុស្ស ពីព្រោះមនុស្សជ្រើសរើសយកវិធីឲ្យគេរត់ពន្ធខ្លួន៖ ពួកគេមិនជ្រើសរើសយកវិធីឲ្យគេជួញដូរទេ។

**ការបិទវគ្គ**

ឲ្យអ្នកចូលរួមសរសេរ ឬ សួរសំណួរ និង/ឬ ផ្តល់ព័ត៌មានត្រឡប់មកវិញ និងប្រគល់ឲ្យអ្នកសម្របសម្រួលដោយមិនបញ្ចេញឈ្មោះ។

ប្រាប់ថា អ្នកនឹងនៅក្នុងបន្ទប់រៀន ១០ នាទីបន្ថែមទៀតបន្ទាប់ពីរៀនមេរៀនចប់ ក្រែងអ្នកចូលរួមមានសំណួរអ្វី ឬចង់ពិភាក្សាជាមួយអ្នកដោយផ្ទាល់ខ្លួន។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថា ពេលនេះគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។

## ការជួញដូរមនុស្ស

ស ជាក្មេងស្រីម្នាក់មានអាយុ ១៩ ឆ្នាំ រស់នៅក្នុងប្រទេស មីយ៉ាន់ម៉ា។ មីងរបស់ ស បានប្រាប់នាងថា គាត់អាចរកការងារល្អមួយ ឲ្យនាងធ្វើនៅប្រទេសម៉ាឡេស៊ី។ ស ត្រូវបានគេបញ្ជូនទៅកាន់ទីក្រុង យ៉ង់ហ្គោន។ បន្ទាប់មកនាងបានស្នាក់នៅក្នុងផ្ទះមួយកន្លែងដែលមានក្មេងស្រី បួន ប្រាំនាក់មកពីភូមិផ្សេង ទៀតរស់នៅទីនោះ។ ស រស់នៅក្នុងផ្ទះនោះរយៈពេល ៣ សប្ដាហ៍។ មានស្ត្រីម្នាក់ដែលមើលការខុសត្រូវលើពួកគេ ហើយបានយកលិខិតឆ្លងដែន និងឯកសារផ្សេងទៀតពីពួកគេ។ ពួកគេទទួលបានអាហារហូបចុកប៉ុន្តែមិនត្រូវ បានអនុញ្ញាតឲ្យចេញក្រៅផ្ទះឡើយ។ ពួកគេត្រូវបានចាក់សោឃុំទុក។
បន្ទាប់មកទៀត ស បានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី ។ នាងបានធ្វើការងារឲ្យគ្រួសារមួយ។ គេបានប្រាប់នាងថា នាងជំពាក់ប្រាក់គេថ្លៃធ្វើដំណើរ ថ្លៃធ្វើលិខិតឆ្លងដែន និងថ្លៃអាហារទាំងអស់ ដូច្នេះនាងត្រូវធ្វើការសងបំណុលរយៈពេល៣ ឆ្នាំដោយមិនទទួលបានប្រាក់ខែ។
គេបានចាក់សោបង្ខាំងនាងទុកនៅក្នុងផ្ទះល្វែងមួយ ហើយគេបានប្រាប់នាងមិនឲ្យចាកចេញពីផ្ទះនោះ ឬទូរស័ព្ទទៅគ្រួសាររបស់នាងឡើយ។

## ការជួញដូរមនុស្ស

វ គឺជាបុរសក្មេងម្នាក់រស់នៅក្នុងប្រទេសឡាវ។ មិត្តភក្តិរបស់គេជាច្រើននាក់បានធ្វើដំណើរទៅប្រទេសថៃដើម្បីរកការងារធ្វើ ហើយ វ បានសម្រេចចិត្តទៅ តាមមិត្តរបស់គេដែរ។ គាត់បានជួបបុរសម្នាក់ដែលបុរសនោះបានប្រាប់គាត់ថា គេនឹងចេញសាហ៊ុយធ្វើដំណើរឲ្យគាត់ហើយ វ អាចសងវិញដោយកាត់ ប្រាក់ខែខ្លះពីប្រាក់ខែថ្មីរបស់គាត់។ វ បានធ្វើដំណើរជាមួយបុរសនោះឆ្លងកាត់ព្រំដែនទៅកាន់ប្រទេសថៃ ប៉ុន្តែពេលទៅដល់កន្លែងធ្វើការ គឺខុសពីអ្វីដែល បុរសនោះបានសន្យា។ គាត់ត្រូវតែធ្វើការងារច្រើនម៉ោង ហើយប្រសិនបើគាត់ខឹងមេការ នឹងត្រូវដាក់ទោសដោយយករំពាត់ ដែករុកចូលច្រមុះគាត់។ គាត់ចង់ចាកចេញ ប៉ុន្តែគាត់ នៅជំពាក់ប្រាក់គេថ្លៃធ្វើដំណើរ ហើយម្ចាស់រោងចក្រប្រាប់ថា គាត់នឹងទូរស័ព្ទហៅប៉ូលីសមកចាប់ វ ប្រសិនបើគាត់ចង់ចាកចេញ។

## ការជួញដូរមនុស្ស

ម គឺជាស្ត្រីវ័យក្មេងម្នាក់មកពីប្រទេសវៀតណាម។ ម្ដាយរបស់នាងមាន ជំងឺ ដូច្នេះ នាងបានទៅរកអ្នកជិតខាងដែលជាអ្នកមានម្នាក់ដើម្បីសាកសួរថា គេ អាច ជួយនាងឲ្យរកការងារធ្វើបានដែរឬទេ? អ្នកជិតខាងបានឆ្លើយថា គេ អាចជួយនាងបាន គឺធ្វើការនៅក្នុងទីក្រុង ហូជីមិញ ជាអ្នក លាងចាននៅក្នុងភោជនីយដ្ឋានមួយកន្លែង។ ម បានព្រមព្រៀងប៉ុន្តែនៅ ពេលនាងទៅដល់ ហូជីមិញ ទើបនាងដឹងថា ភោជនីយដ្ឋាននោ ការពិត គឺជាផ្ទះបនមួយ។ វាយឺតពេលទៅហើយ ម្ចាស់ផ្ទះបននោះបាន ប្រាប់ថា ម អាចស្នាក់នៅផ្ទះបននោះមួយយប់ ហើយព្រឹកឡើងចាំចាកចេញ។ លុះព្រឹកឡើងម្ចាស់ផ្ទះបននោះបានប្រាប់ ម ថា អ្នកជិតខាងនាង ដែលជាអ្នកមាននោះបានលក់នាងឲ្យគាត់ហើយ។ ម្ចាស់ផ្ទះបន បាន ប្រាប់ ទៀតថា ពេលនេះ ម ត្រូវលក់ផ្លូវភេទដើម្បីសងលុយថ្លៃគេទិញនាងវិញ បើមិនដូច្នេះទេប៉ូលីសនឹងបង្ក្រាបញ្ញាដល់ម្ដាយរបស់ ម។ ម ត្រូវស្នាក់នៅ និង ធ្វើការងារជាស្រីពេស្យានៅក្នុងផ្ទះបន។



## ការធ្វើចំណាកស្រុក

ស ជាក្មេងស្រីម្នាក់មានអាយុ ១៩ ឆ្នាំ រស់នៅក្នុងប្រទេស មីយ៉ាន់ម៉ា។ មីងរបស់ ស បានប្រាប់នាងថា គាត់អាចរកការងារល្អមួយ ឲ្យនាងធ្វើនៅប្រទេសម៉ាឡេស៊ី។ ស បានយល់ព្រម។ ស បានចាកចេញទៅកាន់ទីក្រុង យ៉ង់ហ្គោន ហើយបន្ទាប់មកបានស្នាក់នៅក្នុងផ្ទះមួយកន្លែងដែលមានក្មេងស្រី បួន ប្រាំនាក់មកពីភូមិផ្សេងទៀតរស់នៅទីនោះ។ ស រស់នៅក្នុងផ្ទះនោះរយៈពេល ៣ សប្ដាហ៍។ មានស្ត្រីម្នាក់ដែលមើលការខុសត្រូវលើពួកគេ ហើយបានយកលិខិតឆ្លងដែន និងឯកសារផ្សេងទៀតពីពួកគេ។
បន្ទាប់មកទៀត ស បានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី ។ នាងបានធ្វើការងារឲ្យគ្រួសារមួយរយៈពេល ៣ ឆ្នាំ ហើយទទួលបានប្រាក់ខែតិចតួច។

## ការធ្វើចំណាកស្រុក

វ គឺជាបុរសក្មេងម្នាក់រស់នៅក្នុងប្រទេសឡាវ។ មិត្តភក្តិរបស់គេជាច្រើននាក់បានធ្វើដំណើរទៅប្រទេសថៃដើម្បីរកការងារធ្វើ ហើយ វ បានសម្រេចធ្វើដូចមិត្តរបស់គេដែរ។ គាត់បានជួបបុរសម្នាក់ដែលបុរសនោះបានប្រាប់គាត់ថា គេអាចរកការងារ ឲ្យគាត់ធ្វើបាន គឺនៅក្នុងរោងចក្រកែច្នៃត្រីមួយកន្លែង។ ការងារលំបាកណាស់ហើយគាត់ត្រូវបានគេរំពឹងថានឹងធ្វើការងារច្រើនម៉ោង។ គាត់ទទួលបានប្រាក់ខែតិចតួច ប៉ុន្តែគ្រប់គ្រាន់សម្រាប់រស់។ វ ធ្វើការនៅក្នុងរោងចក្រនោះរយៈពេល ៣ ឆ្នាំ។

## ការធ្វើចំណាកស្រុក

ម គឺជាស្ត្រីវ័យក្មេងម្នាក់មកពីប្រទេសវៀតណាម។ ម្ដាយរបស់នាងមានជំងឺ ដូច្នេះ នាងបានទៅរកអ្នកជិតខាង ដែលជាអ្នកមានម្នាក់ ដើម្បីសាកសួរថា គេអាចជួយនាងឲ្យរកការងារធ្វើបានដែរ ឬទេនៅក្នុងទីក្រុង ហូជីមិញ ដែលធ្វើជាអ្នកលាងចាននៅក្នុងភោជនីយដ្ឋានមួយកន្លែង។ ម បាន ធ្វើដំណើរទៅកាន់ទីក្រុង ហូជីមិញ ជាទីដែលនាងចាប់ផ្ដើមធ្វើការជាអ្នកលាងចាន និងអ្នកជូតសម្អាត។ ការងារលំបាកខ្លាំងណាស់ ហើយ ម នៅតែឯង ប៉ុន្តែនាងអាចសន្សំប្រាក់ខែរបស់នាង និងផ្ញើអ្វីដែលនាងអាចរកបានទៅឲ្យម្ដាយរបស់នាង។

# ៣ IS ៣ខ ៖ តើអ្វីជាការជួញដូរមនុស្ស? តើអ្វីជាការធ្វើចំណាកស្រុក?

ដោយយោងតាមមាត្រា ៣ កថាខ័ណ្ឌ (ក) នៃពិធីសារប៉ាលើម៉ូគី : បានកំនត់និយមន័យជាអន្តរជាតិ សម្រាប់ពាក្យ ការជួញដូរមនុស្ស គឺជាការជ្រើសរើសឲ្យធ្វើការងារ ការដឹកជញ្ជូនការផ្ទេរការផ្តល់ជម្រកខុសច្បាប់ ឬការទទួលយកមនុស្ស តាមរយៈមធ្យោបាយនៃការគំរាមកំហែង ឬទម្រង់នៃការបង្ខិតបង្ខំផ្សេងទៀត ការកាត់យកសរីរាង្គកាយ ការក្លែងបន្លំ ការបោកប្រាស់ការរំលោភ អំណាច ឬ ស្ថានភាពជាការងាយរងគ្រោះ ឬតាមមធ្យោបាយប្រគល់ ឬទទួលប្រាក់ ឬ អត្ថប្រយោជន៍ ផ្សេងៗ ដើម្បីទទួលបានការឯកភាពរបស់បុគ្គលណាម្នាក់ដែលគ្រប់គ្រងលើអ្នកដទៃ សម្រាប់ គោលបំណងកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចរួមមាន:អំពើពេស្យាកម្មលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទក្នុងទម្រង់ផ្សេងទៀត ការធ្វើការងារដោយបង្ខំ ឬបម្រើសេវានានាទាសភាព ឬការប្រព្រឹត្តស្រដៀងគ្នានឹង ទាសភាព សេវភាព ឬការកាត់យកនូវសរីរាង្គ ។
ការជួញដូរមនុស្សមានធាតុផ្សំ ៣ ដែលមានបង្ហាញដូចខាងក្រោម ។

| សកម្មភាព | | មធ្យោបាយ | | គោលបំណង | |
|---|---|---|---|---|---|
| ការជ្រើសរើសឲ្យធ្វើការ<br>ការដឹកជញ្ជូន<br>ការផ្ទេរ<br>ការផ្តល់ជម្រកខុសច្បាប់<br>ការទទួលយកមនុស្ស | + | គំរាមកំហែង ឬប្រើការបង្ខិតបង្ខំ<br>ការគាបសង្កត់<br>ការជំរិត<br>អំពើក្លែងបន្លំ<br>ការបោកប្រាស់<br>ការរំលោភអំណាច ឬភាពងាយរងគ្រោះ<br>ការផ្តល់នូវប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀត | + | ការកេងប្រវ័ញ្ច រួមមាន ៖ ការធ្វើពេស្យាកម្ម<br>លើអ្នកដទៃ<br>ការកេងប្រវ័ញ្ចផ្លូវភេទ<br>ការងារដោយបង្ខំ<br>ទាសភាព ឬស្រដៀងនឹងការប្រព្រឹត្តលើបែបទាសភាព<br>ការកាត់យកសរីរាង្គកាយ<br>ការកេងប្រវ័ញ្ចផ្សេងៗទៀត | = ការជួញដូរមនុស្ស |



**ការជួញដូរមនុស្ស ៖** គឺជាការបោកបញ្ឆោត ឬការបង្ខិតបង្ខំមនុស្សឲ្យធ្លាក់ចូលក្នុងទម្រង់ការងារបែបកេងប្រវ័ញ្ចដែលមានការលំបាកខ្លាំងក្នុងការចាកចេញ។ ជារឿយៗការជួញដូរមនុស្សច្រើនពាក់ព័ន្ធជាមួយ ការនាំយកជនរងគ្រោះ ចេញពីកន្លែងដែលពួកគេរស់នៅ ទៅកាន់កន្លែងដទៃទៀតដោយការបង្ខំក្នុងគោលបំណងដើម្បីគេងប្រវ័ញ្ចលើពួកគេ។

**ការបង្ខំ ៖** ពន្យល់ថា នៅពេលដែលមនុស្សត្រូវបានគេជួញដូរគឺគាត់ត្រូវបានគេបង្ខំ ក្នុងរូបភាពផ្សេងៗ។ អ្នកខ្លះត្រូវបានគេជួញដូរដោយគេប្រាប់ថា ខ្លួននឹងទទួលបានការងារល្អនៅពេលដែលទៅដល់គោលដៅ បន្ទាប់មក ពួកគាត់ត្រូវបានបង្ខំឲ្យធ្វើការងារផ្សេងទៅវិញ។ អ្នកខ្លះទៀតត្រូវបានចាក់សោទុកនៅក្នុងរោងចក្រ ឬនៅលើទូក ហើយមិនអាចចាកចេញបានទេ។ អ្នកខ្លះទៀតគេគំរាមថា អ្នកជួញដូរនឹងធ្វើបាបគេ ឬគ្រួសារគេបើគេចាកចេញ។ ទាំងនេះគឺជាឧទាហរណ៍ខុសៗគ្នានៃការបង្ខំ

**ការបោកបញ្ឆោត ៖** ពន្យល់ថា ការបោកប្រាស់ បង្ហាញពីសកម្មភាពនៃការបិទបាំង ឬការថ្លែងភូតកុហក់ពីការពិត ឬភាពមិនស្មោះត្រង់។

**កេងប្រវ័ញ្ច ៖** នៅពេលដែលជនណាប្រើប្រាស់អ្នកដទៃជាធម្មតាគឺដើម្បីផលចំណេញ គឺជននោះកំពុងកេងប្រវ័ញ្ចគេហើយ។ នៅពេលដែលបុគ្គលណាម្នាក់ត្រូវបានគេជួញដូរនោះ គឺគេអាចនឹងត្រូវបានគេកេងប្រវ័ញ្ចដោយការង្ខំឲ្យធ្វើការងារដែលគាត់មិនចង់ធ្វើ បង្ខំឲ្យធ្វើការងារបានកម្រៃតិចតួច ឬមិនមានកម្រៃតែម្តង បង្ខំឲ្យធ្វើការងារទាក់ទងនឹងផ្លូវភេទ ឬអាចនឹងត្រូវបានគេកាត់យកសរីរាង្គកាយដើម្បីលក់។

**ការជួញដូរកុមារ ៖** ប្រសិនបើកុមារត្រូវបានកេងប្រវ័ញ្ចដើម្បីការងារផ្លូវភេទ ឬសរីរាង្គកាយនឹងត្រូវចាត់ទុកជាការជួញដូរ។ សម្រាប់កុមារដែលត្រូវបានជួញដូរ គឺគេមិនចាំបាច់បង្ហាញថា រូបគេត្រូវបានបង្ខំ ឬគ្រួតត្រាលើនោះទេ។

**ការធ្វើចំណាកស្រុក ៖** មានន័យថា ជាដំណើរការដែលមនុស្សម្នាក់ផ្លាស់ទីដើម្បីរកការងារធ្វើ។ ពាក្យថា ជនចំណាកស្រុក សំដៅដល់មនុស្ស ។

# ៤ មេរៀនទី ៤ ៖ ការជួញដូរមនុស្សអាចកើតមានគ្រប់ទិសទី

## ចំណុចបំណង

អ្នកចូលរួមនឹងយល់អំពីនិយមន័យនៃអ្នកជួញដូរមនុស្ស ។ ការជួញដូរ មនុស្សអាចកើតមានគ្រប់ទិសទី ហើយវាអាចមានអ្នកជួញដូរមនុស្សច្រើនជាង ម្នាក់នៅក្នុង ដំណើរការជួញដូរមនុស្សក្នុងមួយលើកៗ។ អ្នកជួញដូរអាចជា "មិត្តភ័ក្តិ" អ្នកជិតខាង មនុស្សចម្លែក ឬអាចជាសាច់ញាតិផងដែរ។

## ពេលវេលា

៨០ នាទី

## ការត្រៀម

ព្យួរ "IS ៤ខ ៖ សញ្ញាប្រាប់ពីទីកន្លែង" នីមួយៗនៅ លើជញ្ជាំង ជាជួរដោយទុកចន្លោះប្រហែល ២ ម៉ែត្រពីសញ្ញាមួយទៅមួយ។

## សម្ភារៈ

- ថតចម្លង " IS ៤ខ ៖ ប័ណ្ណស្តីពីការធ្វើដំណើរ" ប្រហែល ៥ ច្បាប់ កាត់ចេញពីគ្នាតាមរឿងនីមួយៗ (អ្នកចូលរួមម្នាក់ ត្រូវការរឿងមួយ ហើយមានរឿងចំនួន ៥ នៅក្នុងលំហាត់ IS នេះ)
- សរសេរ "IS ៤ខ ៖ សញ្ញាប្រាប់ទីកន្លែង" នីមួយៗជាអក្សរធំៗ លើសន្លឹកក្រដាសដាច់ដោយឡែកពីគ្នាមួយ។
- សម្គាល់លើច្បាប់ចម្លងនីមួយៗនៃលំហាត់ "IS ៤គ៖ រូបភាពរបស់អ្នកជួញដូរមនុស្ស" ។ ការបរិយាយអំពីអ្នកជួញដូរ មនុស្សនៅផ្នែកខាងក្រោមនៃរូបភាពនីមួយៗគឺជាឯកសារយោង ប៉ុន្តែមិនត្រូវបញ្ចូល ទេពេលដែលរូបភាពទាំងនេះត្រូវបានប្រើក្នុងមេរៀន។

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើអ្វីជាការធ្វើចំណាកស្រុក?

តើអ្វីជាការជួញដូរមនុស្ស?

តើការរត់ពន្ធមនុស្សខុសពីការជួញដូរមនុស្សដូចម្តេច?

(លើកទឹកចិត្តឲ្យអ្នកចូលរួមមើលឯកសារព័ត៌មានកាលពីសប្តាហ៍មុន ប្រសិនបើគេច្រឡំ)

## ប័ណ្ណធ្វើដំណើរ និងអ្នកជួញដូរមនុស្ស

ពន្យល់ទៅកាន់អ្នកចូលរួមថា មានមនុស្សដែលទទួលបានអត្ថប្រយោជន៍ពីផ្នែកនីមួយៗនៃដំណើរការជួញដូរមនុស្ស។ អ្នកទាំងនេះ ជាញឹកញាប់គេហៅថា អ្នកជួញដូរមនុស្ស។ ជនជួញដូរមនុស្ស គឺជាអ្នកដែល ដឹងពីអត្ថប្រយោជន៍ដោយការជ្រើសរើសឲ្យធ្វើការងារ ការផ្ទេរ ការរក្សាទុក ឬ ការកេងប្រវ័ញ្ចទៅលើបុគ្គលម្នាក់។ ជាញឹកញាប់ មិនមែនមានតែអ្នកជួញដូរតែ

ម្នាក់នោះទេ ប៉ុន្តែមានអ្នកជួញដូរច្រើននាក់នៅក្នុងដំណើរការនេះ។
ប្រាប់ដល់អ្នកចូលរួមថា មេរៀននេះនិយាយអំពី ការធ្វើដំណើរ ដែលជនចំណាកស្រុកធ្វើដំណើរចេញពីផ្ទះទៅកាន់កន្លែងធ្វើការថ្មី។
ប្រាប់ដល់អ្នកចូលរួមថា មេរៀននេះនឹងនិយាយពីរបៀប និងពេលវេលាដែលជនចំណាកស្រុកអាចប្រឈមមុខត្រូវបានគេជួញដូរក្នុងអំឡុងពេលនៃការធ្វើដំណើរ។
ចែកឯកសារ "IS ៤ខ៖ ប័ណ្ណស្ដីពីការធ្វើដំណើរ" ។
ចង្អុលទៅកាន់ "IS ៤ខ ៖ សញ្ញាប្រាប់ពីទីកន្លែង" នៅលើជញ្ជាំង។ ពន្យល់ប្រាប់ថា ស្លាកសញ្ញាត្រូវបានព្យួរជាជួរ ពីព្រោះវាតាងឲ្យដំណាក់កាលនីមួយៗ នៃការធ្វើដំណើរដែលជនចំណាកស្រុកធ្វើ។ ប្រាប់ឲ្យអ្នកចូលរួមបែងចែកជាក្រុមមានគ្នាពី ៣-៥ នាក់។ ឲ្យពួកគេអានប័ណ្ណស្ដីពីការធ្វើដំណើរនីមួយៗ នៅក្នុងក្រុមរបស់គេ ហើយបន្ទាប់មកដើរទៅ នឹងឈរនៅខាងមុខសញ្ញានីមួយៗ ដែលតំណាងត្រូវជាងគេបំផុតអំពីកន្លែងដែលជនចំណាកស្រុកនៅក្នុងរឿងរបស់គេ កំពុងត្រូវ បានជួញដូរ។ សុំឲ្យអ្នកចូលរួមនីមួយៗកាន់ប័ណ្ណរបស់ខ្លួន ។ ប្រសិនបើសិក្ខាកាមមានប័ណ្ណដូចគ្នា ប៉ុន្តែឈរនៅកន្លែងផ្សេងពីគ្នា លើកទឹកចិត្តឲ្យគេពន្យល់ថា ហេតុអ្វីបានជាគេជ្រើសយកកន្លែងនោះ។ ពន្យល់ការយល់មិនត្រឹមត្រូវទាំងឡាយដោយទន់ភ្លន់។
ពន្យល់ប្រាប់គេថា ជនចំណាកស្រុកអាចត្រូវបានគេជួញដូរនៅក្នុងប្រទេសរបស់គេផ្ទាល់ ឬឆ្លងកាត់ព្រំដែនអន្តរជាតិ។
ពេលនេះ ដកសញ្ញាប្រាប់ពីទីកន្លែងចេញ និងដាក់ជំនួសវិញដោយផ្ទាំង "IS ៤ខ ៖ រូបភាពអំពីអ្នកជួញដូរមនុស្ស" ។ សុំឲ្យអ្នកចូលរួមឈរនៅពីមុខរូបនីមួយៗ ដែលបង្ហាញ ពីអ្នក ជួញដូរមនុស្ស ដូចដែលមានរៀបរាប់នៅក្នុងប័ណ្ណស្ដីពីការធ្វើដំណើររបស់គេ។ ប្រើប្រាស់ទិន្នន័យដែលថា ជាញឹកញាប់មានអ្នកជួញដូរមនុស្សច្រើនជាងម្នាក់នៅក្នុងរឿងរបស់គេដើម្បីលើកទឹកចិត្តដល់ការពិភាក្សាអំពី តើអ្វីទៅជាការជួញដូរមនុស្ស។ ជាថ្មីម្ដងទៀត លើកទឹកចិត្តដល់ការពិភាក្សាអំពីជម្រើសនានា និងកែតម្រូវការយល់ឃើញមិនត្រឹមត្រូវទាំងឡាយដោយទន់ភ្លន់។

## ការពិភាក្សា

ឲ្យអ្នកចូលរួមអង្គុយជារង្វង់មូលមួយរួច សួរគេថា ៖

- តើអ្នកមានអារម្មណ៍រំភើបដែរ ឬទេតាមរយៈអ្វីដែលបានសិក្សាថ្ងៃនេះ?
- តើអ្នកបានដឹងទេថា ការជួញដូរអាចកើតមាននៅក្នុងចំណុចណានៃការធ្វើដំណើរ?
- តើអ្នកបានដឹងទេថា អ្នកជួញដូរអាចជា "មិត្តភ័ក្តិ" អ្នកជិតខាង មនុស្សមិនធ្លាប់ស្គាល់ ឬអាចជាសមាជិកគ្រួសារដែរ ឬទេ?
- តើអ្នកអាចប្រើប្រាស់អ្វីដែលបានរៀនថ្ងៃនេះនៅក្នុងជីវិតពិតរបស់ខ្លួនបានដែរ ឬទេ?

## កំណត់ហេតុ

នៅពេលដែលការពិភាក្សាបានបញ្ចប់ អ្នកចូលរួមប្រហែលជាត្រូវការពេលវេលាខ្លះ ដើម្បីរៀបចំសំណួរទាំងនេះ។ ប្រសិនបើនៅសល់ពេល ទុកពេលឲ្យអ្នកចូលរួម សរសេរកំណត់ហេតុប្រចាំថ្ងៃរបស់គេ។

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមចែកជាក្រុមមានគ្នាពី ៨-១២ នាក់។ ឲ្យក្រុមនីមួយៗ ត្រៀមរៀបចំការសម្តែងរឿង ដោយផ្អែកលើស្ថានភាពខាងក្រោម ៖

តួអង្គសំខាន់គឺអ្នកចំណាកស្រុកម្នាក់ដែលកំពុងជិះរថយន្តក្រុង។ មនុស្សម្នាក់ដែលអង្គុយជាប់នាងកំពុងព្យាយាមបញ្ចុះបញ្ចូលនាងឲ្យទៅជាមួយគាត់ ដើម្បីបានធ្វើការងារដែលបានប្រាក់កម្រៃខ្ពស់។

ឲ្យក្រុមជួយគិតដល់នារីម្នាក់នោះដើម្បីរកវិធីនិយាយថាទេ។

ទុកពេល ៥នាទីឲ្យក្រុមទាំងអស់ដើម្បីរៀបចំការសម្តែងនេះ។ បន្ទាប់មកឲ្យពួកគេសម្តែងម្តងម្នាក់។ អ្នកសម្របសម្រួលគួររៀបរាប់នូវវិធីទាំងអស់ដែលអ្នកដំណើរម្នាក់នោះត្រូវនិយាយថា ទេនិងចែករំលែកជាមួយក្រុម។ ឧទាហរណ៍មានដូចខាងក្រោម ៖

- "ខ្ញុំមានការណាត់ជួបជាមួយនឹងនិយោជកមួយរួចទៅហើយ។"
- "ខ្ញុំនឹងពិភាក្សាអំពីគំនិតរបស់អ្នកជាមួយនឹងឪពុកម្តាយរបស់ខ្ញុំ ហើយខ្ញុំនឹងទូរស័ព្ទទៅអ្នកនៅថ្ងៃស្អែក។"
- "ខ្ញុំមិនជឿអ្នកទេ។"
- ហេតុអ្វីបានអ្នកសួរខ្ញុំ តើអ្នកមិនមានបងប្អូន និងញាតិមិត្តជាច្រើនដែលចង់ធ្វើការងារនេះទេឬ?
- នៅស្ងៀម។ មិនបាច់ខ្វល់ពីអ្នកដំណើរម្នាក់នោះឡើយ។
- សួរសំណួរច្រើនទៅអ្នកដំណើរនោះ។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំភ្លឺបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។ ប្រសិនបើមានអ្នកចូលរួមណាដែលស្គាល់មិត្តភក្តិ ឬគ្រួសារ ឬអ្នកជិតខាងដែលធ្លាប់ត្រូវបានគេជួញដូរ ឬធ្វើជាអ្នកជួញដូរ វាអាចជាការល្អដែលត្រូវរំឭកជាមួយគេក្រោយពេលបញ្ចប់ការប្រជុំនេះ ប្រសិនបើមើលទៅហាក់បីដូចជាមានជះឥទ្ធិពលលើរូបគេ។ ប្រសិនបើគេត្រូវការការគាំទ្របន្ថែម សូមជូនដំណឹងមកកាន់បុគ្គលិករបស់អង្គការទស្សនៈពិភពលោក។

### ការសង្ខេបមេរៀន

- មនុស្សអាចនឹងត្រូវបានគេជួញដូរនៅគ្រប់ទីកន្លែង ៖ ពីផ្ទះរបស់គេពេលកំពុងធ្វើដំណើរ ពេលទៅដល់គោលដៅ និងបន្ទាប់ពីធ្វើការងារ។
- អ្នកជួញដូរមនុស្សអាចជា "មិត្តភ័ក្តិ" អ្នកជិតខាង មនុស្សមិនធ្លាប់ស្គាល់ និយោជកជាដើម។
- អ្នកជួញដូរមនុស្ស អាចជាអ្នកមកពីភូមិរបស់អ្នក ខេត្តរបស់អ្នក ឬ មកពីទីឆ្ងាយ។

## រឿងទី ១

ប មានអាយុ ១៨ ឆ្នាំ ដែលធ្វើដំណើរទៅទីក្រុង និងទទួលបានការងារនៅក្នុងរោងចក្រកាត់ដេរមួយកន្លែង។ នាងមិនពេញចិត្តនឹងការងារនោះទេ។ នាងបានជួបស្ត្រីម្នាក់មកពីខេត្តដូចនាងដែរស្ត្រីនោះនិយាយថា គេអាចជួយ ប ដើម្បីបានការងារល្អជាងនេះធ្វើ។ ប ជឿស្ត្រីម្នាក់នោះ និងបានទៅជាមួយគាត់ដើម្បីទៅធ្វើការនៅរោងចក្រថ្មីនោះ ប ត្រូវបង់ថ្លៃចុះឈ្មោះចូលធ្វើការក្នុងតម្លៃថ្លៃទៅឲ្យម្ចាស់រោងចក្រនោះ។ ម្ចាស់រោងចក្រនិយាយថា គេនឹងកាត់យកពីប្រាក់ខែរបស់នាង។ ម្ចាស់រោងចក្របានដកយកឯកសាររបស់នាងដើម្បីធ្វើឲ្យប្រាកដថា នាងមិនអាចចាកចេញបាន។

ប មិនបានទទួលប្រាក់ខែនោះទេ ដោយសារនាងជំពាក់ប្រាក់។ ប បានដឹងពីកម្មករដទៃថា“មិត្តភក្តិ” របស់នាងនោះ តែងទទួលបានប្រាក់ជានិច្ច សម្រាប់គ្រប់កម្មករទាំងអស់ ដែលនាងនាំមករោងចក្រនេះ។

## រឿងទី ២

វ ជាក្មេងប្រុសអាយុ ១៩ ឆ្នាំ ដែលរស់នៅក្នុងភូមិមួយនៃប្រទេសកម្ពុជា។ អ្នកជិតខាងរបស់គាត់ ម្នាក់បាន ជួយដល់គាត់ឲ្យរកការងារធ្វើនៅក្នុងរោងចក្រត្រីខកំប៉ុងមួយកន្លែងនៅក្នុងទីក្រុងបាងកក។ អ្នកជិតខាងនោះគឺជាឈ្មួញកណ្តាល ហើយគាត់បាននិយាយថា គាត់នឹងចេញប្រាក់ថ្លៃសោហ៊ុយធ្វើដំណើរឲ្យ វ ហើយ វ អាចសងត្រឡប់គេវិញពេលក្រោយ។ ប្រហែលមួយខែក្រោយមកទៀត អ្នកជិតខាងនោះបាននាំ វ ទៅឲ្យបុរសម្នាក់ផ្សេងទៀត ដែលបុរសនោះបានដកហូតយកឯកសាររបស់ វ ហើយបានដឹក វ តាមរថយន្តដឹកអ្នកដំណើរមួយឆ្លងកាត់ព្រំដែនចូលទៅក្នុងប្រទេសថៃ។ នៅពេលគេទៅដល់កំពុងផែ ប៉ាក់ណាម បុរសនោះបានប្រាប់ វ ថា គេត្រូវតែធ្វើការនៅលើទូករយៈពេលមួយខែមុនពេលគេអាចធ្វើការនៅក្នុងរោងចក្របាន។ វ មិនស្គាល់នរណាម្នាក់នៅក្នុងប្រទេសថៃ និងមិនមានប្រាក់គ្រប់គ្រាន់ដើម្បីត្រឡប់ទៅផ្ទះវិញទេ។ គេនៅតែជំពាក់ប្រាក់អ្នកជិតខាងរបស់គេដដែល។ វ បានឡើងទូក ហើយជាក់ស្តែងត្រូវបានគេបង្ខំឲ្យធ្វើការងារនៅលើទូក ដោយមិនទទួលបាន កម្រៃរយៈពេល ២ ឆ្នាំ។

## រឿងទី ៣

ព រស់នៅក្នុងភូមិតូចមួយនៅក្នុងភាគខាងជើងប្រទេសថៃ។ នៅពេលនាងមានអាយុ ១៦ឆ្នាំ នាងបានជិះរថយន្តមកក្រុងបាងកកដើម្បីរកការងារធ្វើ។ មីងរបស់នាងបានណាត់ជួបនាងនៅចំណត រថយន្តក្រុង។ ប៉ុន្តែនៅពេលនាងមកដល់ចំណតរថយន្ត មីងរបស់នាងមិនបានទៅទីនោះទេ។ ព មានការភ័យខ្លាចណាស់ ប៉ុន្តែមានស្ត្រីម្នាក់បានខិតចូលមកជិតនាង ហើយសួរទៅនាងថា តើគាត់អាចជួយនាងបានដែរទេ។ ស្ត្រីម្នាក់នោះបាននិយាយថានិងផ្តល់កន្លែងឲ្យនាងស្នាក់នៅ និងជួយនាងឲ្យជួយនាងម្តាយរបស់នាង។ ប៉ុន្តែផ្ទុយមកវិញស្ត្រីម្នាក់នោះបានយកនាងទៅ ធ្វើការនៅផ្ទះបន។ ព ត្រូវបានគេប្រាប់ថាពេលនេះ នាងនឹងត្រូវធ្វើការនៅផ្ទះបន។ នាងការបដិសេធមិនព្រមធ្វើការនៅទីនោះទេព្រោះមានតែនាងម្នាក់ឯង។

## រឿងទី ៤

ប រស់នៅក្នុងប្រទេស មីយ៉ាន់ម៉ា។ នៅពេលគេមានអាយុ ១៦ ឆ្នាំ គាត់បានបង់ប្រាក់ឲ្យទៅបុរសម្នាក់ឲ្យ ជួយគាត់ឆ្លងកាត់ព្រំដែន។ បន្ទាប់មកគាត់បានជិះរថយន្តក្រុងចេញដំណើរទៅទិសខាង ត្បូងតែម្នាក់ឯង។ គាត់បានរាប់អានមិត្តម្នាក់នៅលើរថយន្តក្រុងនោះ មិត្តនោះបានប្រាប់ថា គេធ្វើ ការងារនៅក្នុងរោងចក្រមួយនិងអាចជួយដល់បឲ្យរកការងារធ្វើនិងទទួលបានប្រាក់ខែខ្ពស់។បុរសនោះបាននាំប ជិះរថយន្តដឹកអ្នកដំណើរខ្នាតតូចមួយទៅកាន់រោងចក្រ។ នៅពេលគេទៅដល់រោងចក្រ ម្ចាស់រោងចក្រប្រាប់ថា ប បានជំពាក់ថ្លៃធ្វើដំណើរតាមរថយន្តដឹកអ្នកដំណើរនោះ ហើយត្រូវតែធ្វើការដើម្បីសងត្រឡប់វិញ។ ប មិនដឹងជាធ្វើយ៉ាងម៉េចដើម្បីត្រឡប់ទៅផ្ទះវិញបាន ព្រោះគាត់មានប្រាក់តិចតួចបំផុត។ គេមិនដែលបានជួបជាមួយនឹង “មិត្តភក្តិ” ដែលគេស្គាល់នៅលើរថយន្តក្រុងនោះទាល់តែសោះ។

## រឿងទី ៥

ត មកពីគ្រួសារក្រីក្រមួយនៅប្រទេសវៀតណាម។ គេមិនដែលចាកចេញពីស្រុកកំណើតរបស់គេឡើយ។ ប៉ុន្តែ ត មានបងប្អូនជាអ្នកមានម្នាក់ដែលរស់នៅទីក្រុងហូជីមិញ។ នៅពេល ត មានអាយុ ១៦ ឆ្នាំ បងប្អូនអ្នកមាននោះបានណែនាំ ត មករស់នៅក្នុងផ្ទះរបស់ខ្លួន និងធ្វើ ការងារនៅក្នុង ភោជនីយដ្ឋានមួយ។ បងប្អូននោះ បាននិយាយថា ការធ្វើបែបនេះនឹងជួយដល់គ្រួសាររបស់ ត ។ នៅពេលមកដល់ទីក្រុង នាងបានរស់នៅជាមួយនឹងបងប្អូននាងនោះ និងសម្អាតផ្ទះរបស់គេ។ ប៉ុន្តែ ភ្លាមៗ ក្រោយពេលនាងមកដល់ បងប្អូនរបស់នាងបាននាំនាងទៅផ្ទះបុរសម្នាក់ផ្សេងទៀត។ បងប្អូនរបស់នាងបានប្រាប់នាងថា បើនាងមិនរួបភេទជាមួយនឹងបុរសនោះទេ នាងនឹងបាត់បង់ការងាររបស់នាង។ ត ក៏យល់ព្រមធ្វើតាមគេ ។

**ចម្លើយ** (មិនត្រូវផ្តល់ចំលើយដល់អ្នកចូលរួម រហូតទាល់ហ្មែបញ្ចប់)។

| **ទីតាំង** | **អ្នកជួញដូរមនុស្ស** |
|---|---|
| រឿងទី ១. ការមកដល់ | រឿងទី ១. មិត្តភក្តិ ៖ ម្ចាស់រោងចក្រ |
| រឿងទី ២. នៅផ្ទះ | រឿងទី ២. អ្នកជិតខាង ៖ បុរសម្នាក់ទៀត ម្ចាស់ទូក |
| រឿងទី ៣. នៅចំណតរថយន្តក្រុង | រឿងទី ៣. ស្ត្រីម្នាក់នៅចំណតរថយន្តក្រុង ម្ចាស់ផ្ទះបន |
| រឿងទី ៤. ពេលកំពុងធ្វើដំណើរ | រឿងទី ៤. “មិត្តភក្តិ” នៅចំណតរថយន្តក្រុង ម្ចាស់រោងចក្រ |
| រឿងទី ៥. បន្ទាប់ពីចាប់ផ្តើមធ្វើការងារ | រឿងទី ៥. សាច់ញាតិដែលជាអ្នកមាន |

**ទីកន្លែងនីមួយៗ គួរសរសេរនៅលើសន្លឹកក្រដាសមួយ ជាអក្សរធំៗ**

**១. ការចាប់ផ្តើម**
(រាប់ទាំងនៅផ្ទះផង)

**២. ការមកដល់**

**៣. ការធ្វើដំណើរ**

**៤. ចំណតរថយន្តក្រុង**

**៥. បន្ទាប់ពីធ្វើការងារ**



1. ‘មិត្តភក្តិ’ ម្នាក់ (ស្ត្រីវ័យក្មេង)



2. ទៅកែរោងចក្រ



៣.អ្នកជិតខាង



៩. បុរសម្នាក់ផ្សេងទៀត



៥. ម្ចាស់ទូក (បុរសចំណាស់)




៦. ស្ត្រីម្នាក់នៅចំណតរថយន្តក្រុង



៧. ម្ចាស់ផ្ទះបន (ស្ត្រី)



៨. មិត្តភ័ក្តិ ម្នាក់នៅលើរថយន្តក្រុង (ជាបុរសក្មេង)



៩. ថៅកែឃ្លាំងចក្រ (ជា បុរសម្នាក់)



១០. បងប្អូនជាអ្នកមាន (ជាបុរសម្នាក់)

# ៥ មេរៀនទី ៥ ៖ ការរើសអើងភេទការដាក់ឲ្យស្ត្រី និងក្មេងស្រីស្ថិតក្នុងហានិភ័យនៃការជួញដូរមនុស្ស

## វត្ថុបំណង

អ្នកចូលរួមនឹងចាប់ផ្តើម យល់អំពីផលប៉ះពាល់នៃការរំពឹងទុកតាមភេទក្នុងសង្គម ហើយនឹងពិចារណា អំពីកត្តាទាំងនេះពាក់ព័ន្ធជាមួយនឹងការជួញដូរមនុស្ស។

## ពេលវេលា

៨០ នាទី

## សម្ភារៈ

- សរសេរ "ｱ៥ក ៖ ភាពខុសគ្នារវាងបុរស និងស្ត្រី" សម្រាប់ជាឯកសារយោងរបស់អ្នកសម្របសម្រួល
- ក្រដាសផ្ទាំងធំសម្រាប់ ៣-៤ ក្រុម
- ប៊ិចក្រហម និងខៀវ

## ការត្រៀម

ចំណាំសម្រាប់អ្នកសម្របសម្រួល៖ អង្គការទស្សនៈពិភពលោកមិនមានការរើសអើង ផ្អែកលើភេទទេ។ អ្នកអាចនឹងឃើញមានក្រុមប្រកាន់ខ្ជាប់នូវទស្សនៈបែបរើសអើង ឧទាហរណ៍៖ គេអាចនឹងនិយាយថា "ការអប់រំក្មេងប្រុសមានសារៈសំខាន់ជាងក្មេងស្រី" ឬ "បុរសគួរជាអ្នកដែលធ្វើការសម្រេចចិត្តគ្រប់បែបយ៉ាងទាំងអស់ នៅក្នុងគ្រួសារ ពីព្រោះបុរសមានភាពឆ្លាតវៃជាង"។ ក្នុងនាមជាអ្នកសម្របសម្រួល អ្នកត្រូវដោះស្រាយទស្សនៈយល់ឃើញទាំងនេះ និង បង្ហាញពីជំនឿរបស់អង្គការទស្សនៈពិភពលោក ឧទាហរណ៍ដូចជា " នៅក្នុងអង្គការទស្សនពិភពលោក យើងគិតថា ការអប់រំក្មេងស្រី គឺមានសារៈសំខាន់ដូចគ្នានឹងការ អប់រំក្មេងប្រុសដែរ" ឬ "យើងគិតថា ស្ត្រីមានភាពឆ្លាតវៃដូចគ្នានឹងបុរសដែរ"។ វាមានសារៈសំខាន់ណាស់ ដែលត្រូវព្យាយាមសម្តែងការគោរពចំពោះវប្បធម៌របស់អ្នកចូលរួមនៅពេលអ្នកបង្ហាញពីស្ថានភាពនេះ។

## សេចក្តីផ្តើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតគ្នានូវក្រដាសចុះហត្ថលេខាវត្តមាន។

### សកម្មភាពមុនចាប់ផ្តើម

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

### ការរំឭកមេរៀន

តើការជួញដូរមនុស្សអាចកើតមានគ្រប់ទិសទីបានដែរ ឬទេ? (បាទ/ចាស់!)

តើមានកន្លែងណាខ្លះដែលយើងនិយាយអំពីការជួញដូរដែលកើតមាននៅក្នុងមេរៀនលើកមុន?

## ការពិភាក្សា

ពន្យល់ថា នៅក្នុងមេរៀននេះ នឹងនិយាយអំពីភាពខុសគ្នារវាងបុរស និងស្ត្រី។

ប្រាប់សិស្សឲ្យបែងចែកជាក្រុមមានគ្នាពី ៥-៦ នាក់។ ឲ្យពួកគេគិតពីឧទាហរណ៍ឲ្យបានច្រើនតាមដែលអាចធ្វើបានពីភាពខុសគ្នារវាងបុរស និងស្ត្រី និងត្រូវសរសេរឧទាហរណ៍ទាំងនេះនៅលើក្រដាសផ្ទាំងធំនៅក្នុងក្រឡោនជា ២៖ បុរស និងស្ត្រី។ ពេលគេកំពុងធ្វើកិច្ចការ សួរថា ៖

- តើអ្វីជាភាពខុសគ្នារវាងបុរស និងស្ត្រីចំពោះ រូបរាង និងការស្លៀកពាក់ ?
- តើអ្វីខ្លះជាភាពខុសគ្នានៃកិច្ចការផ្ទះរវាងបុរស និងស្ត្រី ?
- តើអ្វីខ្លះជាប្រភេទខុសគ្នានៃការងារ ដែលបុរស និងស្ត្រី?
- តើមានភាពខុសគ្នាអ្វីខ្លះរវាងបុរស និងស្ត្រីក្នុងការកំសាន្តសប្បាយ?
- តើនរណាអាចធ្វើដំណើរ តែឯងបាន?

ឲ្យក្រុមមើលតារាងសកម្មភាពរបស់គេអំពីសកម្មភាពដែលបុរស និងស្ត្រីធ្វើ។ ឲ្យក្រុមគូសបន្ទាត់ក្រហមនៅពីក្រោមសកម្មភាពណាដែលជាលទ្ធផលនៃកត្តាជីវសាស្ត្រ និងបន្ទាត់ខៀវនៅពីក្រោមសកម្មភាពណាដែលជាលទ្ធផលនៃកត្តាសង្គម។ នៅពេលដែលពួកគេបានបញ្ចប់តារាង ឬគូសក្រោមសកម្មភាពនីមួយៗរួចរាល់ ឲ្យពួកគេចែករំលែកនូវអ្វីដែលពួកគេបានគូសដែលជាលទ្ធផលនៃកត្តាសង្គម។ នៅចំពោះមុខក្រុមទាំងអស់ កត់ត្រាចម្លើយរបស់ពួកគេនៅលើក្រដាសផ្ទាំងធំមួយនៅក្នុងតារាងមានពីរកាឡោន៖ កត្តាជីវសាស្ត្រ និងកត្តាសង្គម។ (ឧទាហរណ៍ ស្ត្រីមានកូន គឺដោយសារកត្តាជីវសាស្ត្រ ប៉ុន្តែបុរសមានសក់ខ្លីគឺដោយសារកត្តាសង្គម)។

អ្នកសម្របសម្រួលត្រូវមើលកិច្ចការ "IS ៥ក៖ ភាពខុសគ្នារវាងបុរស និងស្ត្រី" ដើម្បីពិនិត្យចម្លើយ។

ពន្យល់ថា ភាពខុសគ្នាភាគច្រើនរវាងបុរស និងស្ត្រីគឺដោយសារកត្តាសង្គម ឬវប្បធម៌ (គូសបន្ទាត់ក្រោមជាពណ៌ខៀវ)។ ទាំងនេះគឺជាភាពខុសគ្នាដែលអាចផ្លាស់ប្តូរបានប្រសិនបើនរណាម្នាក់ចង់ធ្វើ។

## ការពិភាក្សា

ឲ្យអ្នកចូលរួមបែងចែកក្រុមដោយមានគ្នាពី ៤-៦ នាក់។ បែងចែកដាច់ពីគ្នារវាងក្មេងប្រុស និងក្មេងស្រី ដើម្បីឲ្យក្រុមខ្លះ មានតែក្មេងប្រុសសុទ្ធ និងក្រុមខ្លះមានតែក្មេងស្រីសុទ្ធ។ បន្ទាប់មកឲ្យក្រុម នីមួយៗ ពិភាក្សាគ្នាអំពីសំណួរទាំងនេះ ៖

- តើនរណាជាអ្នករកប្រាក់បានច្រើនជាង នៅក្នុងវប្បធម៌របស់យើងជាបុរស ឬស្ត្រី?
- តើនរណាជាអ្នកដែលធ្វើកិច្ចការសម្អាត និងការយកចិត្តទុកដាក់លើយុវជនច្រើនជាងបំផុត? ជាក្មេងប្រុស ឬក្មេងស្រី?
- តើនរណាទៅរៀនបានយូរជាង? ជាក្មេងប្រុស ឬក្មេងស្រី?
- តើនរណាជាអ្នកធ្វើសេចក្តីសម្រេចចិត្ត លើការចំណាយធំៗ (ដូចជាការទិញម៉ូតូមួយ) ជាបុរស ឬស្ត្រី?
- តើនរណាជាអ្នករក្សាកេរ្តិ៍ដីធ្លី នៅពេលឪពុកម្តាយបានស្លាប់ទៅ? ជាកូនស្រី កូនប្រុស ឬទាំងពីរ?
- តើអ្នកគិតថា វប្បធម៌របស់យើងមានភាពយុត្តិធម៌ដែរ ឬទេចំពោះក្មេងប្រុស និងក្មេងស្រី?

នៅពេលដែលពួកគេបានបញ្ចប់ ឲ្យគេចែករំលែក ចម្លើយរបស់គេ ជាមួយនឹងក្រុមទាំងមូល។ ក្មេងស្រីអាចផ្តល់ចម្លើយខុសគ្នា ខ្លាំងពីក្មេងប្រុស។ ប្រសិនបើមានករណីនេះ សួរទៅកាន់ក្រុមថាហេតុអ្វីបានជាបែបនេះ ។

ពន្យល់ប្រាប់ថា ការជួញដូរអាចកើតមានចំពោះទាំងបុរស និងស្ត្រី។ អង្គការពលកម្មពិភពលោក

(ILO) បានប៉ាន់ប្រមាណថា ចំនួនបុរស និងស្ត្រីដែលត្រូវបានគេជួញដូរឲ្យធ្លាក់ចូលក្នុងការងារដោយបង្ខំគឺមានចំនួនស្មើរស្មើគ្នា។ ប៉ុន្តែ អង្គការនេះក៏បានប៉ាន់ប្រមាណផងដែរថា ៩៨ ភាគរយនៃជនរងគ្រោះនៃការជួញដូរ ផ្លូវភេទ គឺជាស្ត្រី។ ពន្យល់ថា វាក៏អាចកើតមានដែរ ដែលក្មេងប្រុសត្រូវបានគេជួញដូរសម្រាប់គោលបំណងផ្លូវភេទផងដែរ ប៉ុន្តែវាមិនសូវកើតមានទេ។

ឲ្យអ្នកចូលរួម លើកឧទាហរណ៍មួយចំនួន អំពីរបៀបដែលការរំពឹងទុក នៃសង្គមធ្វើឲ្យស្ត្រីមានភាពងាយរងគ្រោះច្រើនជាងចំពោះការជួញដូរផ្លូវភេទ។

នៅពេលដែលអ្នកចូលរួមបានផ្តល់ចម្លើយរួច ត្រូវប្រាកដថា អ្នកបានលើកឡើងនូវ ឧទាហរណ៍ខាងក្រោម ប្រសិនបើអ្នកចូលរួមមិនទាន់បានលើកឡើង ៖

- ស្ត្រីចាកចេញពីសាលាមុន និងមិនអាចរកការងារជំនាញបានទេ។
- នៅក្នុងសហគមន៍របស់យើង ការងារសម្រាប់ក្មេងស្រីមានតិចជាងក្មេងប្រុស។
- បុរស អាចនឹងទៅផ្ទះបនដើម្បីរួមភេទជាមួយស្ត្រី។
- ប្រសិនបើ ក្មេងស្រីមិនអាចទទួលកេរ្តិ៍ដី ពីឪពុករបស់ខ្លួន នៅពេលដែលគាត់ស្លាប់ទៅទេនោះ នាងអាចនឹងក្លាយជាអ្នកគ្មានដីធ្លី និងគ្មានទីពំនាក់។
- ក្មេងស្រីដែលធ្វើជាអ្នកបម្រើតាមផ្ទះ អាចនឹងងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទដោយម្ចាស់ផ្ទះ។

ឲ្យអ្នកចូលរួមពិចារណាអំពីមធ្យោបាយដែលក្មេងប្រុស និងបុរសអាចការពារក្មេងស្រី និងស្ត្រីបាន កាន់តែប្រសើរនៅក្នុងជីវិតរបស់ខ្លួន។ ស្របជាមួយគ្នានេះដែរ ឲ្យអ្នកចូលរួម ពិចារណាផងដែរអំពីមធ្យោបាយ ដែលក្មេងស្រី និងស្ត្រីអាចត្រូវបានផ្តល់អំណាចឲ្យដើម្បីការពារខ្លួនឯងនិងក្មេស្រី និងស្ត្រីផ្សេងទៀត នៅក្នុងជីវិតរបស់ខ្លួន។

នៅពេលដែលពួកគេ ផ្តល់ចម្លើយរបស់គេ ត្រូវប្រាកដថា អ្នកបានលើកឡើងនូវ ឧទាហរណ៍ខាងក្រោម ប្រសិនបើពួកគេមិនទាន់បានចែករំលែក ៖

- ផ្តល់ឱកាសដល់ស្ត្រីដើម្បីចូលរួមក្នុងការងារដែលទូទៅគេទុកឲ្យក្មេងប្រុសធ្វើ។
- លើកកម្ពស់ការបណ្តុះបណ្តាលពីបំណិនជីវិត និងជំនាញបច្ចេកទេស សម្រាប់ក្មេងស្រីមុនពេលធ្វើចំណាកស្រុក។
- ជួយស្ត្រីឲ្យយល់ អំពីតួនាទី និងការរំពឹងទុកនានា នៃការងារមួយចំនួនតាមរយៈការ ទទួលបានព័ត៌មានគួរទុកចិត្តបានមុនពេលពួកគេធ្វើចំណាកស្រុក។
- ក្មេងប្រុស និងបុរសគួរទទួលខុសត្រូវសម្រាប់ចំពោះកូនៗរបស់ខ្លួន ហើយមិនត្រូវទម្លាក់ការទទួលខុសត្រូវនោះទៅលើតែក្មេងស្រី/ស្ត្រីតែឯងឡើយ។

## ការសម្តែងតួ

ឲ្យអ្នកចូលរួមបែងចែកជាក្រុមមានគ្នាពី ៨-១២នាក់។ ឲ្យក្រុមនីមួយៗ រៀបចំការសម្តែងរឿង (ប្រសិនបើអ្នកមានក្រុមទាំងអស់លើសពីពីរក្រុម អ្នកអាចប្រើប្រាស់រឿងខាងក្រោមពីរដងបាន។)

*ក្រុមទី១៖* តួអង្គសំខាន់គឺជាក្មេងស្រីអាយុ១៥ឆ្នាំម្នាក់ ដែលម្តាយរបស់នាងចង់ឲ្យនាងឈប់រៀនដើម្បីទៅរកប្រាក់ទ្រទ្រង់ការអប់រំប្អូនប្រុសរបស់នាង។ ចូរប្រាប់ឲ្យក្រុមជួយគិតរកមធ្យោបាយ

ដើម្បីបញ្ចុះបញ្ចូលម្តាយរបស់នាងដើម្បីទុកឲ្យនៅបន្តការសិក្សាបាន។

*ក្រុមទី ២ ៖* តួអង្គសំខាន់គឺជាក្មេងស្រីម្នាក់ដែលគ្រួសាររបស់នាងចង់លក់នាងជាលក្ខណៈការរៀបការក្លែងក្លាយទៅប្រទេសចិន។ ឲ្យក្រុមជួយដល់នាងគិតអំពីមធ្យោបាយដើម្បីបញ្ចុះបញ្ចូលគ្រួសាររបស់នាងដែលនាងគួរតែត្រូវនៅផ្ទះវិញ។

ប្រាប់ក្រុមឲ្យរៀបចំការសម្តែងតរយៈពេល ១០ នាទី បន្ទាប់សម្តែងមួយក្រុមម្តងៗ ។

**ការសង្ខេបមេរៀន**

- មានភាពខុសគ្នាផ្នែកជីវសាស្ត្រមួយចំនួនរវាងបុរស និងស្ត្រីប៉ុណ្ណោះដែលមិនប្រែប្រួល
- មានភាពខុសគ្នាផ្នែកវប្បធម៌មួយចំនួនរវាងបុរស និងស្ត្រីដែលអាច និងពិតជាផ្លាស់ប្តូរ។
- មានភាពខុសគ្នាផ្នែកវប្បធម៌ខ្លះ មិនយុត្តិធម៌សម្រាប់ស្ត្រីទេ។
- ការរំពឹងទុកផ្នែកវប្បធម៌មួយចំនួនទុកឲ្យស្ត្រី និងក្មេងស្រីស្ថិតក្នុងហានិភ័យខ្លាំងនៃការជួញដូរផ្លូវភេទច្រើនជាងបុរស និងក្មេងប្រុស។
- ស្ត្រីមួយភាគធំត្រូវបានគេជួញដូរសម្រាប់គោលបំណងផ្លូវភេទច្រើនជាងបុរស។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកទាំងអស់គ្នាដែលបានមករៀនព្រមទាំង បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។

ប្រាប់ពួកគេឲ្យតាមមើលប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់គេហើយឆ្លើយសំណួរខាងក្រោម ៖

- តើក្មេងប្រុស និងក្មេងស្រី ត្រូវបានគេប្រព្រឹត្តលើ ដោយខុសគ្នាយ៉ាងដូចម្តេចខ្លះ នៅក្នុងសហគមន៍ របស់អ្នក?
- តើបុរស និងស្ត្រីត្រូវបានគេប្រព្រឹត្តលើដោយខុសគ្នាយ៉ាងដូចម្តេចខ្លះនៅក្នុងសហគមន៍របស់អ្នក?

អ្នកសម្របសម្រួលអាច ប្រាប់អ្នកចូលរួមឲ្យសរសេរសំណួរទាំងនេះនៅលើក្រដាស និងយកទៅផ្ទះដើម្បីរំឭកដល់ពួកគេ។

សម្រាប់តែជាឯកសារយោងរបស់អ្នកសម្របសម្រួលប៉ុណ្ណោះ។ មិនត្រូវថតចម្លងចែកសិស្សទេ។

## ចម្លើយសម្រាប់សកម្មភាពស្តីពីតួនាទីយេនឌ័រ

### កត្តាជីវសាស្ត្រ

ស្ត្រីអាចពរពោះ។
ស្ត្រីអាចបំបៅដោះកូនបាន។
បុរសដុះពុកចង្កា។
ស្ត្រីមានសុដន់។

### កត្តាសង្គម

បុរសលេងបាល់ទាត់។
បុរសមានសក់ខ្លី។
នារីមានសក់វែង។
នារីស្លៀករ៉ូប។
បុរសផឹកស្រាបៀរ។
ស្ត្រីមើលថែក្មេងៗ។
ស្ត្រីសម្អាតផ្ទះសម្បែង។
បុរសធ្វើការក្នុងក្រុមការងារសាងសង់។
បុរសធ្វើការសម្រេចចិត្តធំៗនៅក្នុងគ្រួសារ។
បុរសជាអ្នកទទួលមរតកដីធ្លី។
ស្ត្រីមិនគួរធ្វើដំណើរតែឯងទេ។

# មេរៀនទី ៦ ៖ ផលប៉ះពាល់នៃគ្រឿងញៀន និងគ្រឿងស្រវឹងក្នុងការជួញដូរមនុស្ស

៦

## វត្ថុបំណង

អ្នកចូលរួមនឹងរៀនសូត្រពីនិយមន័យនៃថ្នាំញៀន និងរូបរាងរបស់វា។ អ្នកចូលរួមនឹងយល់អំពីរបៀបដែលអាចការពារខ្លួនគេកាន់តែប្រសើរ តាមរយៈការយល់ដឹងអំពីរបៀបដែលគ្រឿងញៀន និង គ្រឿងស្រវឹងអាចត្រូវបានប្រើប្រាស់ដោយអ្នកជួញដូរ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ចង់មួយ
- ប័ណ្ណមានរូបភាពផ្សេងៗ គ្នាអំពីគ្រឿងញៀនខុសច្បាប់នៅម្ខាង និងការរៀបរាប់អំពីគ្រឿងញៀននៅម្ខាងទៀតពី " too៦ក៖ប័ណ្ណអំពីគ្រឿងញៀន"
- ច្បាប់ថតចម្លងនៃ "ទេ ៦ខ ៖ ប័ណ្ណអំពីគ្រឿងញៀន" (គ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗដែលមានគ្នាចាប់ពី ៤-៥ នាក់ គឺអាចមួយច្បាប់។)
- ច្បាប់ថតចម្លងមួយច្បាប់នៃ "ទេ ៦គ ៖ សម្រង់សម្តីអំពីគ្រឿងញៀន" កាត់ចេញពីគ្នា។

## សេចក្តីផ្តើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវក្រដាសចុះហត្ថលេខាវត្តមាន។

### សកម្មភាពមុនចាប់ផ្តើម

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

### ការរំឭកមេរៀន

តើមាននរណាបានអង្កេតមើលលើតួនាទីនៃយែនឌ័រនៅក្នុងសហគមន៍ដែរ ឬទេ?

តើអ្នកបានកត់សម្គាល់ឃើញអ្វីខ្លះលើអ្វីដែលអ្នកមិនធ្លាប់បានសម្គាល់ពីមុន ដោយយោងតាមការពិភាក្សាក្នុងអំឡុងពេលនៃម៉ោងសិក្សាពីមុន?

តើមានតួនាទីណាខ្លះដែលអ្នកចង់ផ្លាស់ប្តូរដែរ ឬទេ?

## ការពិភាក្សា

### តើអ្វីជាគ្រឿងញៀន ?

សួរទៅកាន់ក្រុមថា តើគេអាចប្រាប់អ្នកបានដែរ ឬទេថា គ្រឿងញៀនជាអ្វី។ ឲ្យសិស្សរៀបរាប់អំពីប្រភេទគ្រឿងញៀនខុសៗគ្នា និងផលប៉ះពាល់ដែលវាមាន។

បន្ទាប់មក ពន្យល់ថា គ្រឿងញៀនមានទម្រង់ជាថ្នាំគ្រាប់ ម្សៅ ជារុក្ខជាតិ ឬជាសារធាតុរាវ។ វាអាចត្រូវគេជក់ ចាក់បញ្ចូល ស្រូបជាលក្ខណៈម្សៅ ឬលេប។

ពន្យល់ថា គ្រឿងញៀនបានផ្លាស់ប្តូរផ្លូវដែលអ្នកមើល ផ្លូវដែលអ្នកដឹងរស់ជាតិ ផ្លូវដែលអ្នកមានអារម្មណ៍ ផ្លូវដែលអ្នកធ្វើសកម្មភាព។

ហុចតៗគ្នានូវចង់ដែលមានប័ណ្ណនិយាយអំពីគ្រឿងញៀន។ ឲ្យអ្នកចូលរួមចាប់យករូបភាព និងអានសេចក្តីបរិយាយនៅផ្នែកខាងក្រោយ។

ប្រសិនបើអ្នកចូលរួមមានការភ្ញាក់ផ្អើល ក្នុងការដែលដឹងថា គ្រឿងស្រវឹងក៏ជាសារធាតុញៀនដែរនោះ សួរទៅគេ អំពីរបៀបដែលគ្រឿងស្រវឹងផ្លាស់ប្តូរផ្លូវដែលមនុស្សមានអារម្មណ៍ គិតធ្វើសកម្មភាព នៅពេលដែលគេសេពវា។

នៅពេលដែលសេចក្តីបរិយាយទាំងអស់ត្រូវបានអានចប់ ឲ្យអ្នកចូលរួមពិភាក្សាអំពីគ្រឿងញៀនទូទៅដែលពួកគេធ្លាប់បានឮ។ឧទាហរណ៍ដូចជា មេតំហ្វេតាមីនដែលគេស្គាល់ម្យ៉ាងថាជា យ៉ាបា យ៉ាម៉ា ម៉េត និងទឹកកកនៅតាមប្រទេសផ្សេងៗ។

បន្ទាប់មកឲ្យអ្នកចូលរួមផ្តល់ឧទាហរណ៍អំពីអ្វីដែលគេបានដឹងអំពីគ្រឿងញៀន។ ឧទាហរណ៍ អ្នកចូលរួមអាចនឹងនិយាយថា ៖

"ទឹកកក អាចធ្វើឲ្យអ្នកស្រកទម្ងន់ និងមានស្បែកភ្លឺថ្លា"។

"យ៉ាបាព្យាបាលជំងឺ"

អ្នកត្រូវឆ្លើយតបថា ៖

"ទឹកកក/យ៉ាបាគឺជា ឈ្មោះគេហៅខុសគ្នានៃថ្នាំញៀនប្រភេទតែមួយប៉ុណ្ណោះគឺ ៖ មេតំហ្វេតាមីន ។ វានឹងធ្វើឲ្យស្រកទម្ងន់ ប៉ុន្តែមិនបានធ្វើឲ្យស្បែកភ្លឺថ្លានោះទេ។ វាអាចបំផ្លាញ បេះដូង សរសៃប្រសាទ និងធ្មេញរបស់អ្នកយ៉ាងធ្ងន់ធ្ងរ ហើយវាអាចបង្កឲ្យអ្នកមានភាពវង្វេងវង្វាយ និង មានការភ័យខ្លាច។

បន្ទាប់មកសួរទៅអ្នកចូលរួមថា តើគេអាចរៀបរាប់បានដែរ ឬទេអំពីការញៀន។ សង្ខេបនិងបញ្ជាក់ច្បាស់លាស់អំពីអ្វីដែលគេបាននិយាយដោយបញ្ជាក់ថា ៖ ការញៀនកើត ឡើងនៅពេលដែលរាងកាយ និងអារម្មណ៍ត្រូវការគ្រឿងញៀននៅពេលណាដែលកម្រិតគ្រឿងញៀននៅក្នុងរាងកាយមានកម្រិតទាប។ នៅពេលដែលមនុស្សញៀនថ្នាំ ហើយគេមិនអាចទទួលបានថ្នាំនោះរាងកាយ និងអារម្មណ៍របស់គេចង់សេពគ្រឿងម្តងទៀត។ បន្តិចម្តងៗ គេនឹងក្លាយទៅជាអ្នកមិនអាចអត់គ្រឿងញៀនបាន ដែលធ្វើឲ្យរាងកាយរបស់គេដំណើរការមិនត្រឹមត្រូវប្រសិនបើគ្មានគ្រឿងញៀនទេនោះ។ ពេលខ្លះការញៀននឹងបង្កឲ្យមានផលប៉ះពាល់ដល់រាងកាយ ដែលធ្វើឲ្យមនុស្សញាក់ញ័រ ឬបែកញើស ឬឈឺក្បាល ឬមានអារម្មណ៍កណ្តោចកណ្តែងខ្លាំងទាល់តែគេបានសេពវាម្តងទៀត។

គ្រឿងញៀន និងគ្រឿងស្រវឹងធ្វើទុក្ខទោសដល់មនុស្សក្នុងរូបភាពខុសគ្នា ៖

- វាអាចបង្កការបំផ្លាញរយៈពេលវែង ដល់រាងកាយ ធ្វើទុកដល់បេះដូង សួត ថ្លើម និង តម្រងនោមរបស់អ្នក។
- មនុស្សប្រើច្រើនលើសកម្រិតដោយសេពគ្រឿងញៀនច្រើនហួសដោយខុសឆ្គង ហើយជាលទ្ធផល គេអាចនឹងស្លាប់បាន។
- មនុស្សអាចនឹងឆ្លងមេរោគអេដស៍ និងជំងឺផ្សេងៗទៀតតាមរយៈការប្រើម្ជុលរួមគ្នាដើម្បីចាក់ថ្នាំញៀន។
- គ្រឿងញៀនអាចផ្លាស់ប្តូររបៀបដែលខួរក្បាលរបស់អ្នកដំណើរការ និងធ្វើឲ្យអ្នកមានការភ័យខ្លាច ឬវង្វេងវង្វាយ។
- គ្រឿងញៀន ធ្វើឲ្យអ្នកហ៊ានប្រថុយ ធ្វើអ្វីដែលជាធម្មតា អ្នកមិនហ៊ានធ្វើ ដូចជាការរួមភេទ

ដោយមិនប្រើស្រោមអនាម័យ ការបើកបរពេលស្រវឹង ការវាយតប់គ្នា ឬរួមភេទជាមួយមនុស្ស ដែលអ្នកស្គាល់មិនច្បាស់។

**គ្រឿងញៀនអាចបង្កើនហានិភ័យដល់អ្នកកាន់តែខ្ពស់ចំពោះការដែលត្រូវបានគេជួញដូរ**

ពន្យល់ថា នៅពេលដែលមនុស្សសេពគ្រឿងញៀន រួមទាំងគ្រឿងស្រវឹងនោះដែរ គឺគេមិនបាន គិតច្បាស់លាស់ ហើយគេហានប្រថុយប្រថាន។

ពន្យល់ថា នៅពេលដែលអ្នកមិនបានគិតច្បាស់លាស់ ហើយថែមទាំងការហ៊ានប្រថុយទៀត នោះ អ្នកកំពុងស្ថិតក្នុងគ្រោះថ្នាក់ដ៏ខ្លាំងនៃការដែលត្រូវបានគេជួញដូរ ។

ប្រាប់ទៅសិស្សថា ក៏មានករណីដែលមនុស្សសេពគ្រឿងស្រវឹងច្រើនហួសប្រមាណដល់ ថ្នាក់ដេកលក់ ហើយត្រូវបានគេជួញដូរក្នុងអំឡុងពេលកំពុងលង់លក់នោះ។ គេភ្ញាក់ឡើងនៅលើទូកនេសាទ។ ឲ្យសិស្សបែងចែកជាក្រុមដែលមានគ្នាពី ៤ ឬ ៥ នាក់។ ផ្តល់ឲ្យក្រុមនីមួយៗ នូវរឿងមួយពី "IS ៦ខ៖ គ្រឿងញៀន និងគ្រឿងស្រវឹង" ។ ប្រសិនបើ SNYC របស់អ្នកមានអ្នក សម្របសម្រួលជាយុវជន ឲ្យគេធ្វើការសម្របសម្រួលការពិភាក្សា។ ឲ្យក្រុមនីមួយៗបន្តរឿងរបស់ខ្លួន រៀបរាប់ពន្យល់ពីរបៀបដែលគ្រឿងញៀន និងគ្រឿងស្រវឹងអាចនាំទៅរកការជួញដូរមនុស្ស។ ១០ នាទីក្រោយមក ឲ្យក្រុមទាំងអស់ចែករំលែកនូវចម្លើយរបស់ខ្លួន។

**គ្រឿងញៀន និងការងារ**

សួរថា តើមាននរណាធ្លាប់ឮថា ថៅកែឲ្យថ្នាំញៀនទៅនិយោជិតដែរ ឬទេ។ អនុញ្ញាតិឲ្យសិស្សផ្តល់ ឧទាហរណ៍របស់គេ បន្ទាប់មកពន្យល់ថា ពេលខ្លះថៅកែអគតិមួយចំនួនផ្តល់ថ្នាំញៀនឲ្យទៅ និយោជិត ដើម្បីឲ្យពួកគេខំធ្វើការខ្លាំង ឬដើម្បីជាមធ្យោបាយមួយដើម្បីគ្រប់គ្រងលើពួកគេ។

ចែកនូវសម្រង់សម្តីខាងក្រោមដោយផ្អែកលើរឿងនៃជីវិតពិតពី " IS ៦គ ៖ សម្រង់សម្តីអំពីគ្រឿង ញៀន" និងឲ្យសិស្សស្ម័គ្រចិត្តមួយចំនួនអានឲ្យឮៗ។

"ខ្ញុំបានធ្វើការនៅលើទូកបង្គារមួយ។ យើងចេញទូកទៅសមុទ្រម្តងៗមានរយៈពេលរាប់ខែ។ ម្ចាស់ ទូកឲ្យថ្នាំមួយគ្រាប់ឲ្យយើងលេបរាល់ព្រឹក។ ថ្នាំនោះធ្វើឲ្យយើងមានអារម្មណ៍ថាមានកម្លាំង ហើយយើងខំប្រឹងធ្វើការងារខ្លាំងណាស់ ប៉ុន្តែព្រឹកបន្ទាប់ យើងទាំងអស់គ្នាឈឺក្បាលខ្លាំងមែនទែន"។ (ថ្នាំនោះគឺ យ៉ាម៉ា)។

"ខ្ញុំធ្លាប់ធ្វើការងារនៅក្នុងអណ្តូងរ៉ែមួយកន្លែង។ ការងារនោះពិតជាលំបាកខ្លាំងណាស់ ដោយយើងត្រូវចំណាយពេលពេញមួយថ្ងៃនៅក្រោមដី។ ដូច្នេះបុរសជាច្រើននាក់ធ្វើការនៅទីនោះញៀនហេរ៉ូអ៊ីន។ ថៅកែៗចូលចិត្តវា ហើយពេលខ្លះគេផ្តល់វាឲ្យ ពីព្រោះវាមានន័យថា យើងមិនចង់ចាកចេញពីកន្លែងធ្វើការនេះទេពីព្រោះយើងបានញៀនថ្នាំនោះរួចទៅហើយ។ ជាមួយគ្នានេះដែរគឺយើងមានការនឿយហត់នឹងការត្អូញត្អែរដោយសារតែគ្រឿងញៀនណាស់"។

"ខ្ញុំបានធ្វើការងារនៅក្នុងការដ្ឋានសំណង់មួយកន្លែង ហើយកម្មករទាំងអស់ផ្សេងទៀតបានប្រាប់ខ្ញុំថា វាជាការងាយស្រួលខ្លាំងណាស់ប្រសិនបើខ្ញុំលេប យ៉ាម៉ាជារៀងរាល់ថ្ងៃ។ វាធ្វើឲ្យយើងងាយស្រួលក្នុងការធ្វើកិច្ចការធ្ងន់ៗ។ ដំបូងខ្ញុំមានអារម្មណ៍ថា ខ្លាំងប៉ុន្តែក្រោយមកទៀត ខ្ញុំចាប់ផ្តើមមានអារម្មណ៍ឈឺក្បាលបែកញើស និងញាក់ញ័រគ្រប់ពេលវេលា។

"ខ្ញុំត្រូវបានគេលក់ទៅឲ្យផ្ទះបនមួយកន្លែងកាលពីខ្ញុំមានអាយុបាន ១៥ឆ្នាំ។ ខ្ញុំក្រៀមក្រំរាល់ថ្ងៃ ហើយខ្ញុំចង់តែស្លាប់។ ម្ចាស់ផ្ទះបនផ្តល់ថ្នាំគ្រាប់មួយគ្រាប់ដែលគេបង្ខំខ្ញុំឲ្យលេប។ នៅពេលដែលខ្ញុំលេបថ្នាំនោះ ខ្ញុំមានអារម្មណ៍ថាខ្ញុំដូចជាមិននៅក្នុងខ្លួនខ្ញុំទេ ហើយខ្ញុំមិនខ្វល់ថា រស់ឬស្លាប់ឡើយ។ ក្រោយមកខ្ញុំត្រូវបានគេជួយសង្គ្រោះពីផ្ទះបននោះ ខ្ញុំចាប់ផ្តើមមានការឈឺចាប់ក្នុងរាងកាយរបស់ខ្ញុំ ពីព្រោះខ្ញុំបានញៀនថ្នាំបាត់ទៅហើយ។"

បន្ទាប់មក ពន្យល់ថា យើងបានពិភាក្សារួចហើយថា តើអ្វីទៅជាគ្រឿងញៀន ហើយតើវាធ្វើឲ្យមនុស្សមានអារម្មណ៍បែបណារួចហើយ។ យើងក៏បានពិភាក្សាអំពីការបំផ្លាញដែលវាបង្កឡើង របៀបដែលអ្នកអាចត្រូវបានញៀន ការឈឺចាប់ ឬការហ៊ានប្រថុយគ្រោះថ្នាក់នៅពេលដែលអ្នកសេពគ្រឿងញៀននេះ។ យើងក៏បានពិភាក្សាផងដែរ អំពីរបៀបដែលគ្រឿងញៀនអាចបង្កើនភាពងាយរងគ្រោះ របស់អ្នកទៅនឹងការជួញដូរមនុស្ស។

ដូច្នេះហេតុអ្វីបានជាមនុស្សសេពគ្រឿងញៀនទាំងនេះ?

ឲ្យអ្នកចូលរួមផ្តល់ហេតុផលផ្ទាល់ខ្លួនរបស់គេ។ បន្ទាប់មក ប្រសិនបើ ឧទាហរណ៍ខាងក្រោម មិនទាន់ ត្រូវបានលើកឡើងទេនោះចូរបន្ថែម ៖

- ពួកគេត្រូវបានបង្ខំដោយថៅកែ។
- ដោយសារមិត្តភក្តិរបស់គេសេព។
- ដោយសារវាធ្វើឲ្យពួកគេមានអារម្មណ៍ថា ធំជាងមុន។
- ដោយសារពួកគាត់ជួបប្រទះនឹងអារម្មណ៍លំបាក ហើយគ្រឿងញៀនអាចធ្វើឲ្យពួកគេ បំភ្លេចអារម្មណ៍ទាំងនោះបានមួយរយៈពេលខ្លី បើទោះបីជាក្នុងរយៈពេលវែង វាធ្វើឲ្យមាន អារម្មណ៍កាន់តែអាក្រក់ទៅក៏ដោយ។

បន្ទាប់មក ពន្យល់ថា ចុងក្រោយមានតែអ្នកទេដែលអាចធ្វើការសម្រេចចិត្តអំពីថា តើអ្នកនឹងត្រូវសេពគ្រឿងញៀន ឬយ៉ាងណា។ អ្នកដឹងច្បាស់ថា វាធ្វើទុក្ខទោសដល់អ្នក និងអនាគតរបស់អ្នក។ ប៉ុន្តែអ្នកត្រូវតែរឹងមាំគ្រប់គ្រាន់ក្នុងការនិយាយថាទេដោយខ្លួនឯង។ ដើរជុំវិញរង្វង់ និងឲ្យសិស្សម្នាក់ៗគិតពីមធ្យោបាយក្នុងការនិយាយថា ទេចំពោះអ្នកដែលផ្តល់គ្រឿងញៀនឲ្យទៅពួកគេ។

សួរទៅក្រុមថា តើមធ្យោបាយមួយណាដែលគេគិតថា មានការជំរុញខ្លាំងបំផុតក្នុងការនិយាយថាទេ។

## កំណត់ហេតុ

ឲ្យអ្នកចូលរួមចំណាយពេល ខ្លះដើម្បីកត់ត្រាទុកក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួន។ ឲ្យពួកគេសរសេរ អំពីជំនឿ និងមតិយោបល់ផ្ទាល់ខ្លួនរបស់គេអំពីគ្រឿងញៀន។

**សង្ខេបមេរៀន**

- គ្រឿងញៀនធ្វើឲ្យអ្នកមានអារម្មណ៍ មើល និងគិតខុសពីធម្មតា។
- នៅពេលដែលមនុស្សញៀនថ្នាំ រាងកាយ និងអារម្មណ៍របស់គេស្រេកឃ្លានគ្រឿងញៀន នៅពេលណាដែលគេមិនមានវា។
- សេពគ្រឿងញៀន អាចបង្កើនហានិភ័យរបស់អ្នកជំពោះការជួញដូរមនុស្ស ដោយការជំរុញ ឲ្យអ្នកហ៊ានប្រថុយ និងដោយការធ្វើឲ្យការគិតរបស់អ្នកមិនច្បាស់លាស់។
- និយោជក និងអ្នកជួញដូរ អាចនឹងព្យាយាមបង្ខំនិយោជិត សេពគ្រឿងញៀនដើម្បីធ្វើឲ្យគេងាយស្រួល ក្នុងការបោកបញ្ឆោត។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយមក។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។ ប្រាប់សិស្សឲ្យឆ្លើយសំណួរខាងក្រោម ៖

• តើអ្នកអាចកំណត់ពេលវេលាបានទេថា តើពេលណាដែលអ្នកធ្វើរឿងអ្វីមួយដោយសារតែអ្នកមានអារម្មណ៍ថា រងសម្ពាធពីមិត្តរបស់អ្នក?

អ្នកសម្របសម្រួលអាចឲ្យអ្នកចូលរួមសរសេរសំណួរនេះនៅក្នុងក្រដាសយកទៅផ្ទះដើម្បីរំឭកដល់ពួកគេ។









## គ្រឿងស្រវឹង

**គ្រឿងស្រវឹង** គឺជាសារធាតុអសកម្ម ដែលគេលេបចូលក្នុងលក្ខណៈជាភេសជ្ជៈ។ អ្នកប្រើប្រាស់ គ្រឿង ប្រភេទនេះជាញឹកញាប់ជួបប្រទះនឹងការឆ្លើយតបយឺតៗហើយនិយាយមិនច្បាស់លាស់។ អ្នកដែលស្រវឹងគឺហាក់បីដូចជាហ៊ានប្រថុយ ដូចជាការរួមភេទដោយមិនមានការការពារខ្លួន ឬទៅតាមអ្នកមិនស្គាល់ច្បាស់ទៅកន្លែងផ្សេងទៀត។

## កូកាអ៊ីន

**កូកាអ៊ីន ( ជា Coke, Crack, Blow or Snow)** ឡឺ ជាសារធាតុរំញោចម្យ៉ាង ដែលមានទម្រង់ជា ម្សៅ។ អ្នក ប្រើប្រាស់ថ្នាំនេះ ទទួលបានថាមពល ពុះកញ្ជ្រោលឡើង មានចំណង់ខ្លាំងក្នុងការប្រថុយប្រថាន និង មិនឃ្លាន អាហារ ហើយពួកគេកម្រើកខ្លួនជាប់ជានិច្ច។

## ហេរ៉ូអ៊ីន

**ហេរ៉ូអ៊ីន (ប្រភេទ Dope, Smack, Chiba ឬ Chiva)** គឺជាសារធាតុរំញោចដែលអាចជក់បាន ឬចាក់ក៏បាន។ ជាញឹកញាប់ អ្នកប្រើប្រាស់គ្រឿងញៀនជួបប្រទះនឹងការមានអារម្មណ៍រំភើបហួសហេតុ បាត់បង់ សមត្ថភាពសម្រាប់ការគិត ហើយមើលទៅដូចជាគេកំពុងដេកលក់អញ្ចឹងនៅពេលគេមិនដេកផងនោះ។ ក្នុងករណីខ្លះ អ្នកដែលធ្វើការងារនៅក្នុងអណ្តូងរ៉ែ ឬនៅក្នុងផ្ទះបនតាមគេឲ្យដឹងថា ត្រូវបានគេផ្តល់ឲ្យនូវហេរ៉ូអ៊ីនដើម្បីឲ្យគេងាយគ្រប់គ្រង និងមិនសូវរត់ចោលពីការងារ។








## ការហិតញៀន

**ការហិតញៀន (ហ្គាសសប្បាយ Poppers, Snappers ឬជា Whippets)** គឺជាសារធាតុដែលផលិតចំហាយគីមី ដែលអាចស្រូបចូលក្នុង ខ្លួនបាន ដើម្បីជំរុញ ឲ្យមានឥទ្ធិពលផ្លាស់ប្តូរស្មារតី។ វាអាចមាន សារធាតុជាច្រើនប្រភេទ។ ការហិតគឺជាសារធាតុធ្វើឲ្យស្រវឹងដែលគេហិត។ អ្នកប្រើប្រាស់គ្រឿងញៀនប្រភេទនេះជាញឹកញាប់មានអារម្មណ៍វិលមុខ វង្វេងវង្វាន់ និងស្រវឹង។ ករណីខ្លះ ក្មេងដែលត្រូវបានគេបង្ខំឲ្យដើរសុំទានតាមផ្លូវ ដោយសារចំណាងនៃការជួញដូរ តាមការឲ្យដឹងគឺថាមាន ការប្រើប្រាស់ការដើម្បីជួយពួកគេឲ្យមានអារម្មណ៍ជៀសផុតពីការពិត។

## ខេតាមីន

**ខេតាមីន ( ខេ ឬខេពីសេស)** គឺជាសារធាតុធ្វើឲ្យស្រវឹងដែលអាច លេបបានជាគ្រាប់។ អ្នកប្រើប្រាស់ គ្រឿងញៀន ប្រភេទនេះ មាន អារម្មណ៍ងងុយដេក និងស្រវឹង

## កញ្ឆាE

**កញ្ឆា (Pot, Ganja ឬ ស្មៅ )** គឺជាសារធាតុធ្វើឲ្យស្រវឹងដែលអាចជក់ ឬបរិភោគបានជាមើមថ្នាំនៅក្នុង អាហារ។ អ្នកប្រើប្រាស់ គ្រឿងញៀន ប្រភេទនេះ ជាញឹកញាប់មានអារម្មណ៍ថា ងងុយដេក ឬវង្វេងវង្វាន់។







## MDMA

MDMA (អេស្តាស៊ី មេខ ឬ X) គឺគេលេបដូចជាថ្នាំគ្រាប់។ អ្នកប្រើប្រាស់ថ្នាំនេះ ជាញឹកញាប់ប្រទះនឹងការឆ្លើយតបនៃរាងកាយមាន ការកើនឡើង និងបង្កើនចំណង់ក្នុងការធ្វើចលនា។

## មេតំហ្វេតាមីន

មេតំហ្វេតាមីន (យ៉ាបា យ៉ាម៉ា ឬ ទឹកកក) គឺគេលេបជាគ្រាប់ ឬ ជក់។ អ្នកប្រើប្រាស់ថ្នាំនេះ ជាញឹកញាប់ជួបនឹងការកើនកម្លាំងខ្លាំង និងមានចំណង់ខ្លាំងក្នុងការប្រថុយប្រថាន ហើយគេកម្រើកខ្លួនជាប់ជាប្រចាំ។ មានករណីខ្លះ អ្នកដែលធ្វើការងារនៅក្នុងការដ្ឋានសំណង់ និងនៅក្នុងទូកនេសាទ តាមការឲ្យដឹងគឺថា ថៅកែបានផ្តល់ យ៉ាម៉ា/យ៉ាបា/ទឹកកក ដើម្បីឲ្យគេខំធ្វើការកាន់តែខ្លាំង។

## រ៉ូអ៊ីពណុល (Roofie ឬ ថ្នាំក្រមី)

អាចលេបបាន ជាគ្រាប់ ជាប្រភេទម្សៅ ឬលាយជាមួយសារធាតុរាវ។ អ្នកប្រើប្រាស់ថ្នាំនេះ អាចនឹងនិយាយមិនច្បាស់ ពិបាកដើរ និងការគិតមិនច្បាស់លាស់ ឬ អាច សន្លប់។ ករណីខ្លះ មនុស្សត្រូវបានគេបោកប្រាស់ឲ្យ សេពថ្នាំរ៉ូអ៊ីពណុលនេះ ពេលវាត្រូវបានគេលាយ ជាមួយ នឹងភេសជ្ជៈ។ អ្នកប្រើថ្នាំនេះអាចនឹង មិនដឹងពីអ្វីដែល ខ្លួនធ្វើឡើយ ហើយមិនមានការឆ្លើយតបទេ។ ថ្នាំរ៉ូអ៊ីពណុលនេះ ត្រូវបានគេប្រើ បង្ខក់ មនុស្ស ហើយបន្ទាប់ មករំលោភ គេនៅពេលដែលគេមិនដឹងពីសកម្មភាព របស់ខ្លួន។ មានករណីខ្លះថ្នាំនេះ ត្រូវបានគេប្រើ នៅក្នុងផ្ទះបន។




ថ្នាំÊSteroids

ថ្នាំ Steroids គឺជាឱសថស្របច្បាប់ដែលអាចប្រើប្រាស់ខុសច្បាប់បាន។ អ្នកប្រើប្រាស់ថ្នាំនេះ ទទួលរងនូវការកើនថាមពលខ្លាំងក្លា ប្រសិនបើប្រើ រយៈពេលវែង ថ្នាំ Steroid នេះ នឹងបង្កឲ្យអ្នកប្រើ ឡើងទម្ងន់ម៉ាស់សាច់ដុំ។ ក្នុងករណីមួយចំនួន គេបានឲ្យដឹងថា នៅតាមផ្ទះបនបានបង្ខំឲ្យស្ត្រីបម្រើផ្លូវភេទ ប្រើថ្នាំនេះ មើលទៅឃើញដូចជាសុខភាពល្អសម្រាប់អតិថិជន។

## រឿងទី ១

ខ ធ្វើការជាអ្នករត់តុនៅក្នុងភោជនីយដ្ឋានមួយ។ ប្រុសៗដែលមកភោជនីយដ្ឋាននោះត្រូវការស្រ្តីបម្រើសេវាផ្លូវភេទ ប៉ុន្តែ ខ គឺគ្រាន់តែជាអ្នករត់តុម្នាក់ប៉ុណ្ណោះ។ នៅពេលអតិថិជនសុំឲ្យឲ្យនាងអង្គុយជិត និងផឹកជាមួយគេ ខ ក៏យល់ព្រម។
ចូបញ្ចប់រឿងនេះ ដោយរៀបរាប់អំពីរបៀបដែលគ្រឿងស្រវឹងបង្កើនហានិភ័យរបស់ ខ ចំពោះការដែលត្រូវបានគេជួញដូរ។

## រឿងទី ២

ស ធ្វើការងារនៅក្នុងការដ្ឋានសំណង់មួយកន្លែង។ ថៅកែបានឲ្យថ្នាំ មេតំហ្វេតាមីន ទៅកម្មករដើម្បីឲ្យគេធ្វើការកាន់តែខ្លាំង និងបានច្រើនម៉ោង។ នៅពេល ស ឈប់ពីការងារនោះ គាត់បានក្លាយអ្នកញៀនថ្នាំបាត់ទៅហើយ។ ចូរបញ្ចប់រឿងនេះ ដោយរៀបរាប់ពីរបៀបនៃការញៀនថ្នាំបង្កើនហានិភ័យរបស់ ស ចំពោះការដែលត្រូវបានគេជួញដូរ។

## រឿងទី ៣

ល ធ្វើការក្នុងរោងចក្រមួយកន្លែង។ រាល់ពេលចុងសប្តាហ៍ គេតែងតែចេញក្រៅជាមួយនឹងមិត្តភក្តិរបស់គេ។ យប់មួយ មានបុរសម្នាក់ដែល ល មិនធ្លាប់ជួបពីមុនសោះ បានឲ្យថ្នាំគ្រាប់មួយទៅឲ្យគាត់ ហើយប្រាប់ថា វានឹងធ្វើឲ្យពួកគេមានអារម្មណ៍អស្ចារ្យបំផុត។ ល មិនដឹងថាថ្នាំនោះជាថ្នាំអ្វីទេ។ ដោយសារមិត្តរបស់ ល បានសេពថ្នាំនោះ ល ក៏មានសម្ពាធ ដោយបង្ខំសេពនឹងគេដែរ។ ចូរបញ្ចប់រឿងនេះ ដោយរៀបរាប់ពីរបៀបដែលថ្នាំនេះបង្កើនហានិភ័យដល់ ល ចំពោះការដែលត្រូវបានគេជួញដូរ។

## រឿងទី ៤

ក គឺជាជនចំណាកស្រុកម្នាក់ដែលធ្វើការងារនៅក្នុងរោងចក្រមួយនៅទីក្រុង។ នាងមានមិត្តប្រុសម្នាក់ដែលនាងបានស្គាល់បានរយៈពេល ១ ខែ។ ជាធម្មតា មិត្តប្រុសរបស់នាងមើលទៅហាក់បីដូចជាមានប្រាក់ច្រើន។ នាងក៏លង់ស្រលាញ់គេ។ ល្ងាចមួយ មិត្តប្រុសរបស់ ក បានឲ្យថ្នាំមួយគ្រាប់ឲ្យ ក លេប។ ក មិនប្រាកដថា គួរលេប ឬយ៉ាងណានោះទេ ប៉ុន្តែមិត្តប្រុសនាងប្រាប់ថា បើនាងលេបវា វានឹងបទពិសោធន៍មួយដែលធ្វើឲ្យសេចក្តីស្នេហាពួកគេកាន់តែរឹងមាំ ។ ចូរបញ្ចប់រឿងនេះ ដោយរៀបរាប់ពីរបៀបដែលថ្នាំនេះបង្កើនហានិភ័យរបស់ ល ចំពោះការដែលត្រូវបានគេជួញដូរ។

“ខ្ញុំបានធ្វើការនៅលើទូកបង្គារមួយ។ យើងចេញទូកទៅសមុទ្រម្ដងៗ មានរយៈពេលរាប់ខែ។ ម្ចាស់ទូកឲ្យថ្នាំមួយគ្រាប់មកយើងលេបរាល់ព្រឹក។ ថ្នាំនោះធ្វើឲ្យយើងមានអារម្មណ៍ថាមានកំលាំងហើយយើងខំប្រឹងធ្វើការងារខ្លាំងណាស់ ប៉ុន្តែព្រឹកបន្ទាប់យើងទាំងអស់គ្នាឈឺក្បាលខ្លាំងមែនទែន”។ (ថ្នាំនោះគឺ យ៉ាម៉ា)។

“ខ្ញុំធ្លាប់ធ្វើការងារនៅក្នុងអណ្ដូងរ៉ែមួយកន្លែង។ ការងារនោះពិតជាលំបាកខ្លាំងណាស់ ដោយយើងត្រូវចំណាយពេលពេញមួយថ្ងៃនៅក្រោមដី។ ដូច្នេះបុរសជាច្រើននាក់ធ្វើការនៅទីនោះញៀនហេរ៉ូអ៊ីន។ ថៅកែៗចូលចិត្តវា ហើយពេលខ្លះគេផ្ដល់វាឲ្យពួកយើងពីព្រោះ វាជាវិធីមួយដែលធ្វើឲ្យយើង មិនចង់ចាកចេញពីកន្លែងធ្វើការនេះ ដោយសារយើងបានញៀនថ្នាំនោះរួចទៅហើយ។ ជាមួយគ្នានេះដែរ គឺយើងមានការនឿយហត់នឹងការត្អូញត្អែរដោយសារតែគ្រឿងញៀនណាស់”។

“ខ្ញុំបានធ្វើការងារនៅក្នុងការដ្ឋានសំណង់មួយកន្លែង ហើយកម្មករទាំងអស់ផ្សេងទៀតបានប្រាប់ខ្ញុំថា វាជាការងាយស្រួលខ្លាំងណាស់ប្រសិនបើខ្ញុំលេប យ៉ាម៉ាជារៀងរាល់ថ្ងៃ។ វាធ្វើឲ្យយើងងាយស្រួលក្នុងការធ្វើកិច្ចការធ្ងន់ៗ។ ដំបូងខ្ញុំមានអារម្មណ៍ថា ខ្លាំងប៉ុន្តែក្រោយមកទៀតខ្ញុំចាប់ផ្ដើមមានអារម្មណ៍ឈឺ បែកញើស និងញាក់ញ័រគ្រប់ពេលវេលា។

“ខ្ញុំត្រូវបានគេលក់ទៅឲ្យផ្ទះបនមួយកន្លែងកាលពីខ្ញុំមានអាយុបាន ១៥ ឆ្នាំ។ ខ្ញុំក្រៀមក្រំរាល់ថ្ងៃហើយខ្ញុំចង់តែស្លាប់។ ម្ចាស់ផ្ទះបនផ្ដល់ថ្នាំគ្រាប់មួយគ្រាប់ដែលគេបង្ខំខ្ញុំឲ្យលេប។ នៅពេលដែលខ្ញុំលេបថ្នាំនោះ ខ្ញុំមានអារម្មណ៍ដូចជាមិននៅក្នុងខ្លួនខ្ញុំទេ ហើយខ្ញុំមិនខ្វល់ថា រស់ឬស្លាប់ឡើយ។ ក្រោយមកខ្ញុំត្រូវបានគេជួយសង្គ្រោះពីផ្ទះបននោះ ខ្ញុំចាប់ផ្ដើមមានការឈឺចាប់ក្នុងរាងកាយរបស់ខ្ញុំ ពីព្រោះខ្ញុំបានញៀនថ្នាំបាត់ទៅហើយ។”

# ៧ មេរៀនទី ៧ ៖ ការជួញដូរ និងកេងប្រវ័ញ្ចកំលាំងពលកម្មកុមារ

## ចំណុចបំណង
អ្នកចូលរួម នឹងអាចរៀបរាប់បានអំពីពលកម្មកុមារ និងពិភាក្សាអំពីរបៀបដែលវាប៉ះពាល់ដល់ជីវិតរបស់កុមារក្នុងមូលដ្ឋាន។ អ្នកចូលរួម នឹងអាចរៀបរាប់បានអំពីភាពខុសគ្នារវាងពលកម្មកុមារ និងការជួញដូរកុមារ។

## ពេលវេលា
៧៥ នាទី

**សម្ភារៈ**
- ពលកម្មកុមារ ៖ រូបភាព (គ្រប់គ្រាន់សម្រាប់ឲ្យអ្នកចូលរួមម្នាក់អាចមើលរូបភាពមួយជាមួយដៃគូម្នាក់)
- ក្រដាសផ្ទាំងធំ
- កូនសៀវភៅនាវិកឆ្លាត

ម៉ោងសិក្សាក្រោយ ពិភាក្សាអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងមនុស្សពេញវ័យ។ ប្រសិនបើអ្នកដឹងថា មានសមាជិកក្រុមណាធ្លាប់ត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទឬរំលោភនោះ អ្នកគួរលៃរកពេលណាមួយ ក្នុងម៉ោងសិក្សានេះ ដើម្បីប្រាប់គេឲ្យដឹងអំពីអ្វីដែល អ្នកនឹងគ្រោងសម្រាប់ម៉ោងក្រោយ។ អ្នកអាចពន្យល់ថា មិនចាំបាច់រៀនម៉ោងក្រោយនេះទេ ប្រសិនបើគេមិនចង់។

## សេចក្តីផ្តើម
**ការស្វាគមន៍**

ស្វាគមន៍ដោយហៅឈ្មោះ។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសយកល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើនរណាម្នាក់អាចរៀបរាប់បានដែរ ឬទេអំពីវិធីដែលអ្នកជួញដូរមនុស្សប្រើប្រាស់គ្រឿងញៀនដើម្បីគ្រប់គ្រងមនុស្ស?

### ពលកម្មកុមារ
សួរថា តើមាននរណាម្នាក់ចងចាំពីធាតុទាំងបីនៃការជួញដូរមនុស្សដែរ ឬទេ។ ឲ្យអ្នកចូលរួមទៅមើល ក្នុងកូនសៀវភៅនាវិកឆ្លាតរបស់គេ។ បន្ទាប់មក ឲ្យអ្នកចូលរួមណា ម្នាក់រៀបរាប់ថា តើនិយមន័យនៃការជួញដូរមនុស្សខុសគ្នាសម្រាប់មនុស្សធំ និងកុមារយ៉ាង ដូចម្តេចខ្លះ។
ពន្យល់ថា ប្រសិនបើកុមារត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្ម ផ្លូវភេទ ឬសរីរាង្គនៃរាងកាយនោះគេចាត់ទុកថា ជាការជួញដូរ។
ចំពោះយុវជន ចាត់ទុកថា ត្រូវបានគេជួញដូរ គឺគេមិនចាំបាច់បញ្ជាក់ថាគេត្រូវ បានគៀបសង្កត់បង្ខិតបង្ខំ ឬត្រូតត្រាឡើយ។ វាជាការគ្រប់គ្រាន់ហើយ ចំពោះការបង្ហាញថា មានសកម្មភាព

ប្រព្រឹត្ត ដោយជនណាម្នាក់ដែលជាចុងក្រោយធ្វើឲ្យកុមារធ្លាក់ក្នុងស្ថានភាពកេងប្រវ័ញ្ច។
ប្រាប់អ្នកចូលរួមថា នៅក្នុងសហគមន៍របស់យើង យុវជនតែងតែធ្វើការងារ។ វាជារឿងសាមញ្ញបំផុតចំពោះការដែលយុវវ័យធ្វើការងារតិចតួចដើម្បីជួយដល់គ្រួសាររបស់គេ។ នេះគឺជារឿងល្អ។ ពន្យល់ប្រាប់ថា វាក៏ជារឿងសាមញ្ញដែរដែលយុវវ័យត្រូវបានគេជួលឲ្យធ្វើការងារសម្រាប់អ្នកដទៃ។ នេះគឺគេហៅថា ពលកម្មកុមារ ។ ពលកម្មកុមារ អាចមានផលអាក្រក់សម្រាប់យុវជនជាពិសេសនៅពេលដែល ៖

- ធ្វើទុក្ខទោសដល់រាងកាយ ឬចិត្តរបស់យុវជន
- ហាមឃាត់យុវជនមិនឲ្យមានមិត្តភក្តិ
- ហាមឃាត់យុវជនមិនឲ្យទៅរៀន
- ហាមឃាត់យុវជនមិនឲ្យមានលទ្ធភាពធ្វើកិច្ចការផ្ទះពីសាលា
- សញ្ញាដែល ធ្វើឲ្យពួកគេនឿយហត់ខ្លាំងពេកដែលមិនអាចទៅសាលាថ្ងៃបន្ទាប់បាន
- ធ្វើទុក្ខទោសដល់អនាគតរបស់ពួកគេ។

ប៉ុន្តែទោះជាយ៉ាងណា ចំពោះការពិតដែលពលកម្មកុមារអាចផ្តល់ទុក្ខទោសដល់អនាគត របស់យុវជននោះ មិនមានន័យទាំងអស់ថា ពលកម្មកុមារសុទ្ធតែជាការជួញដូរមនុស្សនោះទេ។ (ពិភាក្សានៅពេលក្រោយ)

## សកម្មភាព

បែងចែកអ្នកចូលរួមជាក្រុមមានគ្នាពីរនាក់។ ឲ្យក្រុមនីមួយៗនូវរូបភាពមួយសន្លឹកពី “ IS ៧ក ៖ រូបភាពស្តីពីពលកម្មកុមារ” ។

ឲ្យគេសរសេរបរិយាយនៅខាងក្រោមរូបនីមួយៗអំពីថា តើពួកគេគិតថា កុមារនៅក្នុងរូប នោះមានអារម្មណ៍ មើលឃើញ ស្តាប់ឮ និងដឹងក្លិនយ៉ាងដូចម្តេច។ ឲ្យអ្នកចូលរួមបង្ហាញគ្នាអំពីរូបភាព និងអំពីថា តើគេបានពិពណ៌នាអំពីអារម្មណ៍កុមារយ៉ាងដូចម្តេច។

## ការរៀបចំក្រុម

នៅពេលពួកគេចប់សព្វគ្រប់ ឲ្យក្រុមនិយាយឲ្យឮៗអំពីឈ្មោះប្រភេទការងារដែលកុមារធ្វើនៅក្នុងសហគមន៍នេះ។ សរសេរឧទាហរណ៍ទាំងអស់នៅក្នុងក្រដាសផ្ទាំងធំ។ ទុកកន្លែងធំល្មមដើម្បី អ្នកអាចគូរតារាងបន្ថែមមួយទៀតនៅលើផ្នែកខាងឆ្វេងនៃក្រដាសផ្ទាំងធំនោះ ដូចក្នុងរូប “IS ៧ខ៖ តារាងឧទាហរណ៍អំពីពលកម្មកុមារ”។

ពេលនេះ គូរតារាងមានកាឡេន ៤។ សម្គាល់កាឡេននីមួយៗ។ ឲ្យអ្នកចូលរួមមើលឧទាហរណ៍នីមួយៗគ្រប់ទាំងអស់ ហើយគូសសញ្ញា ធីក នៅក្នុងកាឡេននៃការងារនីមួយៗដែលត្រូវទៅនឹងការពិពណ៌នា។

- ការងារដែលធ្វើទុក្ខទោសដល់រាងកាយរបស់កុមារ
- ការងារដែលធ្វើទុក្ខទោសដល់ផ្លូវចិត្តរបស់កុមារ
- ការងារដែលធ្វើទុក្ខទោសដល់ការអប់រំរបស់កុមារ
- ការងារដែលធ្វើទុក្ខទោសដល់អនាគតរបស់កុមារ

## ភាពខុសគ្នារវាងពលកម្មកុមារ និងការជួញដូរកុមារ

ប្រាប់អ្នកចូលរួមថា ពលកម្មកុមារអាចធ្វើទុក្ខទោសដល់កុមារ ប៉ុន្តែវាមិនមែនមានន័យថា គ្រប់ពលកម្ម កុមារទាំងអស់គឺជាទម្រង់មួយនៃការជួញដូរមនុស្សទេ។ ពលកម្មកុមារគឺជាការជួញដូរកុមារ តែក្នុងករណីដែលកុមារ ត្រូវបានគេកេងប្រវ័ញ្ចយកកម្លាំងពលកម្ម / ទាសភាពដោយបង្ខំសកម្មភាព ពេស្យាកម្ម / ផ្លូវភេទ / សកម្មភាពពាក់ព័ន្ធផ្លូវភេទ / រូបភាព / វីដេអូអាសអាភាស ការកែណ្ឌ ចូលសមរភូមិយោធា ការលក់ដូរគ្រឿងញៀន ការបង្ខំឲ្យសុំទាន ឬការកាត់ផ្នែកនៃសរីរាង្គកាយ។

ឧទាហរណ៍ ស្ថានភាពខាងក្រោមនេះ បរិយាយអំពីការជួញដូរមនុស្ស ៖

- កុមារដែលជាទាសករ
- កុមារដែលធ្វើការនៅក្នុងផ្ទះបនដែលលក់សេវាផ្លូវភេទ
- កុមារដែលធ្វើជាអ្នកបម្រើតាមផ្ទះដោយមិនទទួលបានប្រាក់កម្រៃ

ការងារខាងក្រោមនេះ គឺជាឧទាហរណ៍នៃពលកម្មកុមារ ប៉ុន្តែមិនមែនជាការជួញដូរទេ ៖

- កុមារដែលធ្វើការនៅក្នុងហាងលក់ទំនិញ អាចចាកចេញបានគ្រប់ពេល និងបានប្រាក់ខែ។
- កុមារដែលប្រមូលផលស្រូវ ទទួលបានប្រាក់កម្រៃ និងស្នាក់នៅផ្ទះ

## មនុស្សពេញវ័យ និងការជួញដូរសម្រាប់ការកេងប្រវ័ញ្ចពលកម្ម

ប្រាប់អ្នកចូលរួមថា កុមារអាចត្រូវបានគេជួញដូរសម្រាប់ពលកម្ម។ ក៏ប៉ុន្តែការជួញដូរក៏អាចកើតមានចំពោះមនុស្សធំផងដែរ។ នៅក្នុងអំឡុងនៃការប្រជុំក្លិបនេះ ដែលបានពិភាក្សាគ្នារួចហើយអំពីបទពិសោធន៍នានាដែលកុមារត្រូវបានគេជួញដូរទៅធ្វើការងារដែលមានគ្រោះថ្នាក់។ សួរថាតើមានអ្នកណា ដែលអាចឲ្យឧទាហរណ៍ អំពីប្រភេទការងារដែលមនុស្សធំ អាចត្រូវបានគេជួញដូរវិញម្តង។

សរសេរឧទាហរណ៍របស់ពួកគេនៅលើក្រដាសផ្ទាំងធំ ហើយបន្ទាប់មកបន្ថែមឧទាហរណ៍ខាងក្រោមប្រសិនបើពួកគេមិនទាន់បាននិយាយ ៖

- ការងារដែលអ្នកធ្វើការមិនទទួលបានកម្រៃជាទៀងរាល់ខែ
- ការងារដែលអ្នកធ្វើការត្រូវបានហាមឃាត់មិនឲ្យចាកចេញពីកន្លែងធ្វើការ។ (ឧទាហរណ៍ អ្នកបម្រើតាមផ្ទះ ដែលគេចាក់សោរទុកក្នុងផ្ទះ ឬអ្នកនេសាទដែលគេមិនឲ្យចាកចេញពីទូក)។
- ការងារដែលអ្នកធ្វើការត្រូវបានគេប្រាប់ថា បានជំពាក់ប្រាក់ថៅកែ ហើយមិនអាចចាកចេញបាន។ (ឧទាហរណ៍ បុគ្គលដែលគេបញ្ជូនទៅធ្វើការនៅក្នុងកសិដ្ឋាន ហើយគេប្រាប់គាត់ថា គាត់បានជំពាក់ប្រាក់ម្ចាស់កសិដ្ឋាន សម្រាប់ការស្នាក់នៅ ការហូបចុក ដើម្បីរស់នៅក្នុងកសិដ្ឋាន និងសាហ៊ុយធ្វើដំណើរ ហើយគាត់ត្រូវតែធ្វើការច្រើនឆ្នាំដើម្បីសងបំណុលនេះ)។
- ការងារដែលអ្នកធ្វើការត្រូវបានគេរំលោភបំពានផ្លូវភេទ។ (ឧទាហរណ៍ អ្នកបម្រើតាមផ្ទះដែល គេបង្ខំឲ្យរួមភេទជាមួយម្ចាស់ផ្ទះ ហើយមិនអាចគេចខ្លួនរួច)។
- ការងារដែលអ្នកធ្វើការត្រូវបានគេគំរាមកំហែងថា នឹងត្រូវជាប់ពន្ធនាគារប្រសិនបើគេចាកចេញ។ (ឧទាហរណ៍ កម្មកររោងចក្រ ដែលគេបានប្រាប់ថា ប្រសិនបើគាត់ព្យាយាមរត់ចេញនោះ ថៅកែនឹងទូរស័ព្ទហៅប៉ូលីស ហើយគេនឹងចាប់ខ្លួនគាត់)។

ប្រាប់អ្នកចូលរួមថា ជាញឹកញាប់កុមារ និងមនុស្សធំមិនបានដឹងច្បាស់ទេថា ការងារទាំងនេះ មិនត្រឹមតែជា "ការងារមិនល្អ" ប៉ុណ្ណោះទេ ៖ ឧទាហរណ៍ទាំងនេះ គឺជាឧទាហរណ៍ ជាក់ស្តែង នៃការជួញដូរមនុស្ស និងការងារខុសច្បាប់។ នៅមេរៀនក្រោយៗនឹងមានព័ត៌មានបន្ថែមអំពី ច្បាប់ និងការជួញដូរមនុស្ស។

**សង្ខេបមេរៀន**

- ពលកម្មកុមារធ្វើទុកទោសដល់យុវជននៅពេលដែលគេធ្វើ ៖
  - ការងារដែលធ្វើទុក្ខទោសដល់រាងកាយរបស់គេ
  - ការងារដែលធ្វើទុក្ខទោសដល់ការអប់រំរបស់គេ
  - ការងារដែលធ្វើទុក្ខទោសដល់អនាគតរបស់គេ
- ការជួញដូរកុមារមានន័យថា កុមារត្រូវបានគេកេងប្រវ័ញ្ច សម្រាប់យកកម្លាំងពលកម្ម ផ្លូវភេទ ផ្នែកនៃសរីរាង្គកាយ។ ចំពោះកុមារដែលត្រូវចាត់ទុកថាត្រូវបានគេជួញដូរមិនចាំបាច់ បង្ហាញថាគេត្រូវបានបង្ខិតបង្ខំ ឬត្រូតត្រានោះទេ។
- មនុស្សធំក៏ត្រូវបានគេជួញដូរដើម្បីយកកម្លាំងពលកម្មផងដែរ។ ពួកគេត្រូវបានជួញដូរ ឲ្យធ្វើការងារដែល ៖
  - គេមិនទទួលបានកម្រៃ
  - គេត្រូវបានរំលោភបំពានផ្លូវភេទ
  - គេមិនអាចចាកចេញបាន
  - គេត្រូវបានគំរាមកំហែងដោយកម្លាំងប្រសិនបើគេចាកចេញ
  - គេត្រូវបានគំរាមកំហែងដោយការចាប់ខ្លួនប្រសិនបើគេចាកចេញ
  - គេជំពាក់ប្រាក់ថៅកែ ដូច្នេះហើយគេមិនអនុញ្ញាតិឲ្យចាកចេញទេ។

## ភារកិច្ចទីបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់គេទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។ ប្រាប់អ្នកចូលរួម ឲ្យតាមមើលប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់គេ ហើយឆ្លើយសំណួរខាងក្រោម ៖

- តើការងារប្រភេទណាដែលកុមារធ្វើនៅក្នុងសហគមន៍របស់អ្នក?
- តើការងារទាំងនោះផ្តល់ទុក្ខទោសដល់កុមារដែរ ឬទេ? បើមាន តើដោយរបៀបណា?

អ្នកសម្របសម្រួល អាចប្រាប់អ្នកចូលរួម ឲ្យសរសេរសំណួរទាំងនេះនៅលើក្រដាស និងយកទៅផ្ទះ ដើម្បីរំឭកដល់ពួកគេ។



១. កុមារធ្វើការនៅក្នុងឡឥដ្ឋ



ខ. កុមារធ្វើជាទាហាន



៣. កុមារធ្វើការនៅក្នុងស្រែ ជាការងារប្រមូលផលស្រូវ



៩. កុមារធ្វើការជូតកម្រាលឥដ្ឋបន្ទប់ទឹក



៥ កុមារធ្វើការនៅក្នុងរោងចក្រកាត់ដេរ

| រាងកាយ | ស្មារតី | ការអប់រំ | អនាគត | |
|---|---|---|---|---|
| ✓ | ✓ | ✓ | ✓ | ភោជនីយដ្ឋាន |
| | | | | |
| ✓ | ✓ | ✓ | ✓ | ឡឥដ្ឋ |
| | | | | |
| ✓ | ✓ | ✓ | ✓ | លក់ផ្កាតាមផ្លូវ |
| | | | | |
| ✓ | ✓ | ✓ | ✓ | ស្រីបោយដៃ |
| | | | | |
| ✓ | ✓ | ✓ | ✓ | ការងារកសិកម្ម |
| | | | | |
| ✓ | ✓ | ✓ | ✓ | ការងារកិនថ្ម |
| | | | | |

# ៨ មេរៀនទី ៨ ៖ ការជួញដូរ សម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ

## ទស្សនៈចំណាន

អ្នកចូលរួម នឹងអាចអភិវឌ្ឍចំណេះដឹងអំពីអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSEC) និងអាចអភិវឌ្ឍការយល់អារម្មណ៍របស់ជនរងគ្រោះ។

## ពេលវេលា

៧៥ នាទី

### សម្ភារៈ

- ថតចម្លង "IS ៨ក ៖ ករណីសិក្សាអំពី CSEC" ៤-៥ ច្បាប់ (មួយច្បាប់ សម្រាប់មួយក្រុមដែលមានគ្នាពី ៤-៥ នាក់ )
- "IS ៨ខ ៖ នរណាជាអ្នកទទួលខុសត្រូវ?" ចំនួន ១ ច្បាប់ សម្រាប់ជាឯកសារយោងរបស់អ្នកសម្របសម្រួលប៉ុណ្ណោះ។ (អ្នកមិនចាំបាច់ថតចម្លងច្រើនច្បាប់ទេ)។

## ការរៀបចំ

ក្នុងសហគមន៍ខ្លះ (ដូចជាសាលាបង្រៀនជាភាសាចិន) យុវជន ប្រហែលជាមិនដឹងទេថាអ្វីទៅជាការរួមភេទទេ។ ប្រសិនបើក្នុងសហគមន៍របស់អ្នកមានករណីបែបនេះ ចូរកត់សម្គាល់រក អង្គការ NGO ណាដែលធ្វើការងារផ្នែកសុខភាពបន្តពូជ ឬការងារប្រឆាំង មេរោគអេដស៍។

សាកសួរថា តើគេអាចផ្តល់នូវគ្រូឧទ្ទេសដែលមានបទពិសោធន៍ដើម្បីដឹកនាំមេរៀនមួយដែលពន្យល់អំពីថា តើអ្វីជាការរួមភេទក្នុងលក្ខណៈមួយសមរម្យ ស្និទ្ធស្នាលជាមួយកុមារ។ ត្រូវប្រាកដថាអ្នកបានសុំការអនុញ្ញាតិពីឪពុកម្តាយរបស់កុមារហើយមុនពេលនឹងបង្រៀនមេរៀននេះ។

ត្រូវជម្រាបដល់ឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំដល់កុមារផងដែរ មុនពេលចាប់ផ្តើមក្លិបយុវជននេះថា ប្រធានបទនៃមេរៀននេះគឺអំពីអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (SCEC)។ ប្រសិនបើអ្នកបានដឹងថា មានអ្នកចូលរួមណាដែលធ្លាប់ត្រូវបានគេរំលោភបំពានផ្លូវភេទ ឬត្រូវបានគេរំលោភសេពសន្ថវៈនោះ ត្រូវប្រាប់ដល់គេអំពីប្រធានបទសម្រាប់សប្តាហ៍នេះ ឲ្យបានមុនមួយសប្តាហ៍ នៅក្នុងទីកន្លែងស្ងាត់មួយ។ អ្នកចូលរួមនឹងអាចជ្រើសរើសថា គួរចូលរួម ឬមិនចូលបាន។ មុនពេលចាប់ផ្តើមមេរៀននេះ ត្រូវបានរំឭកដល់អ្នកចូលរួមថា ការពិភាក្សានៅក្នុងមេរៀនថ្ងៃនេះ នឹងរួមមានប្រធានបទរសើបៗមួយចំនួន។ ដោយសារតែនិយាយអំពីប្រធានបទនេះ ដូច្នេះការចេញលេងជាទៀងទាត់គឺត្រូវបានលើកទឹកចិត្ត។ ឲ្យអ្នកចូលរួម ចេញពីថ្នាក់ដោយស្ងាត់ស្ងៀម ប្រសិនបើគេមានអារម្មណ៍មិនស្ងួរស្រួលក្នុងការចូលរៀន ពេញមួយម៉ោងនោះ។

ប្រសិនបើមាន អ្នកចូលរួមណាម្នាក់ ស្តែងចេញនូវអារម្មណ៍ក្រៀមក្រំ ក្នុងអំឡុងពេលកំពុងសិក្សានោះ គឺមិនត្រូវទាញចំណាប់អារម្មណ៍ពីគេម្នាក់នោះឡើយ ហើយ មិនត្រូវ សួនាំ គេ ដោយបើក ចំហដែរ។ រង់ចាំរហូតទាល់តែអ្នកចូលរួមផ្សេងបានចាកចេញអស់ បន្ទាប់ មកចូលទៅសួរនាំគេថា តើគេចង់និយាយអ្វីដែរ ឬទេ។

អានឡើងវិញនូវអត្ថបទ "ការឆ្លើយតបទៅនឹងភាពតានតឹងរបស់យុវជន" នៅក្នុងមេរៀនទី ៩ នៃសៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលអំពីការចង្អុលបង្ហាញដ៏ឆ្លាតវៃ។

## សេចក្ដីផ្ដើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតគ្នានូវក្រដាសចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្ដើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើប្រភេទការងារអ្វីខ្លះដែលកុមារធ្វើនៅក្នុងសហគមន៍របស់យើង?

តើប្រភេទការងារនេះផ្ដល់ទុក្ខទោសដល់កុមារដែរ ឬទេ? បើមានតើយ៉ាងដូចម្ដេច?

## ការពិភាក្សា

ពន្យល់ថា មេរៀនថ្ងៃនេះគឺជាប្រធានបទដែលពិបាកពិភាក្សាគ្នាណាស់។ នៅពេលដែលអ្នកចូលរួមជជែកគ្នាអំពីប្រធានបទនេះ គេអាចនឹងមានអារម្មណ៍ក្រៀមក្រំ។ ពន្យល់ទៅអ្នកចូលរួមថា គេអាចនៅស្ងៀមបាន ឬអាចចាកចេញពីរៀននេះបានប្រសិនបើវាពិបាកខ្លាំងពេក។ ប្រសិនបើគេមានអារម្មណ៍ក្រៀមក្រំ ហើយចង់ជជែកពីបញ្ហានេះនៅពេលក្រោយ អ្នកសម្របសម្រួលគួរតែលៃពេលដើម្បីជជែកជាមួយគេបន្ទាប់ពីចប់ម៉ោងសិក្សា។

ពន្យល់ថា លទ្ធផលដែលត្រូវបានគេជួញដូរ មនុស្សអាចនឹងត្រូវទល់ច្រកដោយការធ្វើការងារដ៏អាក្រក់។ ការជួញដូរកម្លាំងពលកម្មត្រូវបានលើកយកមកពិភាក្សាគ្នា នៅពេលដែលបុគ្គលម្នាក់ត្រូវបានគេជួញដូរយកទៅធ្វើការងារដោយប្រើកម្លាំងពលកម្ម (ឧទាហរណ៍ ការធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ នៅលើទូកនេសាទបង្គារ ឬធ្វើជាអ្នកបម្រើតាមផ្ទះ)។ ប៉ុន្តែមនុស្សក៏អាចត្រូវបានគេជួញដូរដើម្បីលក់សេវាផ្លូវភេទផងដែរ។

**ការប្រកបអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSEC)**

ពន្យល់ថា CSEC (ការប្រកបអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ) បរិយាយអំពីស្ថានភាពមួយដែលមនុស្សម្នាក់ (ជាញឹកញាប់ជាមនុស្សពេញវ័យ ប៉ុន្តែពេលខ្លះក៏មានកុមារផងដែរ) រំលោភបំពានផ្លូវភេទទៅលើកុមារ និងចំណាយប្រាក់សម្រាប់សកម្មភាពនេះ។

ពន្យល់ថា មនុស្សធំអាចចំណាយជាប្រាក់ ឬក្នុងមធ្យោបាយផ្សេង ដូចជាអាហារ ឬជាគុណស្រ័យ។ ភាគច្រើន កុមារមិនទទួលបានកម្រៃនោះទេ ៖ មនុស្សធំជាអ្នកទទួលប្រាក់ជំនួសវិញ ដូចជាម្ចាស់ផ្ទះបន ឬសាច់ញាតិរបស់គេ។

ពន្យល់ថា CSEC អាចកើតមានទៅលើទាំងក្មេងប្រុស និងក្មេងស្រី

ប្រាប់អ្នកចូលរួមថា ប្រទេសផ្សេងៗពីគ្នាតែងមាននិយមន័យខុសៗគ្នាអំពី តើអ្វីជាអត្ថន័យនៃកុមារ ប៉ុន្តែនៅក្នុង SNYC "កុមារ" គឺសំដៅចំពោះមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំប៉ុណ្ណោះ។

ពន្យល់ថា បើទោះបីជាមានភាពខុសគ្នានៃ CSEC ក៏មានប្រភេទដែលសំខាន់គឺ ៖

- នៅពេលដែលកុមារគឺជាស្រីពេស្យា (រួមទាំងទេសចរណ៍ផ្លូវភេទផងដែរ)
- នៅពេលដែលកុមារចូលរួមក្នុងរូបភាព/វីដេអូអាសអាភាស។

ពន្យល់ពាក្យថា ពេស្យាចារ្យ មានន័យថា ការទទួលប្រាក់ជាថ្នូរនឹងការរួមភេទជាមួយអ្នកដទៃ។

នៅពេលដែលកុមារត្រូវបានបង្ខំឲ្យធ្វើជា ស្រីពេស្យា មនុស្សធំដែលត្រួតត្រាលើពួកគេ តែងតែទទួលប្រាក់ជំនួសកុមារ។

ពន្យល់ ពាក្យថា ភាពយន្ត/រូបភាពអាសអាភាស គឺបរិយាយអំពីសាច់រឿង រូបភាព និងភាពយន្តពីការរួមភេទ។ ពេលខ្លះមនុស្សមើលភាពយន្តអាសអាភាសតាមអិនធឺណិត ឬតាមទូរស័ព្ទដៃ។ កុមារអាចនឹងត្រូវបានចូលរួមមើលភាពយន្តអាសអាភាស ដែលបង្ហាញពីសកម្មភាពរួមភេទច្បាស់ៗ។

ប្រាប់អ្នកចូលរួមថា នៅពេលដែលកុមារក្លាយជាជនរងគ្រោះនៃ CSEC មនុស្សធំដែលត្រួតត្រាលើពួកគេ តែងតែបំបែកពួកគេចេញពីគ្នាជាញឹកញាប់។ ការធ្វើបែបនេះ អាចរួមមាន ការគំរាមកំហែងការវាយដំ ការបង្អត់អាហារ ឬការឲ្យថ្នាំញៀនដល់កុមារ ដូច្នេះពួកគេនឹងធ្វើអ្វីដែលមនុស្សធំនិយាយ និងបង្ខំឲ្យញញឹមដាក់អតិថិជន។

ពន្យល់ថា CSEC គឺជាទម្រង់មួយនៃការជួញដូរ ពីព្រោះថា កុមារត្រូវបានគេកេងប្រវ័ញ្ចដោយគិតកម្រៃ។

## ករណីសិក្សា

បែងចែកអ្នកចូលរួមជាក្រុមតូចៗដែលមានគ្នាពី ៤-៥ នាក់។ ផ្តល់ឲ្យក្រុមនូវ ក្រដាស "IS ៨ក៖ ករណីសិក្សាអំពី CSEC" និងសុំឲ្យអ្នកចូលរួមឆ្លើយសំណួរជាក្រុម។

## ការណែនាំអំពីផ្ទះបន

ពន្យល់ថា នេះគឺជាប្រធានបទពិបាកមួយផ្សេងទៀត។ ផ្ទះបនគឺជាទីកន្លែងដែលបុរសទៅ ដើម្បីរួមភេទ ហើយចំណាយលុយ។ (ផ្លូវភេទពេលខ្លះក៏មានលក់នៅតាមផ្លូវ ក្នុងភោជនីយដ្ឋាន បារខារ៉ាអូខេនឹងនៅផ្ទះផងដែរ) ។ ជាញឹកញាប់ ផ្ទះបនត្រូវបានគេឃើញមានច្បាស់នៅក្នុងសហគមន៍ ហើយសមាជិកសហគមន៍ដឹងច្បាស់ថា វានៅកន្លែងណា និងមានអ្វីកើតឡើងនៅក្នុងនោះ។ ករណីខ្លះវាមានការលាក់បាំងច្រើនណាស់ ប៉ុន្តែអ្នកដែលចង់ចំណាយដើម្បីរួមភេទនៅតែអាចរកឃើញ។

ស្ត្រី និងកុមារអាចត្រូវបានគេជួញដូរយកចូលទៅក្នុងផ្ទះបនហើយត្រូវបានបង្ខំឲ្យរួមភេទជាមួយភ្ញៀវ។

ប្រាប់អ្នកចូលរួមថា ផ្ទះបនជាញឹកញាប់តែងតែមានចំណែកក្នុងការជួញដូរមនុស្ស។ នៅពេលបុរស ម្នាក់ទៅលេងផ្ទះបន ពួកគេអាចមានឱកាសរួមភេទជាមួយស្ត្រីពេស្យាដែលជាកុមារ ត្រូវបានគេជួញដូរ។ តាមការប៉ាន់ប្រមាណបានឲ្យដឹងថា ចំនួនពី ១០-៣៥ ភាគរយនៃស្ត្រីបម្រើសេវាផ្លូវភេទនៅក្នុងអនុតំបន់ទន្លេមេគង្គ (កម្ពុជា វៀតណាម និងថៃ) មានអាយុចន្លោះពី ១២-១៧ ឆ្នាំ។ ចំនួននេះអាចដូចគ្នានឹងប្រទេសមីយ៉ាន់ម៉ា ចិន និងប្រទេសឡាវផងដែរ ប៉ុន្តែការស្ទង់មតិមិនបានរាប់ប្រទេសទាំងនោះទេ។

ពន្យល់ថា បើទោះបីជាស្ត្រីដែលប្រុសៗរួមភេទជាមួយមិនមែនជាកុមារក៏ដោយ ក៏អាចមានករណីដែលនាងត្រូវបានគេជួញដូរយកទៅផ្ទះបននោះ ហើយមិនអាចចាកចេញបានដែរ។

បើទោះបីជាស្ត្រីបម្រើសេវា ផ្លូវភេទធ្វើការនៅក្នុងផ្ទះបន ដោយការជ្រើសរើសរបស់ខ្លួនក៏ដោយ ក៏ជីវិតរបស់ពួកនាងអាចប្រឈមមុខខ្ពស់ទៅនឹងការទទួលរងការរំលោភបំពានទៅលើរាងកាយ និងផ្លូវចិត្តក៏ដោយ។

## តើនរណាជាអ្នកទទួលខុសត្រូវ?

អានរឿងក្នុងក្រដាស "IS ៨ខ ៖ តើនរណាជាអ្នកទទួលខុសត្រូវ?"។ បន្ទាប់មក អ្នកនឹងឃើញថា អ្នកចូលរួមមានភាពស្ងៀមស្ងាត់ និងស្រពាប់ស្រពោន។ នេះគឺជាការឆ្លើយតបធម្មតា។ ពិភាក្សាសំណួរ ដែលមាននៅចុងបញ្ចប់នៃរឿង។

## ការស្តីបន្ទោស

សួរថា តើមាននរណាធ្លាប់បានឮគេបកស្រាយអំពីស្ត្រីពេស្យាបែបនេះដែរឬទេ ៖
"នាងគឺជាកូនស្រីដ៏ល្អ ប៉ុន្តែគឺជាស្ត្រីដ៏អាក្រក់"។

ពន្យល់ថា នៅពេលដែលនិយាយបែបនេះគឺគេកំពុងស្តីបន្ទោសដល់ក្មេងស្រីដែលទៅធ្វើការជាស្ត្រីពេស្យាដើម្បីជួយដល់គ្រួសាររបស់គេ។

ពន្យល់ថា នេះគឺជារបួសទីពីរ។ ទីមួយ បុគ្គលគឺជាជនរងគ្រោះនៃការជួញដូរសម្រាប់គោលបំណងបម្រើសេវាផ្លូវភេទ ហើយបន្ទាប់មក សហគមន៍បង្ករបួសដល់នាងមួយជាន់ទៀតតាមរយៈការរើសអើងប្រឆាំងនឹងរូបនាង។ ប្រាប់អ្នកចូលរួមថា នៅពេលដែលនរណាម្នាក់ត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ជាការសំខាន់សម្រាប់យើងគឺត្រូវដឹងថា ពួកគេបានរងទុក្ខទោសយ៉ាងខ្លាំង ដែលវាមិនមែនជាកំហុសរបស់គេនោះទេ ហើយគេត្រូវការជំនួយ និងការទទួល។

ប្រាប់អ្នកចូលរួមថា ជនរងគ្រោះនៃអំពើជួញដូរមិនគួររងការស្តីបន្ទោសចំពោះបទពិសោធន៍របស់គេឡើយ។ ជនរងគ្រោះពីអំពើជួញដូរទាំងអស់ស័ក្តិសមនឹងត្រូវបានទទួលការត្រឡប់ចូលទៅក្នុងសហគមន៍ដើមរបស់ខ្លួនវិញ។

## កំណត់ហេតុ

ឲ្យក្រុមសរសេរ ឬគូររូបបង្ហាញថា តើគេមានអារម្មណ៍បែបណាបន្ទាប់ពីបានស្តាប់ព័ត៌មាននេះ។

### សង្ខេបមេរៀន

- CSEC (ការកេងប្រវ័ញ្ចផ្លូវភេទបែបពាណិជ្ជកម្មលើកុមារ) បរិយាយអំពីស្ថានភាពមួយដែលមនុស្សម្នាក់ (ជាញឹកញាប់ជា មនុស្សពេញវ័យ ប៉ុន្តែពេលខ្លះក៏មានកុមារផងដែរ) រំលោភបំពានផ្លូវភេទទៅលើកុមារ និងចំណាយប្រាក់សម្រាប់សកម្មភាពនេះ។
- ផ្ទះបនជាញឹកញាប់តែងតែមានចំណែកការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ។
- ជនរងគ្រោះពីការជួញដូរមនុស្សមិនគួររងការស្តីបន្ទាសឡើយ។
- ជនរងគ្រោះពីអំពើជួញដូរទាំងអស់ ស័ក្តិសមនឹង ត្រូវបាន ទទួលត្រឡប់ចូល ទៅក្នុងសហគមន៍ ដើម របស់ខ្លួនវិញ

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមសទាំងអស់គ្នាដែលបានចូលរួម។បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀនសិក្សានេះ។ ពន្យល់ថា ការនិយាយអំពី CSEC និងផ្ទះបនអាចធ្វើឲ្យមានការមិនសប្បាយចិត្ត ហើយអ្នកនឹងត្រូវនៅឈរចាំនៅក្នុងបន្ទប់រយៈពេល ១០ នាទីបន្ទាប់ពីចប់ម៉ោងសិក្សាក្រែងមាននរណាម្នាក់ចង់និយាយជាមួយ។

ករណីសិក្សាផ្អែកលើរឿងពិតមួយ

### រឿងទី ១

រ រស់នៅក្នុងភូមិជិតទីក្រុងទេសចរណ៍មួយ។ គេមានអាយុ ១០ ឆ្នាំ។ គេមានបងប្អូនប្រុស ស្រីជាច្រើននាក់ ហើយឪពុករបស់គេបានចាកចេញរយៈពេលជាច្រើនឆ្នាំឯកន្លងទៅហើយ។ មានអ្នកជិតខាង ម្នាក់បានមកជួយយកគេទៅទីក្រុងទេសចរណ៍នោះ អ្នកជិតខាងរបស់គេបានប្រាប់ថា អាចដើរសុំទានពីភ្ញៀវទេសចរណ៍ដែលជាអ្នកមានបាន។

នៅពេលដែល រ ទៅដល់ អ្នកជិតខាងនោះបានសម្តែងភាពឃោឃៅមកលើរូបគេ។ រ ដេកតាមឆ្នេរខ្សាច់ ហើយដើរសុំទានគេពេលថ្ងៃ ប៉ុន្តែប្រសិនបើគេមិនអាចសុំប្រាក់បានគ្រប់ចំនួនទេនោះ អ្នកជិតខាងម្នាក់នោះនឹងវាយគេនៅពេលយប់។

ពេលខ្លះភ្ញៀវទេសចរណ៍ឲ្យប្រាក់ទៅ រ ជាថ្នូរនឹងការរួមភេទជាមួយគេ។ រ មិនចង់ធ្វើបែបនេះទេ ប៉ុន្តែគេមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ហូបចុក និងសម្រាប់បង់ទៅឲ្យអ្នកជិតខាងម្នាក់នោះ ដូច្នេះពេលខ្លះគេក៏យល់ព្រមតាម។

ថ្ងៃមួយ រ បានជួបជាមួយនឹងមនុស្សម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាល ដែលបានដឹង អំពីបញ្ហារបស់គេ។ អង្គការ មិនមែនរដ្ឋាភិបាលមួយនោះបានជួយនាំ រ ចាកចេញពីទីក្រុងនោះ ត្រឡប់ទៅភូមិកំណើតរបស់គេវិញ ហើយបានទាក់ទងរកប៉ូលីសដើម្បីរាយការណ៍ប្រាប់អំពីអ្នកជិតខាងម្នាក់នោះ។ រ បាន ត្រឡប់ទៅរស់នៅក្នុងភូមិជាមួយនឹងឯគ្រួសាររបស់គេវិញ ហើយអង្គការមិនមែនរដ្ឋាភិបាលនោះ បានបន្តគាំទ្រដល់ពួកគេ។

- តើអ្វីដែលធ្វើឲ្យ រ មានភាពងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ច ?
- តើនណាជាអ្នកជួញដូរ រ?
- តើការជួយប្រភេទអ្វីដែលអ្នកភូមិអាចផ្តល់ឲ្យដើម្បីជួយស្តារជីវិតគេខ្លួនវិញ?

### រឿងទី ២

ស ជាក្មេងស្រីមានអាយុ ១៥ ឆ្នាំម្នាក់ មកពីក្រុមជនជាតិភាគតិច។ នាងមិនដែល បានទៅសាលា រៀនទេ។ ថ្ងៃមួយ នាងបានពីស្រែវិញឃើញថា ឪពុករបស់នាងធ្លាក់ខ្លួនឈឺ។ គ្រួសាររបស់នាងបាននាំគាត់ទៅមន្ទីរពេទ្យដើម្បីព្យាបាល ប៉ុន្តែត្រូវខ្ចីប្រាក់ពីអ្នកចង់ការប្រាក់ក្នុងស្រុកម្នាក់ដើម្បីបង់ឲ្យគ្រូពេទ្យ។ ឪពុករបស់នាងត្រូវចំណាយពេលវេលាច្រើនដើម្បីជាសះស្បើយវិញ ហើយគាត់មិនអាចធ្វើការងារបានទេ។ ម្ចាស់បំណុលចាប់ផ្តើមទៅដល់ផ្ទះដើម្បីទារប្រាក់របស់ខ្លួន ហើយគ្រួសានាងមិនមានប្រាក់ដើម្បីសងទេ។

ថ្ងៃមួយម្ចាស់បំណុលនោះបានឲ្យយោបល់ថា ពួកគេអាចឲ្យ ស ទៅគេជាថ្នូរនឹងប្រាក់ដែលជំពាក់។ គ្រួសាររបស់នាងបានយល់ព្រមតាម ហើយ ស ត្រូវបានគេនាំយកទៅផ្ទះបនដើម្បីធ្វើការ។ ស ត្រូវបានគេបង្ខំ ឲ្យធ្វើការនៅក្នុងផ្ទះបនអស់រយៈពេល ២ ឆ្នាំ។ នាងទទួលភ្ញៀវច្រើននាក់ក្នុងមួយថ្ងៃៗ ហើយមិនដែលទទួលបានប្រាក់ ឡើយ។ នាងខូចចិត្តខ្លាំងណាស់ដល់ថ្នាក់លែងចង់រស់។

ពីរឆ្នាំក្រោយមក ផ្ទះបននោះត្រូវបានឆែកឆេរដោយប៉ូលីស ហើយ ស បានត្រឡប់ទៅគ្រួសាររបស់នាងវិញ។

- តើអ្វីដែលធ្វើឲ្យ ស មានភាពងាយរងគ្រោះទៅនឹងការជួញដូរ?
- តើនរណាជាអ្នកជួញដូរ ស?
- តើការជួញដូរនេះជាកំហុសរបស់ ស មែនទេ?
- តើការជួយបែបណាដែល ស ត្រូវការដើម្បីស្តារជីវិតរបស់នាងឡើងវិញ?

សម្រាប់ជាឯកសារយោងរបស់អ្នកសម្របសម្រួលប៉ុណ្ណោះ សូមកុំចែកឲ្យអ្នកចូលរួម

មានផ្ទះបនមួយនៅកណ្តាលទីក្រុង។ អ្នកគ្រប់គ្នានៅក្នុងសហគមន៍ដឹងច្បាស់ថា មានអ្វីកើតឡើង នៅក្នុងផ្ទះបននោះ។ ប្រជាពលរដ្ឋអាចមើលឃើញនារីក្មេងៗឈរនៅក្រោមពន្លឺភ្លើងពេលគេ បើកបរកាត់ពេលយប់ ហើយពេលខ្លះស្រីៗទាំងនោះមើលទៅឃើញក្មេងខ្លាំង។ ប្រជាពលរដ្ឋមកពីទីក្រុងអាចមើលឃើញមានបុរសខ្លះមកពីសហគមន៍ដែលស្រវឹងនៅជាមួយនឹងស្រីៗទាំងនេះ។ អ្នកគ្រប់គ្នាអាចទាយដឹងថា មានអ្វីកើតឡើងនៅពេលដែលបុរសៗបានបាត់ខ្លួនចូលទៅក្នុងបន្ទប់នៅជាន់ខាងលើ។ មានពាក្យចចាមអារាមនៅក្នុងទីក្រុងអំពីផ្ទះបននេះ។ គេនិយាយថាពេលខ្លះផ្ទះបននេះអនុញ្ញាតិឲ្យគ្រួសារក្រីក្រអាចសងបំណុលរបស់ខ្លួនដោយការបញ្ជូនកូនស្រីរបស់គេមកផ្ទះបននេះ។ អ្នកផ្សេងទៀតនិយាយថា ក្មេងស្រីជាច្រើនមានអាយុក្រោម ១៨ ឆ្នាំ។ គេថែមទាំងនិយាយទៀតថា អ្នករួមរ័ក្សជាមួយនឹងស្រ្តីព្រហ្មចារីបានផងដែរ ប្រសិនបើអ្នកមានប្រាក់គ្រប់។ ល្ងាចមួយម្ចាស់តូបនៅផ្លូវកែងនេះបានឃើញក្មេងស្រីមកថ្មីម្នាក់ដែលមើលទៅមានអាយុ ប្រហែលជា ១៦ ឆ្នាំ អង្គុយនឹងតុ។ ក្មេងស្រីនោះមើលទៅមានការភ័យខ្លាច និងក្រៀមគ្រំ។ អ្នកចាក់ស្រាបៀរនៅយប់នោះឃើញក្មេងស្រីនោះ ហើយនាំគ្នាមានការបារម្ភអំពីនាង ពីព្រោះនាង មើលទៅនៅក្មេងណាស់។ បុរសចំណាស់គួរគោរពម្នាក់នៅក្នុងសហគមន៍បានគិតថា វាជាការអាម៉ាស់ ដែលរឿងបែបនេះកើតមាននៅក្នុងទីក្រុងនេះ ប៉ុន្តែគាត់គិតខ្លួនឯងថាតើខ្ញុំអាចធ្វើអ្វីកើត?នេះគឺជារឿងធម្មតានៅក្នុងភូមិនេះទៅហើយ។ យប់នោះសិស្សសាលាមួយក្រុមបានមក ផ្ទះបននោះ។ ពួកគេមានអារម្មណ៍អាក់អន់ចិត្តពេលឃើញក្មេងស្រីនោះ ប៉ុន្តែពួកគេសំលឹងមើល តែស្រីដែលចាស់ជាងនាងជំនួសវិញ។ យប់នោះមានមនុស្សម្នាក់ឲ្យប្រាក់ទៅម្ចាស់ផ្ទះបនជាថ្នូរនឹងព្រហ្មចារីរបស់ក្មេងស្រីនោះ។ គេបាននាំនាងទៅក្នុងបន្ទប់ ប៉ុន្តែនាងមានភាពភ័យខ្លាចហើយបានប្រតប់ប្រតាយគ្នា។ពេលកំពុងព្យាយាមគ្រប់គ្រងលើនាងបុរសនោះបានច្រាននាងទៅខ្ទប់នឹងជញ្ជាំង។ ក្មេងស្រីនោះបានស្លាប់បាត់បង់ជីវិតនៅក្នុងយប់នោះ។ ប៉ូលីសបាន មកកាន់ដល់កន្លែងកើតហេតុ ហើយបានរកឃើញថា ក្មេងស្រីនោះមានអាយុទើបតែ ១៥ ឆ្នាំ និងត្រូវបានជួញដូរដោយគ្រួសារក្រីក្ររបស់នាង។ មនុស្សគ្រប់គ្នានៅក្នុងទីក្រុងនិយាយអំពីបញ្ហានេះ។

សម្តីរបស់ម្តាយនាង

“វាមិនមែនជាកំហុសរបស់ខ្ញុំទេ” ។ “យើងត្រូវការសងបំណុលគ្រួសារយើង”។

សម្តីរបស់ម្ចាស់តូប “វាមិនមែនជាកំហុសរបស់ខ្ញុំទេ”។ “វាមិនមែនជារឿងរបស់ខ្ញុំទេ”។

សម្តីរបស់អ្នកចាក់ស្រាបៀរ “វាមិនមែនជាកំហុសរបស់ខ្ញុំទេ”។ “យើងមិនអាចធ្វើអ្វីបានទាំងអស់”

សម្ដីរបស់បុរសចំណាស់គួរគោរព "វាមិនមែនជាកំហុសរបស់ខ្ញុំទេ"។ "ខ្ញុំគ្មានអំណាចគ្រប់គ្រាន់ដើម្បីបញ្ឈប់គេបានទេ"

សម្ដីរបស់ក្រុមសិស្ស "វាមិនមែនជាកំហុសរបស់ខ្ញុំទេ"។"យើងមិនបានរួមភេទជាមួយនាងទ"។

សម្ដីរបស់ម្ចាស់ផ្ទះបន "វាមិនមែនជាកំហុសរបស់ខ្ញុំទេ"។ "ខ្ញុំមិនគិតថា គាត់ដល់ថ្នាក់សម្លាប់នាងនោះទេ"។

ប៉ុន្តែនៅក្នុងយប់នោះ គ្មាននរណាម្នាក់ដេកលក់ស្រួលនោះទេ។ គេដេកនៅលើគ្រែ ហើយស្រមៃថា គេកំពុងត្រូវបានសម្លឹងមើលដោយព្រលឹងក្មេងស្រីដែលបានស្លាប់នោះ។ ខ្យល់បក់ខ្លាំង ហើយពួកគេយល់សប្តិថា គេបានឮសំឡេងរបស់នាងតាមខ្យល់ ដោយនិយាយថា

"អ្នកបានឃើញខ្ញុំហើយ ហេតុអ្វីបានជាអ្នកមិនជួយខ្ញុំផង?"

លុះព្រឹកឡើងអ្នកទាំងនោះក្រោកពីដំណេកជាមួយនឹងអារម្មណ៍ក្ដុកក្ដួលខ្លាំង។ពួកគេស្ទាបបេះដូងខ្លួនឯង ហើយមានអារម្មណ៍ថា មានពារុទ្ធ។

ការគិតរបស់ម្ដាយក្មេងស្រី "វាគឺជាកំហុសរបស់ខ្ញុំ"។ "ខ្ញុំមិនគួរលក់នាងដើម្បីដោះបំណុលរបស់ខ្ញុំនោះទេ"។

ការគិតរបស់ម្ចាស់តូបលក់ឥវ៉ាន់ "វាគឺជាកំហុសរបស់ខ្ញុំ"។ "ខ្ញុំគួរតែបានហៅទូរស័ព្ទទៅកាន់លេខជំនួយបន្ទាន់"។

ការគិតរបស់បុរសចាក់ស្រាបៀរ "វាគឺជាកំហុសរបស់ខ្ញុំ"។ "យើងគួរតែទាក់ទងទៅកាន់ប៉ូលីស"។

សម្ដីរបស់បុរសចំណាស់គួរគោរព "វាគឺជាកំហុសរបស់ខ្ញុំ"។ "ខ្ញុំគួរតែប្ដឹងពីកន្លែងបីសាចនោះជាច្រើនឆ្នាំមកហើយ"។

ការគិតរបស់ក្រុមសិស្ស "វាគឺជាកំហុសរបស់ខ្ញុំ"។ "យើងដឹងហើយថា ផ្ទះបននោះធ្វើទុក្ខទោសក្មេងស្រីៗយើងមិនគួរទៅទីនោះទេ"។

ការគិតរបស់ម្ចាស់ផ្ទះបន "វាគឺជាកំហុសរបស់ខ្ញុំ"។ "ខ្ញុំមិនគួរត្រូវបានអូសទាញដោយប្រាក់សោះ"។

ការគិតរបស់ប្រជាពលរដ្ឋ ទាំងអស់ក្នុងក្រុងនោះ "វាគឺជាកំហុសរបស់ខ្ញុំ"។ "យើងបានឮពាក្យ ចចាមអារាម អំពីផ្ទះបននោះនៅក្នុងទីក្រុងនេះ ប៉ុន្តែយើងនៅតែទុកឲ្យផ្ទះបននោះបន្តដំណើការក្នុងទីក្រុងរបស់យើង"។

## សំណួរពិភាក្សា

តើអ្នកគិតយ៉ាងដូចម្ដេចអំពីរឿងនេះ?

ប្រសិនបើមាន តើនរណាដែលអ្នកគិតថា ត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ក្មេងស្រីនេះ?

តើអ្នកគិតថា ផ្ទះបននោះមានចំណែកក្នុងការជួញដូរមនុស្សដែរ ឬទេ?

# មេរៀនទី ៩ ÷ កុំចាញ់បោកគេ! ៩

## ទស្សនៈ

អ្នកចូលរួមនឹងដឹងអំពីល្បិចមួយចំនួន ដែលអ្នកជួញដូរប្រើប្រាស់ជាមួយនឹងជនចំណាកស្រុក ដើម្បីឲ្យគេអាចការពារខ្លួនបានពីការដែលត្រូវបានគេជួញដូរ ប្រសិនបើគេឃើញថា ស្ថានភាពមួយប្រហាក់ប្រហែលគ្នាបែបនេះ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ព្រីនក្រដាស 'IS ៩ក៖ ប័ណ្ណហ្គេមអំពីអ្នកជួញដូរមនុស្ស" ចេញជា ដប សំណុំ (ថតចម្លងដើម្បីឲ្យគ្រប់ចំនួនសម្រាប់សមាជិកគ្រប់គ្នា នៃក្រុមដែលត្រូវមានប័ណ្ណនេះទាំងអស់)
- ការដាសផ្ទាំងធំ និងប៊ិច
- ថតចម្លងរឿងនីមួយៗជា ៤-៥ ច្បាប់ (ប័ណ្ណអំពីការធ្វើដំណើរ) ពី ក្រដាស 'IS ៤ក ៖ ប័ណ្ណអំពីការធ្វើដំណើរ" (ប្រើប្រាស់នៅក្នុង មេរៀនទី ៤ នៃឯកសារណែនាំនេះ)
- ស្ទីគ័របិទ
- កូនសៀវភៅនារីកឆ្លាត

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាននរណាអាចឲ្យនិយមន័យនៃពាក្យថា ការជួញដូរមនុស្សដែរ ឬទេ?

(លើកទឹកចិត្ត ឲ្យអ្នកចូលរួមមើលកូនសៀវភៅស្តីពីការវង្កលបង្ហាញដ៏ឆ្លាតវៃប្រសិនបើគេមានការ យល់ច្រឡំ)។

## ការពិភាក្សា

បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី ៤-៥ នាក់។ ចែក ប័ណ្ណអំពីការធ្វើដំណើរមួយសំណើទៅក្រុមនីមួយៗពីពេលចាប់ផ្តើមនៃម៉ោងសិក្សាដូច្នេះគ្រប់ក្រុមមានរឿងចំនួនប្រាំ។

ឲ្យអ្នកចូលរួមអានរឿងទាំងនេះម្តងទៀត និងរៀបរាប់អំពីមធ្យោបាយដែលអ្នកជួញដូរមនុស្សប្រើល្បិចបោកជនចំណាកស្រុក (ឧទាហរណ៍ "ធ្វើពុតជាមិត្តភ័ក្តិ)។ នៅពេលដែលក្រុមបានធ្វើរួចឲ្យចែករំលែកការរៀបរាប់របស់គេជាមួយគ្នា។

សរសេរចម្លើយរបស់គេនៅលើក្រដាសផ្ទាំងធំ។

បន្ថែមឧទាហរណ៍មួយចំនួនខាងក្រោមនេះ ប្រសិនបើពួកគេមិនទាន់បានលើកឡើង ៖

- អ្នកជួញដូរធ្វើពុតជាមិត្តភ័ក្តិ ឬធ្វើជាចង់ជួយ
- អ្នកជួញដូរផ្តល់ការងារដែលទទួលបានប្រាក់ខែខ្ពស់ ជាញឹកញាប់តែងតែខ្ពស់ជាងប្រាក់ខែធម្មតា។
- អ្នកជួញដូរឲ្យជនចំណាកស្រុកចំណាយថ្លៃសុំចូលធ្វើការដំបូង ចំណាយថ្លៃសាហ៊ុយ របស់ជនចំណាកស្រុក ឬឲ្យប្រាក់ជនចំណាកស្រុក ខ្ចីដើម្បីឲ្យប្រាកដថា គេមិនរត់ចោលការងារ។ អ្នក

ជួញដូរធ្វើឲ្យប្រាកដថា ជនចំណាកស្រុកបានជំពាក់ប្រាក់អ្នកជួញដូរ។

- អ្នកជួញដូរដកហូតយកឯកសារអត្តសញ្ញាណរបស់ជនចំណាកស្រុក។
- អ្នកជួញដូរកុហក់ថា នឹងយកជនចំណាកស្រុកទៅកន្លែងធ្វើការងារ។

ពន្យល់ប្រាប់ថា ក៏មានទម្រង់ផ្សេងទៀតនៃរឿងទាំងនេះផងដែរ។ ជនចំណាកស្រុក គឺមិនមាន ការរៀបចំបានល្អទេ។ នៅពេលដែលជនចំណាកស្រុកដឹងថា ខ្លួនមានបញ្ហា គេមិនមានប្រាក់គ្រប់គ្រាន់ ឬមិនដឹងអំពីវិធីធ្វើយ៉ាងណា ដើម្បីអាចត្រឡប់មកផ្ទះវិញបាននោះទេ។ នៅផ្នែកក្រោយទៀតនៃសៀវភៅមគ្គុទេសនេះ និងមានមេរៀនអំពីរបៀបតើត្រូវរៀបចំយ៉ាងដូចម្តេច ដើម្បីធ្វើឲ្យជនចំណាកស្រុកមានសុវត្ថិភាពជាងនេះ ដូច្នេះអ្នកចូលរួមនៃ SNYC នឹងមិនទល់ច្រកនៅក្នុងស្ថានភាពដូចគ្នានេះ។

ប្រាប់ថា ទាំងនេះមិនមែនត្រឹមតែជាវិធីដែលអ្នកជួញដូរបោកប្រាស់ជនចំណាកស្រុកប៉ុណ្ណោះទេ។ ប៉ុន្តែវាជារឿងសាមញ្ញ ហើយប្រសិនបើនរណាម្នាក់ធ្វើទង្វើមួយក្នុងចំណោមទង្វើទាំងនេះ វាអាចជាល្បិចមួយផងដែរ។

## ល្បែងអំពីអ្នកជួញដូរមនុស្ស

បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នា ១០ នាក់។ ឲ្យសមាជិកម្នាក់នៃក្រុមនីមួយៗដើរតួរធ្វើជា "អ្នកជួញដូរ" ហើយឲ្យស្ទីគ័រស្អិតទៅម្នាក់នោះដើម្បីប្រើនៅក្នុងល្បែងនេះ។ ចែកឲ្យក្រុមនីមួយៗនូវប័ណ្ណសម្រាប់លេងល្បែង ("IS ៩ក ៖ ប័ណ្ណសម្រាប់លេងល្បែងអំពីអ្នកជួញដូរមនុស្ស") ហើយសុំឲ្យក្រុមនីមួយៗចែកតៗគ្នាដើម្បីឲ្យគ្រប់គ្នាទទួលបានប័ណ្ណមួយ។

ក្រុមត្រូវលេងដេញបិទស្ទីគ័រដោយ "អ្នកជួញដូរ" ព្យាយាមចាប់យកមនុស្សម្នាក់ក្នុងចំណោមអ្នកចូលរួម។ ប្រសិនបើអ្នកចូលរួមត្រូវគេចាប់បាន អ្នកជួញដូរសួរទៅអ្នកចូលរួមថា

- តើអ្នកអាចគេចរួចទេ?

ប័ណ្ណនីមួយៗមានការរៀបរាប់អំពីហេតុផល ដែលមានអត្ថបទចំណុចមួយចំពោះហេតុផលនីមួយៗ។ អ្នកដែលត្រូវបានគេបិទស្ទីគ័រជាប់ ត្រូវដោះលែងវិញនៅពេលបន្ទាប់។

នៅពេលចំណុចទាំងអស់របស់អ្នកចូលរួមត្រូវបានបិទពីលើដោយស្ទីគ័រទាំងអស់នោះ មានន័យថាអ្នកនោះ ត្រូវបានគេជួញដូរហើយ ហើយត្រឡប់មកកន្លែងអង្គុយវិញ ជាមួយនឹងជនរងគ្រោះផ្សេងទៀត រហូតទាល់តែអ្នកទាំងអស់គ្នាបានបញ្ចប់ល្បែងនេះ។

ខាងក្រោមនេះគឺជាឧទារណ៍នៃប័ណ្ណល្បែងស្តីពីអ្នកជួញដូរដែលគេបានបំពេញរួច។

### ប័ណ្ណល្បែងអំពីអ្នកជួញដូរ ៖ ២

អ្នកគឺជាក្មេងវ័យជំទង់ក្រីក្រម្នាក់ដែលមិនចេះអានអក្សរ ។ អ្នកជួញដូរម្នាក់បានមកជិតអ្នកហើយចង់រកការងារឲ្យអ្នកធ្វើនៅក្នុងការដ្ឋានសំណង់មួយកន្លែងនៅក្នុងប្រទេសថៃ។

- ខ្ញុំគេចចេញពីព្រោះប្រាក់ខែដែលគាត់បានផ្តល់ឲ្យខ្ញុំគឺខ្ពស់ខ្លាំងពេកដែលធ្វើឲ្យខ្ញុំសង្ស័យ
- ខ្ញុំត្រូវគេចាប់ជាប់ ពីព្រោះគាត់បានផ្តល់ប្រាក់ឲ្យគ្រួសាររបស់ខ្ញុំចំនួន ៥០ ដុល្លារ។ បន្ទាប់គាត់ឲ្យខ្ញុំធ្វើការពីរឆ្នាំដោយមិនមានកម្រៃ។ គេកុហក់ ហើយនិយាយថា វាជាច្បាប់ ហើយខ្ញុំមិនអាចអានបាន ដូច្នេះខ្ញុំមិនដឹងត្រូវធ្វើអ្វីនោះទេ។

## ការពិភាក្សា

បន្ទាប់ពីលេងល្បែងរួច អ្នកចូលរួមត្រូវអង្គុយជារង្វង់មួយ។ បន្ទាប់មកសួរសំណួរខាងក្រោម ៖

- តើមានអារម្មណ៍បែបណាដែលបានលេងល្បែងនេះ ?
- តើអ្វីដែលជួយដល់មនុស្សឲ្យគេចខ្លួនបាន? (ចម្លើយរួមមាន ការអប់រំ ការកាន់កាប់ដី ការចេះដឹងអំពីច្បាប់ បដិសេធន៍មិនព្រមប្រគល់ឯកសារឲ្យ បដិសេធន៍មិនចូលក្នុងរថយន្ត។)
- តើអ្វីដែលធ្វើឲ្យមនុស្សមានលទ្ធភាពកាន់តែខ្ពស់ចំពោះការដែលត្រូវគេចាប់? (ចម្លើយរួមមាន៖ មិនចេះអក្សរ ជឿទុកចិត្តជនមិនស្គាល់គ្នា ផ្តល់ឯកសារឲ្យគេ ទទួលយកកម្ចី រង់ចាំការសងត្រឡប់វិញ នៅតែឯង ជាកុមារ ក្រីក្រខ្លាំងពេក)។
- បើទោះបីជាអ្នកមិនធ្លាក់ចូលក្នុងល្បិចរបស់អ្នកជួញដូរក៏ដោយ ប៉ុន្តែអ្នកនៅតែស្ថិតក្នុងស្ថានភាពក្រីក្រដដែល តើនរណាជាអ្នកជួយដល់អ្នក?
- តើអ្នកអាចការពារអ្នកផ្សេងទៀតនៅក្នុងស្ថានភាពបែបនេះបានយ៉ាងដូចម្តេចទៅ?

## ការសម្តែងផ្ទាល់

ឲ្យអ្នកចូលរួមបែងចែកជាក្រុមដែលមានគ្នាពី ៨-១២ នាក់។ ប្រាប់ឲ្យក្រុមនីមួយៗរៀបចំការសម្តែងរឿង។ (ប្រសិនបើអ្នកមានក្រុមលើសពីពីរក្រុម អ្នកអាចប្រើរឿងតែមួយខាងក្រោមនេះបានពីរដង)។

ក្រុមទី ១៖ តួអង្គសំខាន់គឺជាក្មេងស្រីអាយុ ១៥ ឆ្នាំម្នាក់ ដែលកំពុងដាក់ពាក្យសុំចូលធ្វើការមួយ។ ថៅកែរោងចក្រចង់ដកហូតយកឯកសារអត្តសញ្ញាណរបស់នាង។ តើនាងធ្វើដូចម្តេចដើម្បីរួចផុតពីល្បិចនេះ?

ក្រុមទី ២ ៖ តួអង្គសំខាន់គឺជាក្មេងប្រុសម្នាក់ដែលពូរបស់គេបានប្រាប់គេថា គាត់អាចរកការងារឲ្យគេធ្វើដែលទទួលបានប្រាក់ខែខ្ពស់នៅក្រៅប្រទេស។ គ្រួសាររបស់គេមានអារម្មណ៍រំភើបអំពីប្រាក់ខែខ្ពស់។ ក្មេងប្រុសនោះមានការសង្ស័យ។ តើគេអាចបញ្ចុះបញ្ចូលឪពុកម្តាយរបស់គេយ៉ាងដូចម្តេចថា នេះគឺជាល្បិចនោះ?

ឲ្យក្រុមចំណាយពេលប្រាំនាទី ដើម្បីរៀបចំការសម្តែងរឿង។ បន្ទាប់មកសម្តែងរឿងមួយក្រុមម្តងៗ។

### ការសង្ខេបមេរៀន

អ្នកជួញដូរតែងតែប្រើល្បិចទាំងនេះដើម្បីដាក់អន្ទាក់ដល់ជនចំណាកស្រុក៖

- អ្នកជួញដូរធ្វើពុតជាមិត្តភក្តិ ឬធ្វើជាចង់ជួយ
- អ្នកជួញដូរផ្តល់ការងារដែលទទួលបានប្រាក់ខែខ្ពស់
- អ្នកជួញដូរឲ្យជនចំណាកស្រុកចំណាយថ្លៃសុំចូលធ្វើការដំបូង
- អ្នកជួញដូរចំណាយថ្លៃសាហ៊ុយរបស់ជនចំណាកស្រុក
- អ្នកជួញដូរឲ្យប្រាក់ជនចំណាកស្រុកខ្ចី
- អ្នកជួញដូរដកហូតយកឯកសារអត្តសញ្ញាណរបស់ជនចំណាកស្រុក។
- អ្នកជួញដូរកុហកថា នឹងយកជនចំណាកស្រុកទៅរោងចក្រ។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។

ឲ្យអ្នកចូលរួមសួរសំណួរទាំងនេះទៅឪពុកម្តាយរបស់គេ ៖

- តើអ្នកធ្លាប់ឮអំពីករណីជួញដូរដែរ ឬទេ?
- តើល្បិចភាគច្រើនអ្វីខ្លះដែលអ្នកជួញដូរតែងតែប្រើ?

អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមឲ្យសរសេរសំណួរទាំងនោះនៅលើក្រដាស ដើម្បីយកទៅផ្ទះទុកកុំឲ្យភ្លេចសំណួរ។

អ្នកសម្របសម្រួល ៖ ថតចម្លងឯកសារ IS នេះ និងកាត់រឿង និងរូបដែលបានបង់លេខបញ្ចូលទៅក្នុងប័ណ្ណនីមួយៗ។ អ្នកគួរមានប័ណ្ណគ្រប់គ្រាន់ដើម្បីឲ្យសិស្សម្នាក់អាចទទួលបានមួយ។

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ១ ៖

អ្នកគឺជា ប មកពីប្រទេសចិន។ មានឈ្មួញកណ្តាលម្នាក់ចង់ជួយរៀបចំរកការងារមួយឲ្យអ្នកធ្វើការនៅកោះតៃវ៉ាន់។ ឈ្មួញកណ្តាលនោះគឺជាអ្នកជួញដូរមនុស្ស ហើយចង់លក់អ្នកជាកូនក្រមុំវ័យក្មេងម្នាក់។

- ○ ខ្ញុំគេចចេញ ពីព្រោះខ្ញុំបានទៅឃើញគ្រួសារមួយផ្សេងទៀតដែលបានបញ្ជូនកូនរបស់គេតាមបុរសម្នាក់នេះហើយ។ ពួកគេនិយាយថា នាងមិនបានទូរស័ព្ទមករយៈពេលមួយឆ្នាំហើយដូច្នេះខ្ញុំមិនទៅទេ។
- ○ ខ្ញុំគេចចេញ ពីព្រោះនៅពេលដែលបុរសនោះសួររកឯកសារផ្លូវច្បាប់របស់ខ្ញុំ ខ្ញុំបានបដិសេធន៍មិនប្រគល់ឲ្យគាត់ទេ។
- ○ ខ្ញុំត្រូវគេចាប់បាន គឺខ្ញុំយល់ព្រមទៅ ពីព្រោះគ្រួសាររបស់ខ្ញុំទាំងមូលដាក់សម្ពាធឲ្យខ្ញុំត្រូវទទួលយកការផ្តល់ឲ្យនេះ។

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ២ ៖

អ្នកគឺជាក្មេងវ័យជំទង់ក្រីក្រម្នាក់ដែលមិនចេះអានអក្សរ។ អ្នកជួញដូរម្នាក់បានមកជិតអ្នកហើយចង់រកការងារឲ្យអ្នកធ្វើនៅក្នុងការដ្ឋានសំណង់មួយកន្លែងនៅក្នុងប្រទេសថៃ។

- ○ ខ្ញុំគេចចេញពីព្រោះ ប្រាក់ខែដែលគាត់បានផ្តល់ឲ្យខ្ញុំគឺខ្ពស់ខ្លាំងពេកដែលធ្វើឲ្យខ្ញុំសង្ស័យ
- ○ ខ្ញុំត្រូវគេចាប់ជាប់ ពីព្រោះគាត់បានផ្តល់ប្រាក់ឲ្យគ្រួសាររបស់ខ្ញុំចំនួន ៥០ ដុល្លារ។ បន្ទាប់គាត់ឲ្យខ្ញុំធ្វើការពីរឆ្នាំដោយមិនមានកម្រៃ។ គេកុហក់ ហើយនិយាយថាវាជា

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៣៖

អ្នកគឺជាស្ត្រីវ័យក្មេងម្នាក់ដែលរស់នៅក្នុងទីរួមខេត្តមួយ។ អ្នកជួញដូរម្នាក់ចង់ជួយអ្នកឲ្យរកការងារ បានធ្វើនៅក្នុងប្រទេសឥណ្ឌូណេស៊ី

- ○ ខ្ញុំគេចចេញ ពីព្រោះខ្ញុំចេះអានអក្សរ។ ខ្ញុំបានសុំមើលកិច្ចសន្យា ហើយពេលខ្ញុំអានវា ខ្ញុំបានដឹងច្បាស់ថា កិច្ចសន្យានោះចែងថា ខ្ញុំមិនត្រូវបានអនុញ្ញាតិឲ្យចេញក្រៅពីផ្ទះរបស់ម្ចាស់ផ្ទះទេ។ ខ្ញុំបានដឹងច្បាស់ថា ខ្ញុំនឹងជាប់អន្ទាក់។
- ○ ខ្ញុំគេចចេញពីព្រោះពេលខ្ញុំទៅមើលដល់អាស័យដ្ឋានដែលគាត់បានផ្តល់ឲ្យខ្ញុំ សម្រាប់ជាការិយាល័យរបស់ឈ្មួញកណ្តាលនោះ ហើយខ្ញុំក៏បានដឹងច្បាស់ថាមិនមានការិយាល័យអ្វីនោះទេ។ វាធ្វើឲ្យខ្ញុំមានការសង្ស័យ។
- ○ ខ្ញុំត្រូវគេចាប់បាន ពីព្រោះម្តាយខ្ញុំមានជំងឺ ហើយខ្ញុំសម្រេចចិត្តប្រថុយប្រថានដើម្បីគាត់។


CONTRACT
FOR
THAILAND

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៤៖

អ្នកគឺជាក្មេងស្រីម្នាក់ដែលមិនចេះអក្សររស់នៅភាគខាងជើងប្រទេសថៃ។ អ្នកសម្រេចចិត្តមកកាន់ទីក្រុងបាងកកដើម្បីរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ អ្នកបានជួបជាមួយនឹងអ្នកជួញដូរម្នាក់នៅលើរថយន្តក្រុង។

- ◯ ខ្ញុំគេចចេញ ពីព្រោះខ្ញុំបដិសេធមិននិយាយជាមួយនឹងអ្នកមិនស្គាល់លើរថយន្តក្រុង
- ◯ ខ្ញុំត្រូវគេចាប់បានពីព្រោះនៅពេលដែលខ្ញុំទៅដល់ទីក្រុងបាងកក ខ្ញុំវង្វេងផ្លូវ មិនស្គាល់នរណាម្នាក់ ហើយគ្មានប្រាក់ដើម្បីត្រឡប់មកផ្ទះវិញឡើយ។ បុរសនៅលើរថយន្តក្រុងចង់ជួយដល់ខ្ញុំ ហើយខ្ញុំក៏យល់ព្រម

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៥៖

អ្នកគឺជាបុរសក្មេងម្នាក់មកពីភូមិមួយនៃប្រទេសមីយ៉ាន់ម៉ា។អ្នកសម្រេចចិត្តទៅប្រទេសថៃដើម្បីរកការងារធ្វើនៅក្នុងឧស្សាហកម្មនេសាទ។ អ្នកបានជួបជាមួយនឹងអ្នកជួញដូរមនុស្សម្នាក់នៅឯកំពង់ផែដែលគេបាននិយាយថា នឹងជួយដល់អ្នកឲ្យទៅរករោងចក្រមួយ។

- ◯ អ្នកគេចចេញពីព្រោះអ្នកធ្វើដំណើរជាក្រុមជាមួយនឹងមិត្តផ្សេងទៀត ហើយអ្នកបដិសេធន៍ចំពោះការបំបែកពីគ្នា។
- ◯ អ្នកគេចចេញ ពីព្រោះអ្នកបដិសេធមិនចូលទៅក្នុងរថយន្តឯកជនជាមួយគាត់។ ជំនួសមកវិញអ្នកសុំឲ្យគាត់ប្រាប់ពីទិសដៅទៅកាន់រោងចក្រនោះ ដូច្នេះគឺអ្នកអាចមើលឃើញរោងចក្រនោះដោយខ្លួនឯង។
- ◯ អ្នកត្រូវគេចាប់បាន ពីព្រោះអ្នកបានទៅជាមួយគាត់ ហើយត្រូវបានជួញដូរឲ្យទៅធ្វើការនៅលើទូកនេសាទទៅវិញ។

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៦៖

អ្នកមកពីគ្រួសារក្រីក្រម្នាក់។ ឪពុករបស់អ្នកផឹកស្រាច្រើនណាស់ ហើយវាយដំម្តាយរបស់អ្នក។ អ្នកមិនធ្លាប់បានទៅសាលារៀនទេ។ អ្នកជួញដូរមនុស្សម្នាក់ផ្តល់ប្រាក់ឲ្យឪពុករបស់អ្នក ឲ្យលក់អ្នកទៅឲ្យផ្ទះបនមួយកន្លែង។

- ◯ អ្នកមិនអាចគេចផុតទេ ពីព្រោះអ្នកគ្មានប្រាក់ គ្មានអំណាច និងគ្មានការអប់រំ ។




PORT



## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៧៖

អ្នកគឺជា និស្សិតទើបបញ្ចប់សកលវិទ្យាល័យ។ អ្នកជួញដូរមនុស្សម្នាក់បានមកជិតអ្នកចង់ជួយរកការងារមួយឲ្យអ្នកធ្វើនៅក្នុងរោងចក្រមួយនៅប្រទេសម៉ាឡេស៊ី

◯ អ្នកគេចចេញ ពីព្រោះអ្នកបានស្វែងរករោងចក្រនោះតាមបណ្តាញអិនធឺណិត ហើយការពិតរោងចក្រនោះមិនមានទេ។

◯ អ្នកគេចចេញ ពីព្រោះគ្រួសាររបស់អ្នកនិយាយថា គេនឹងទ្រទ្រង់អ្នករហូតទាល់តែអ្នករកបានការងារផ្សេងទៀតធ្វើ

◯ អ្នកនឹងនៅតែអាចគេចផុតបាន ពីព្រោះអ្នកកើតមកដោយមានអភ័យឯកសិទ្ធិ ហើយអ្នកមិនអស់សង្ឃឹមដល់ថ្នាក់ប្រថុយធ្វើការងារដ៏គ្រោះថ្នាក់នោះទេ។

---

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៨៖

អ្នកគឺជា កូនកម្មករក្រីក្រមកពីប្រទេសមីយ៉ាន់ម៉ា។ ឪពុករបស់អ្នកបានខ្ចីប្រាក់ពីអ្នកឲ្យខ្ចីប្រាក់ម្នាក់កាលពី ១០ ឆ្នាំមុនដើម្បីចំណាយថ្លៃព្យាបាលជំងឺ។ គាត់មិនអាចមានលទ្ធភាពសងប្រាក់គេគ្រប់ចំនួនឡើយ។ អ្នកជួញដូរចង់ឲ្យអ្នកទៅធ្វើការនៅក្នុងឡឥដ្ឋមួយកន្លែង ដោយមិនទទួលបានកម្រៃ ដើម្បីសងបំណុលឪពុករបស់អ្នក។

◯ អ្នកមិនអាចគេចផុតទេ ពីព្រោះអ្នកគ្មានប្រាក់ គ្មានអំណាច និងគ្មានការអប់រំ ។

---

## ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៩៖

អ្នកគឺជា ក្មេងស្រីម្នាក់មានអាយុ ១៦ ឆ្នាំ ហើយត្រូវបានបញ្ជូនទៅទីក្រុងដើម្បីរស់នៅជាមួយគ្រួសារមានស្តុកស្តម្ភ ដូច្នេះអ្នកអាចបន្តការសិក្សាថ្នាក់មធ្យមសិក្សាបាន។ អ្នកព្រម ធ្វើការងារសម្អាតផ្ទះសម្បែង ដូច្នេះអ្នកអាចរស់នៅក្នុងផ្ទះនោះបាន។ យប់មួយបុរសជាឪពុកគេនៅក្នុងផ្ទះនោះបានមករកអ្នក ហើយប្រាប់អ្នកថា អ្នកត្រូវតែរួមភេទជាមួយគេទើបគេអនុញ្ញាតិឲ្យអ្នកស្នាក់នៅបាន។

◯ អ្នកអាចគេចចេញបានពីព្រោះអ្នកអាចស្រែកឲ្យឮខ្លាំងៗ។គាត់នឹងខ្លាចប្រពន្ធរបស់គាត់ដូចនេះគាត់នឹងបញ្ឈប់។

◯ អ្នកអាចគេចផុត ពីព្រោះពេលអ្នកចាកចេញពីផ្ទះ អ្នកបានយកប្រាក់ទៅជាមួយគ្រាប់គ្រាន់សម្រាប់ចំណាយសោហ៊ុយរថយន្តបាន ហើយអ្នកដឹងអំពីរបៀបរករថយន្ត ដើម្បីជិះត្រឡប់មកផ្ទះវិញរួចហើយ។ អ្នកក៏បានយកលេខទូរស័ព្ទរបស់អ្នកជិតខាងអ្នកដែលគេមានលេខទូរស័ព្ទ ដូច្នេះពេលព្រឹកឡើងបន្ទាប់ពីការកើតហេតុ អ្នកអាចទូរស័ព្ទទៅឪពុកម្តាយអ្នកនិងត្រឡប់ទៅផ្ទះវិញ។



**ប័ណ្ណលេខល្បែងអំពីអ្នកជួញដូរ ទី ៨៖**

អ្នកគឺជាអ្នកជួញដូរមនុស្ស ។



# មេរៀនទី ១០ ៖ អនុសញ្ញាស្តីពីសិទ្ធិកុមារ ១០

**ចំណុចបំណង**

អ្នកចូលរួមបានយល់អំពីសិទ្ធិរបស់គេរៀងៗខ្លួនក្នុងនាមជាយុវវ័យ ស្ថិតក្រោមច្បាប់ និងអាចភ្ជាប់ទំនាក់ទំនងសិទ្ធិទាំងនេះ ទៅនឹងជីវិតផ្ទាល់ខ្លួនរបស់គេ។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- ក្រដាសផ្ទាំងធំចំនួនពី ៨-១០ ផ្ទាំង
- ប៊ិចចម្រុះពណ៌មួយចំនួន

**សេចក្តីផ្តើម**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចក្រដាសតត្តានូវក្រដាចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

តើអ្នកបានសួរឪពុកម្តាយរបស់អ្នកអំពីការជួញដូរមនុស្សដែរ ឬទេ?
តើឪពុកម្តាយរបស់អ្នកបានដឹងអំពីល្បិចទូទៅមួយចំនួនរបស់អ្នកជួញដូរមនុស្សដែរ ឬទេ?

## សិទ្ធិកុមារ

### អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)

ពន្យល់ប្រាប់ថា មេរៀននេះ និយាយអំពីសិទ្ធិកុមារ ។ សួរថា តើមានអ្នកចូលរួមណាបានដឹងអំពី សិទ្ធិទាំងនេះដែរឬទេ ហើយប្រសិនបើមានឲ្យគេចែករំលែកចំណេះដឹងរបស់គេជាមួយនឹងក្រុម។ ពន្យាល់ថា កាលពី ២០ឆ្នាំមុន អង្គការសហប្រជាជាតិ (UN) បានបង្កើតអនុសញ្ញាមួយស្តីពីសិទ្ធិកុមារ។ CRC គឺជាកិច្ចព្រមព្រៀងក្នុងចំណោមប្រទេសនានាដែលប្រទេសទាំងអស់នោះបានឯកភាពអនុវត្តតាមច្បាប់ដូចគ្នាពាក់ព័ន្ធនឹងកុមារ។

ប្រាប់សិស្សថា CRC រៀបរាប់អំពីសិទ្ធិនានាដែលកុមារអាយុក្រោម ១៨ ឆ្នាំ ត្រូវមាន។ បណ្តាលប្រទេសជាច្រើនបានចុះហត្ថលេខាលើ CRC ច្រើនជាអនុសញ្ញាផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ។ ពន្យល់ប្រាប់គេថា ប្រទេសរបស់ខ្លួនបានចុះហត្ថលេខាលើអនុសញ្ញានេះរួចហើយ ដែលមានន័យថា ប្រទេសនេះបានព្រមព្រៀងថា កុមារនៅក្នុងប្រទេសនេះត្រូវមានសិទ្ធិដែលមានចែងក្នុងអនុសញ្ញានេះ។

ពន្យល់ថា មានមាត្រាចំនួន ៥៤ នៃ CRC ចែងរៀបរាប់អំពីសិទ្ធិផ្សេងៗដែលកុមារត្រូវមាន។ ដោយសារតែមានច្រើនពេក សិទ្ធិទាំងនេះត្រូវបានដាក់បញ្ចូលគ្នាជា បួនក្រុម “សំណុំ” នៃសិទ្ធិដើម្បីឲ្យគេងាយស្រួលក្នុងការចងចាំ។ សរសេរឈ្មោះនៃសំណុំសិទ្ធិទាំងបួននៅក្នុងរង្វង់ចំនួនធំៗចំនួនបួននៅលើក្រដាស់ផ្ទាំងធំមួយផ្ទាំង។ សំណុំសិទ្ធិទាំងនេះមានដូចខាងក្រោម ៖

### សិទ្ធិចំពោះការរស់រានមានជីវិត

ពន្យល់ថា សិទ្ធិទាំងនេះរួមមានសិទ្ធិចំពោះការហូបចុកគ្រប់គ្រាន់ សិទ្ធិចំពោះការថែទាំសុខភាព សិទ្ធិទទួលបានជម្រកស្នាក់នៅ និងសិទ្ធិទទួលបានការចុះឈ្មោះ និងសញ្ជាតិក្នុងបញ្ជីស្រប ច្បាប់។

### សិទ្ធិទទួលបានការការពារ

ពន្យល់ថា សិទ្ធិទាំងនេះរួមមាន សិទ្ធិទទួលបានការការពារប្រឆាំងនឹងអំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត ឬការរំលោភបំពាន សិទ្ធិទទួលបានការការពារពីការព្រងើយកន្តើយ ឬការកេងប្រវ័ញ្ច សិទ្ធិទទួលបានការការពារពីការរំលោភបំពានផ្លូវភេទ និងសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម និងពីការប្រើប្រាស់គ្រឿងញៀន។

### សិទ្ធិចំពោះការអភិវឌ្ឍ

ពន្យល់ថា សិទ្ធិទាំងនេះរួមមាន សិទ្ធិក្នុងការលេងកំសាន្ត សិទ្ធិទទួលបានការអប់រំ និងសិទ្ធិទទួលបានការថែទាំយ៉ាងកក់ក្តៅពីសំណាក់ឪពុកម្តាយ។

### សិទ្ធិចំពោះការចូលរួម

ពន្យល់អ្នកចូលរួមថា សិទ្ធិទាំងនេះរួមមាន សិទ្ធិក្នុងការសម្តែងមតិរបស់ខ្លួន និងការបញ្ចេញមតិ សិទ្ធិក្នុងការចូលរួមក្នុងក្រុម (ដូចជា SNYC) និងក្នុងការជួបមិត្តភ័ក្តិ។

### ការគូររូបភាព

ឲ្យអ្នកចូលរួមបំបែកក្រុមដែលមានគ្នាពី ៤-៥ នាក់ដើម្បីគូររូបគូរធំមួយអំពីសហគមន៍របស់គេលើក្រដាស ផ្ទាំងធំមួយ។ ប្រាប់ពួកគេថា មិនមែនផ្តោតលើជំនាញក្នុងការគូររូបទេ ប៉ុន្តែ ផ្តោតសំខាន់លើគំនិត។ ឲ្យក្រុមនីមួយៗគូរពីរូបភាពនៃផែនទីជីវិតរបស់កុមារនៅក្នុង សហគមន៍ របស់គេ និងគូរពីទីកន្លែងដែលកុមារអាចទទួលបានសិទ្ធិរបស់ខ្លួន ឬមិនទទួលបាន សិទ្ធិរបស់ខ្លួន។

ឧទាហរណ៍ថា កុមារបរិភោគអាហារពេលព្រឹក គឺជាការទទួលបានសិទ្ធិមួយ កុមាដែលអត់ឃ្លានគឺមិនទទួលបានសិទ្ធិមួយ។ អំឡុងពេលពួកគេកំពុងគូរ ចូរដើរទៅមកក្នុងបន្ទប់ និងប្រាប់ឲ្យពួកគេដាក់បញ្ចូលនូវអ្វីដែលបង្កការប៉ះពាល់ដល់កុមារផង រួមមាន ៖

- សុខភាព
- លទ្ធភាពទៅសាលារៀន
- ការងារ
- អំពើហិង្សារ
- ការសប្បាយ
- លទ្ធភាពក្នុងការបញ្ចេញមតិ

### សកម្មភាព

នៅពេលពួកគេបានបញ្ចប់ ប្រមូលអ្នកចូលរួមឲ្យមកជុំគ្នា។ គូសបន្ទាត់មួយពុះត្រង់ចុះមកក្រោមលើក្រដាសផ្ទាំងធំ។ ម្ខាងសរសេរ កុមារទទួលបានសិទ្ធិរបស់ខ្លួន នៅម្ខាងទៀតសរសេរថា កុមារមិនទទួលបានសិទ្ធិរបស់ខ្លួន។ឲ្យសិស្សផ្តល់ឧទាហរណ៍ពីគំនូររបស់គេទៅលើចំណុចទាំងពីរនេះ ហើយសរសេរលើក្រដាសនោះ។ នៅពេលដែលបញ្ចប់ ចូរបន្ថែមចំណុចខាងក្រោមដែលមិនទាន់បានលើកឡើង។

| កុមារទទួលបានសិទ្ធិរបស់ខ្លួន | កុមារមិនទទួលបានសិទ្ធិរបស់ខ្លួន |
|---|---|
| កុមារទៅសាលារៀន | កុមារមិនបានទៅសាលារៀន |
| កុមារទទួលបានការថែទាំសុខភាព | កុមារមិនទទួលបានការថែទាំសុខភាព |
| កុមារត្រូវបានអនុញ្ញាតិឲ្យបញ្ចេញមតិ | កុមារមិនត្រូវបានអនុញ្ញាតិឲ្យបញ្ចេញមតិ |
| កុមារបានបរិភោគគ្រប់គ្រាន់ | កុមារមិនបានបរិភោគគ្រប់គ្រាន់ |
| កុមារត្រូវបានអនុញ្ញាតិឲ្យលេងជាមួយមិត្តភក្តិ | កុមារមិនត្រូវបានអនុញ្ញាតិឲ្យលេងជាមួយមិត្តភក្តិ |
| កុមារមានសំបុត្រកំណើត | កុមារមិនមានសំបុត្រកំណើត |
| កុមារមានឯកសារអត្តសញ្ញាណជាតិ | កុមារមិនមានឯកសារអត្តសញ្ញាណជាតិ |
| កុមារត្រូវបានអនុញ្ញាតិឲ្យនិយាយភាសាដើម | កុមារមិនត្រូវបានអនុញ្ញាតិឲ្យនិយាយភាសាដើម |
| កុមារត្រូវបានអនុញ្ញាតិឲ្យគោរពសាសនាតាមជម្រើស | កុមារមិនត្រូវបានអនុញ្ញាតិឲ្យគោរពសាសនាតាមជម្រើស |
| កុមារទទួលបានព័ត៌មានពិតប្រាកដអំពីពិភពលោក | កុមារមិនទទួលបានព័ត៌មានពិតប្រាកដអំពីពិភពលោក |
| កុមារត្រូវបានការពារពីការរំលោភបំពានរាងកាយ/ផ្លូវភេទ | កុមារសេពគ្រឿងញៀន ឬគ្រឿងស្រវឹងច្រើនហួស<br>កុមារត្រូវគេវាយដំ<br>កុមារធ្វើការងារលំបាកខ្លាំង<br>កុមារត្រូវគេរំលោភបំពានផ្លូវភេទ។<br>កុមារធ្វើការនៅក្នុងផ្ទះបន |

## ការពិភាក្សា

ឲ្យអ្នកចូលរួម គិតអំពីក្មេងប្រុសអាយុ ១៦ឆ្នាំ ដែលត្រូវបានគេជួញដូរទៅក្នុងទូកនេសាទមួយ។ គេធ្វើការងារច្រើនម៉ោង ហើយមិនអាចគេចចេញពីទូកនោះបានទេ។ ចូរអានតារាងខាង កុមារមិនទទួលបានសិទ្ធិរបស់ខ្លួន ហើយដាក់សញ្ញា X នៅជាប់នឹងសិទ្ធិដែលគេពិតជាមិនទទួលបាន។

បន្ទាប់មក ឲ្យអ្នកចូលរួមពិចារណាអំពិក្មេងស្រីជាអ្នកបម្រើតាមផ្ទះដែលមានអាយុ ១១ ឆ្នាំម្នាក់។ នាងមិនមានឯកសារបញ្ជាក់អត្តសញ្ញាណទេ ពីព្រោះឪពុកម្តាយរបស់នាងជាជនចំណាកស្រុកមកពីទីជនបទ ហើយមិនអាចចុះបញ្ជីឲ្យនាងបាននៅពេលដែលនាងកើត។ នាងធ្វើការងារដោយមិនទទួលបានប្រាក់កម្រៃឲ្យគ្រួសារនោះ។ជាថ្មីម្តងទៀត ចូរអានតារាងខាង កុមារមិនទទួលបានសិទ្ធិរបស់ខ្លួនហើយដាក់សញ្ញា X នៅជាប់នឹងសិទ្ធិដែលនាងពិតជាមិនទទួលបាន។

ពន្យល់ថា កុមារដែលត្រូវបានគេជួញដូរ មិនអាចទទួលបាននូវសិទ្ធិរបស់គេជាច្រើនទៀត។ លើសពីនោះទៅទៀត កុមារដែលមិនទទួលបានសិទ្ធិរបស់ខ្លួន គឺមានភាពងាយរងគ្រោះកាន់តែខ្លាំងចំពោះការជួញដូរ។ សួរសំណួរខាងក្រោមទៅកាន់ក្រុមនីមួយៗ ៖

**តើកុមារដែលមិនបានរៀននៅសាលាទំនងជាភាគច្រើនត្រូវបានជួញដូរ ដែរឬទេ?**

ទុកពេលឲ្យអ្នកចូលរួមផ្តល់ចម្លើយរបស់គេសិន ហើយបន្ទាប់មកបន្ថែមចម្លើយខាងក្រោមប្រសិនបើមិនទាន់មានលើកឡើងទេនោះ ៖

ត្រឹមត្រូវហើយ កុមារដែលមិនបានទៅសាលារៀន គឺទំនងជាអាចនឹងត្រូវបានជួញដូរច្រើនជាងពីព្រោះ ៖

- អ្នកដែលទទួលបានការអប់រំ ជាញឹកញាប់តែងតែទទួលបានការងារល្អជាងអ្នកដែលមិនមានការអប់រំ។
- ការមានលទ្ធភាពអាចអានកិច្ចសន្យាបាន អាចនឹងបញ្ឈប់អ្នកមិនឲ្យចុះហត្ថលេខាលើកិច្ចសន្យាមិនល្អបាន។
- មនុស្សចាស់ទុំដែលបានបញ្ចប់ការសិក្សាកាន់តែច្រើនឆ្នាំ ដឹងកាន់តែច្រើនអំពីពិភពលោក ។

**តើកុមារដែលមិនមានឯកសារអត្តសញ្ញាណ ភាគច្រើនទំនងជាត្រូវបានគេជួញដូរមែន ឬទេ?**

ទុកពេលឲ្យអ្នកចូលរួមផ្តល់ចម្លើយរបស់គេសិន ហើយបន្ទាប់មក បន្ថែមចម្លើយខាងក្រោមប្រសិនបើ មិនទាន់មានលើកឡើងទេនោះ ៖

ត្រឹមត្រូវ កុមារដែលមិនមានឯកសារអត្តសញ្ញាណ គឺទំនងជាអាចនឹងត្រូវបានជួញដូរច្រើនពីព្រោះ

- មានការងារជាច្រើន ដែលអ្នកមិនអាចដាក់ពាក្យសុំធ្វើបាន ប្រសិនបើអ្នកមិនមានឯកសាររបស់រដ្ឋដែលគេត្រូវការទេនោះ។
- អ្នកអាចនឹងខ្លាចមិនហ៊ានទៅរកប៉ូលីសនៅពេលដែលអ្នកជួបប្រទះបញ្ហា។

**តើកុមារដែលមិនអាចទទួលបានព័ត៌មានពិតប្រាកដអំពីពិភពលោក អាចទំនងជាត្រូវគេជួញដូរមែនឬទេ?**

ទុកពេលឲ្យសិស្សផ្តល់ចម្លើយរបស់គេសិន ហើយបន្ទាប់មកបន្ថែមចម្លើយខាងក្រោមប្រសិនបើមិនទាន់មានលើកឡើងទេនោះ ៖

ត្រឹមត្រូវហើយ កុមារដែលមិនអាចទទួលបានព័ត៌មានពិតប្រាកដ អំពីពិភពលោកអាចទំនងជាត្រូវគេជួញដូរមែន ពីព្រោះ ៖

- បើអ្នកមានចំណេះដឹងកាន់តែច្រើន អំពីវិធីទទួលបានការងារដ៏មានសុវត្ថិភាពមួយ ធ្វើចំណាកស្រុក ដោយសុវត្ថិភាព និងគេចផុតពីល្បិចឆបោករបស់អ្នកជួញដូរនោះ គឺអ្នកអាចការពារ ខ្លួនបានកាន់តែល្អ។

  បន្ទាប់ពីពួកគេបានបញ្ចប់ ឲ្យអ្នកចូលរួមអង្គុយក្នុងក្រុមមួយ និងសុំឲ្យពួកគេពិចារណាអំពីសំណួរខាងក្រោម។ លើកទឹកចិត្តពួកគេបញ្ចេញមតិយោបល់របស់ខ្លួន និងស្តាប់គំនិតរបស់អ្នកដទៃ។
- តើអ្វីដែលជួយដល់កុមារឲ្យទទួលបានសិទ្ធិរបស់គេ?
- តើអ្វីដែលបញ្ឈប់កុមារមិនឲ្យទទួលបានសិទ្ធិរបស់ខ្លួន? តើភាពក្រីក្រ ឪពុកម្តាយ និងការ

រើសអើងជះឥទ្ធិពលលើកត្តានេះដែរ ឬទេ?
- តើកូនអ្នកមានទទួលបានសិទ្ធិច្រើនជាងកូនអ្នកក្រមែន ឬទេ? ហេតុអ្វី?
- តើក្មេងប្រុសទទួលបានសិទ្ធិច្រើនជាងក្មេងស្រីមែន ឬទេ? ហេតុអ្វី?

**អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់**

នៅចុងបញ្ចប់នៃមេរៀនសិក្សានេះ និយាយឡើងវិញអំពីអ្វីដែលបានលើកឡើងពីខាងដើមអំពីការចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៃប្រទេសនីមួយៗ និងការព្រមព្រៀងប្រកាន់ខ្ជាប់នូវសិទ្ធិទាំងឡាយដែលអនុសញ្ញានេះបានផ្តល់ឲ្យកុមារ។ ពន្យល់ថា មានកុមារជាច្រើននៅក្នុងសហគមន៍របស់គេដែលត្រូវបានគេបដិសេធន៍ចំពោះសិទ្ធិមួយចំនួននៅក្នុង CRC។ ច្បាប់នឹងត្រូវលើកយកមកពិភាក្សាជាក់លាក់បន្ថែមទៀតនៅមេរៀនបន្ទាប់ ប៉ុន្តែជាការសំខាន់គឺត្រូវចងចាំថា ដោយសារតែមានច្បាប់អន្តរជាតិប៉ុណ្ណឹង មិនមែនមានន័យថាច្បាប់ជានិច្ចកាលត្រូវបានគោរពតាម ឬអនុវត្តនោះទេ។

**សង្ខេបមេរៀន**
- CRC គឺជាឯកសារអន្តរជាតិមួយដែលរៀបរាប់អំពីសិទ្ធិដែលកុមារត្រូវមាន។
- មានសំណុំសិទ្ធិចំនួន ៤ នៅក្នុង CRC
  - ការការពារ
  - ការអភិវឌ្ឍ
  - ការរស់រានមានជីវិត
  - ការចូលរួម។
- នៅពេលដែលកុមារត្រូវបានគេជួញដូរ គេពុំបានទទួលនូវសិទ្ធិរបស់គេឡើយ។
- នៅពេលដែលកុមារមិនទទួលបានសិទ្ធិរបស់ខ្លួននោះ ពួកគេមានភាពងាយរងគ្រោះកាន់តែខ្លាំងចំពោះការដែលត្រូវបានគេជួញដូរ
- មនុស្សជាច្រើននៅក្នុងប្រទេសរបស់យើង និងនៅលើសកលលោកមិនទទួលបានសិទ្ធិរបស់គេដែលមានចែងនៅក្នុង CRC នោះទេ។

**ការបិទវគ្គ**

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចូលឈ្មោះ។

ប្រាប់គេថា មិនមានការសម្តែងរឿង ឬកំណាត់ហេតុទេនៅចុងបញ្ចប់នៃមេរៀនថ្ងៃនេះ ពីព្រោះមានព័ត៌មានយ៉ាងច្រើនអំពី CRC ដែលត្រូវពិភាក្សា។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានរៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំគ្នាពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។

ឲ្យអ្នកចូលរួម អង្កេតមើលកន្លែងនានានៅក្នុងសហគមន៍របស់គេផ្ទាល់ជាទីដែលកុមារទទួលបានសិទ្ធិរបស់គេ និងទីដែលកុមារត្រូវបានបដិសេធន៍សិទ្ធិរបស់គេ។

អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមឲ្យសរសេរការណែនាំនេះលើក្រដាសដើម្បីយកទៅផ្ទះ ដើម្បីរំឭក ។

# ១១ មេរៀនទី១១៖ ច្បាប់ស្តីពីការជួញដូរមនុស្ស និងសិទ្ធិមនុស្ស

**វត្ថុបំណង**

យុវជននឹងយល់អំពីច្បាប់ និងវិធីធ្វើយ៉ាងណាដើម្បីទទួលបានយុត្តិធម៌នៅក្នុងក្របខ័ណ្ឌច្បាប់

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- កូនសៀវភៅនារីកវែឆ្លាត
- ថងចម្លងនូវ "TS ១១ក ៖ សេណារីយ៉ូ ក្រោយការជួញដូរមនុស្ស" សម្រាប់យុវជនម្នាក់ៗ"

**សេចក្តីផ្តើម**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសល្បែងថាមពលពីក្នុងតារាង។

**ការរំឭកមេរៀន**

តើអ្នកបានអង្កេតមើលកន្លែងនានានៅក្នុងសហគមន៍របស់អ្នកជាទីដែលកុមារទទួលបានសិទ្ធិរបស់គេ ឬជាទីដែលកុមារត្រូវបានបដិសេធន៍សិទ្ធិរបស់គេដែ ឬទេ? ចូររៀបរាប់ ។

តើយើងអាចជួយដល់កុមារឲ្យទទួលបានសិទ្ធិរបស់គេនៅថ្ងៃអនាគតបានដែរ ឬទេ? ប្រសិនបើបានតើដោយវិធីណា?

**ការពិភាក្សា**

ពន្យល់ថា ប្រទេសនីមួយៗមានច្បាប់ដែលគ្រប់គ្រងលើអ្វីដែលកើតមានឡើងនៅក្នុងប្រទេសរបស់ខ្លួន។

ពន្យល់ថា ប្រទេសនានាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលមានប្រសិទ្ធភាពអនុវត្តនៅក្នុងប្រទេសផ្សេងៗជាច្រើនទៀតផងដែរ។

នៅពេលដែលប្រទេសមួយចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ មានន័យថា ខ្លួនមានភារកិច្ចក្នុងការព្យាយាមអនុវត្តនូវប្រការទាំងឡាយនៅក្នុងកិច្ចព្រមព្រៀងនោះនៅក្នុងប្រទេសរបស់ខ្លួន។

ប្រាប់អ្នកចូលរួមថា មានកិច្ចព្រមព្រៀងសំខាន់ៗចំនួនពីរគឺ ៖

- អនុសញ្ញាស្តីពីសិទ្ធិកុមារ (បានពិភាក្សាកាលពីមេរៀនមុន)
- ពិធីសារប៉ាលែរម៉ូ

ចែកកូនសៀវភៅនារីក។ ឲ្យអ្នកចូលរួមបើកទៅផ្នែកនិយាយអំពី "ច្បាប់ និងអនុសញ្ញាពាក់ព័ន្ធនឹងការជួញដូរមនុស្ស" នៅក្នុងទំព័រទី ៥។

ឲ្យអ្នកចូលរួមស្ម័គ្រចិត្តដាក់វេណគ្នាអានអត្ថបទទាំងនេះឲ្យឮៗ និងសុំឲ្យអ្នកចូលរួមពិចារណាថា តើការដឹងអំពីច្បាប់នានាអាចនឹងជួយដល់ពួកគេបានច្រើនចាកចេញពីស្ថានភាពជួញដូរ

និងស្វែងរកជំនួយបានដែរ ឬទេ។

ពន្យល់ថា ពិធីសារប៉ាល័រម៉ូ និង CRC ត្រូវបានចុះហត្ថលេខាដោយប្រទេសជាច្រើនរួមទាំងប្រទេសរបស់អ្នកចូលរួមផងដែរ។ ប្រទេសរបស់គេមានការហាមឃាត់ការជួញដូរមនុស្ស។ ប៉ុន្តែការជួញដូរមនុស្សនៅតែជាបញ្ហាចម្បងដដែល។

- មានចំនួនចន្លោះពី ១៥% និង ៣០% ទាំងក្មេងប្រុស និងក្មេងស្រី ដែលតាមឲ្យដឹង គឺថាបានជួបប្រទះនឹងការរួមភេទដោយបង្ខំ នៅក្នុងតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក។
- អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថា កុមារ និងយុវវ័យប្រមាណ ១,២ លាននាក់ត្រូវបានជួញដូរជារៀងរាល់ឆ្នាំ ។
- ការប៉ាន់ប្រមាណនានាបានលើកឡើងថា មនុស្សប្រមាណ ២៧ នាក់គឺជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស

សួរទៅសិស្សថា ៖ “តើការជួញដូរមនុស្សជាអំពើខុសច្បាប់ដែរ ឬទេ ហេតុអ្វីក៏វាមានការរីករាលដាលសំបើមម្លេះ? តើមាននរណាអាចប្រាប់មូលហេតុថា ហេតុអ្វីបានជាអំពើជួញដូរមនុស្សនៅតែបន្តកើនឡើងបានដែរ ឬទេ ?”

បន្ទាប់ពីអ្នកចូលរួមបានផ្តល់គំនិតរបស់គេរួច ចូរបន្ថែមនូវមូលហេតុខាងក្រោម ប្រសិនបើគេមិនទាន់បានលើកឡើង ៖

**១. អ្នកជួញដូររកប្រាក់បានច្រើន ៖**

ពន្យល់ថា ការចំណាយទិញមនុស្សគឺថោកណាស់បើប្រៀបធៀបទៅនឹងប្រាក់ដែលមនុស្សអាចរកឲ្យអ្នកជួញដូរនោះ។ ម្ចាស់ទូកដែលជាអ្នកជួញដូរម្នាក់គ្រាន់តែចំណាយប្រាក់ទិញជនរងគ្រោះប៉ុណ្ណោះ ប៉ុន្តែគេមិនចាំបាច់បើកប្រាក់ខែឲ្យជនរងគ្រោះទេ។

**២. ប្រព័ន្ធអយ្យការមិនរឹងមាំ ៖**

ពន្យល់ថា គ្រប់ប្រទេសទាំងអស់ មានប្រព័ន្ធមួយដែលមានសិទ្ធិចាប់ខ្លួនបុគ្គលដែលគេសង្ស័យពីបទឧក្រិដ្ឋ ស៊ើបអង្កេតបទឧក្រិដ្ឋ និងចោទប្រកាន់ជនសង្ស័យនៅតុលាការដើម្បីកំណត់ថាតើគេមានពិរុទ្ធភាពដែរ ឬទេ គេត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ។ ប៉ូលីស មេធាវី ចៅក្រម និងតុលាការត្រូវតែមានភាពរឹងមាំសម្រាប់ដំណើរការនេះ ដើម្បីដំណើការបាន។ ប្រព័ន្ធនេះគេ ហៅថាប្រព័ន្ធអយ្យការ។

ប្រាប់អ្នកចូលរួមថា ប្រព័ន្ធអយ្យការដែលនឹងដាក់ទោសទណ្ឌ ឬចោទប្រកាន់លើអ្នកជួញដូរមនុស្សនោះ មិនមែនមានភាពរឹងមាំគ្រប់ពេលឡើយ។ ប៉ូលីស និងតុលាការប្រហែលជាមិនបានដឹងពីវិធីណាដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរទេ ហើយអាចនឹងចោទប្រកាន់ជនរងគ្រោះពីការជួញដូរថា ជាជនចំណាកស្រុកខុសច្បាប់ទៅវិញ។

ប្រាប់អ្នកចូលរួមថា ជនរងគ្រោះពីការជួញដូរអាចនឹងត្រូវបានចោទប្រកាន់ក្នុងលក្ខណៈមួយដែលធ្វើឲ្យគេមានការឈឺចាប់។ ឧទាហរណ៍ដូចជា ជនរងគ្រោះពីការជួញដូរអាចនឹងត្រូវបានបង្ខំឲ្យបង្ហាញខ្លួននៅចំពោះមុខនៅក្នុងបន្ទប់សវនាការដែលពេញទៅដោយមនុស្សដើម្បីបកស្រាយអំពីរឿងរ៉ាវអាក្រក់ៗដែលបានកើតមានចំពោះពួកគេពេលដែលគេត្រូវបានជួញដូរ។

ពន្យល់ថា ពេលខ្លះអ្នកជួញដូរមនុស្សជាអ្នកមានទ្រព្យច្រើន និងមានអំណាច។ ប៉ូលីស

អាចនឹងមិនហ៊ានចោទប្រកាន់អ្នកជួញដូរនោះទេ ឬអ្នកជួញដូរអាចនឹងបង់ប្រាក់ឲ្យប៉ូលីសដើម្បីលុបចោលសំណុំរឿងចោទលើរូបគេផងដែរ។ ពេលខ្លះប៉ូលីស ឬមេធាវីមិនមានប្រាក់ ឬមធ្យោបាយ ដើម្បីស៊ើបអង្កេតលើអ្នកជួញដូរមនុស្សទេ។

**៣. ជនរងគ្រោះពីការជួញដូរអាចនឹងមិនប្តឹងចោទ។**

ពន្យល់ថា ជនរងគ្រោះពីការជួញដូរអាចនឹងមិនហ៊ានប្តឹងចោទអ្នកជួញដូររូបគេទេ ដោយសារគេ ភ័យខ្លាច មិនយល់អំពីសិទ្ធិរបស់គេ ឬប្រហែលជាមិនដឹងច្បាស់អ្វីដែលបានកើតឡើងលើរូបគេគឺជាអំពើខុសច្បាប់នោះទេ។

## សកម្មភាព

ចែកក្រដាស “IS ១១ក ៖ សេណារីយ៉ូ ក្រោយពីការជួញដូរ”

ប្រាប់អ្នកចូលរួមឲ្យចែកជាក្រុមមានគ្នា បី នាក់។ ឲ្យក្រុមនីមួយៗមើលរូបភាព និងអានរឿងទាំងអស់។ ឲ្យ អ្នកចូលរួមសជ្រើសរើសរឿងមួយក្នុងចំណោមរឿងទាំងអស់ និងសរសេរនៅក្នុងពពុះគំនិត អំពីអារម្មណ៍របស់ជនរងគ្រោះពាក់ព័ន្ធនឹងចំណេះដឹង ឬភាពមិនដឹងអំពីសិទ្ធិរបស់ខ្លួន។ មានចម្លើយជាឧទាហរណ៍មួយចំនួនចុងបញ្ចប់។

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមបែងចែកជាពីរក្រុមដែលមួយក្រុមមានគ្នាពី ៨-១២ នាក់។ ឲ្យក្រុមនីមួយៗរៀបចំម្តែងរឿង។

ពន្យល់អ្នកចូលរួមថា ការសម្តែងរឿងទាំងពីរនេះនឹងប្រើរឿងតែមួយដែលមានអធិប្បាយខាងក្រោមនេះ ប៉ុន្តែមានចុងបញ្ចប់ / លទ្ធផលនៃរឿងគឺខុសគ្នា។ អានរឿងឲ្យឮៗ។

**រឿង**

ក្មេងចំណាកស្រុកអាយុ១៧ឆ្នាំម្នាក់ត្រូវបាននាំទៅដល់រោងចក្រមួយដោយអ្នកជ្រើសរើសបុគ្គលិកម្នាក់។អ្នកចំណាកស្រុកម្នាក់នោះមិនចូលចិត្តរោងចក្រនោះទេ ហើយមានការសង្ស័យ។ មើលទៅការងារដូចជាគ្រោះថ្នាក់ណាស់ ហើយកម្មករដូចជាភ័យខ្លាច។ ជនចំណាកស្រុកនេះកាន់តែមានការសង្ស័យទៀតនៅពេលដែលអ្នកជ្រើសរើសបុគ្គលិកម្នាក់នោះបាននិយាយថា គេត្រូវធ្វើការនៅក្នុងរោងចក្រនោះរយៈពេល ៣ ខែដោយមិនទទួលបានកម្រៃ។

បន្ទាប់មកឲ្យអ្នកចូលរួមទៅមើលចំណុច “ច្បាប់ជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស” នៅក្នុងកូនសៀវភៅនាវិកវៃឆ្លាត ដើម្បីរកច្បាប់ណាដែលអាចការពារជនចំណាកស្រុកនៅក្នុងរឿងនេះ។ ក្រុមមួយគួររៀបចំការសម្តែងរឿងដែលជនចំណាកស្រុកគេចចេញពីអ្នកជួញដូរមនុស្សដោយការតវ៉ាសម្រាប់សិទ្ធិរបស់ខ្លួន។ ក្រុមមួយទៀតត្រូវបង្កើតរឿងដែលជនចំណាកស្រុកមិនដឹងអំពីសិទ្ធិរបស់ខ្លួន ហើយមិនគេចចេញទេ។ សួរទៅក្រុមទាំងពីរថា ហេតុអ្វីបានជាការដឹងអំពីច្បាប់អាចជួយដល់ជនចំណាកស្រុកឲ្យគេចចេញបាន។

ប្រាប់ក្រុមទាំងពីរឲ្យរៀបចំការសម្តែងរឿងមានរយៈពេល ៥ នាទី ហើយបន្ទាប់មកសម្តែងម្តងមួយក្រុម។

ពន្យល់ថា ប្រសិនបើមនុស្សអាចរត់គេចចេញបាននៅពេលដែលគេត្រូវបានជួញដូរនោះនឹងមានរឿងប្លែកៗជាច្រើន ដែលអាចនឹងកើតមានចំពោះគេ ៖

- អ្នកខ្លះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។
- អ្នកខ្លះទទួលបានជម្រកពីប្រទេសដែលគេទៅដល់រយៈពេលបី បួនខែ ហើយបន្ទាប់មកត្រូវបានបញ្ជូនត្រឡប់មកផ្ទះវិញ។
- អ្នកខ្លះបានត្រឡប់មកផ្ទះវិញដោយមិនបានបញ្ជូនទៅកាន់ប៉ូលីស
- អ្នកខ្លះផ្លាស់ទៅរកការងារផ្សេងទៀត
- អ្នកខ្លះត្រូវបានឃាត់ខ្លួនក្នុងលក្ខណៈជាជនចំណាកស្រុកខុសច្បាប់ ប្រសិនបើរដ្ឋាភិបាលនៃប្រទេសដែលគេទៅដល់នោះមិនទទួលស្គាល់ថា គេជាជនរងគ្រោះពីការជួញដូរទេនោះ។

ពន្យល់ប្រាប់ថា ប្រសិនបើគេកំពុងគិតអំពីការធ្វើចំណាកស្រុកនោះ ជាការសំខាន់គឺត្រូវដឹងឲ្យបានច្បាស់ថាបើទោះបីជាការជួញដូរមនុស្សជាអំពើខុសច្បាប់ក៏ដោយក៏វាមិនមែនមានន័យថាអ្នកអាចពឹងផ្អែកលើច្បាប់ដើម្បីការពារខ្លួនអ្នកដែរ ប្រសិនបើអ្នកត្រូវបានគេជួញដូរហើយនោះ។ អ្នកជួញដូរមិនមែនត្រូវបានចោទពីបទល្មើសដោយច្បាប់គ្រប់ពេលវេលានោះទេ។

**សង្ខេបមេរៀន**

- ពិធីសារក្រុង ប៉ាលឺម៉ូ និងច្បាប់របស់ប្រទេសយើងហាមឃាត់ចំពោះការជួញដូរមនុស្ស។
- ការជួញដូរមនុស្ស ក៏បដិសេធន៍កុមារចំពោះសិទ្ធិរបស់គេ ដែលបានផ្តល់ឲ្យកុមារនៅក្នុង CRC។
- បើទោះបីជាការជួញដូរមនុស្សជាអំពើខុសច្បាប់ក៏ដោយ ក៏មានមនុស្សប្រមាណជា២៧លាននាក់កំពុងក្លាយជាជនរងគ្រោះនៃអំពើជួញដូរនេះដែរ។
- អ្នកជួញដូរមិនមែនត្រូវបានចោទពីបទល្មើសដោយច្បាប់គ្រប់ពេលទេ។ នេះអាចដោយសារតែ៖
  - អ្នកជួញដូររកប្រាក់បានច្រើន។
  - ប្រព័ន្ធអយ្យការមិនរឹងមាំ។
  - ជនរងគ្រោះពីការជួញដូរមិនហ៊ានប្តឹងចោទ។
- ប្រសិនបើគេកំពុងគិតអំពីការធ្វើចំណាកស្រុកនោះ អ្នកមិនអាចពឹងផ្អែកលើច្បាប់ដើម្បីការពារខ្លួន តែមួយមុខនោះទេ។

## ភារកិច្ចវគ្គ

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។ ឲ្យអ្នកចូលរួមសួរសំណួរខាងក្រោមទៅឪពុកម្តាយរបស់គេ ៖

- តើពុកម៉ែមានធ្លាប់ដឹងរឿងថាមានអ្នកដែលត្រូវគេជួញដូរពីក្នុងសហគមន៍របស់យើងដែរទេ?
- តើជនរងគ្រោះពីការជួញដូរជ្រើសរើផ្លូវប្តឹងអ្នកជួញដូរទៅតុលាការដែរ ឬទេ? ហេតុអ្វីគេធ្វើ ហេតុអ្វីគេមិនហ៊ានធ្វើ?

អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមឲ្យសរសេរការណែនាំនេះលើក្រដាសដើម្បីយកទៅផ្ទះដើម្បីរំឭក ។



១. ធ បានគេចចេញ ពីការជួញដូរដោយសម្រេចចិត្តស្នាក់នៅប្រទេសថៃ។ គេរកបានការងារផ្សេងទៀត ប៉ុន្តែត្រូវគេជួញដូរម្តងទៀត។ ចុងក្រោយ ធ បានគេចខ្លួនទៀត ប៉ុន្តែភ័យខ្លាចអាជ្ញាធរចាប់ខ្លួន ពីព្រោះគេមិនមានឯកសារ ស្របច្បាប់ទេ ដូច្នេះ ចុងក្រោយគេរកបានការងារនៅក្នុងកសិដ្ឋានមួយ។ គេមិនដែលយល់ច្បាស់ទេថា គេត្រូវបានជួញដូរ។ គាត់គ្រាន់តែគិតថា គាត់មានការងារមិនល្អប៉ុណ្ណោះ។



២. ម បានគេចចេញ ពីការជួញដូរជាអ្នកបម្រើតាមផ្ទះម្នាក់នៅប្រទេសម៉ាឡេស៊ី។ នាងត្រូវបានចាប់ខ្លួនដោយប៉ូលីសចោទពីបទជនអន្តោប្រវេសន៍ខុសច្បាប់ ហើយចាប់ឃុំខ្លួន ៣ខែ មុនពេលនាងត្រូវបានបញ្ជូនត្រឡប់ទៅកម្ពុជាវិញ។ នាងបានត្រឡប់ទៅផ្ទះវិញ ហើយមិនបាននិយាយអំពីអ្វីដែលបានកើតឡើងចំពោះនាងនោះទេ។



៣. ស ត្រូវបានជួយសង្គ្រោះពីរោងចក្រមួយនៅក្នុងប្រទេសរបស់នាងដោយប្រតិបត្តិការឆែកឆេរបស់ប៉ូលីស។ ប៉ូលីសបាននិយាយថា នាងត្រូវបានគេជួញដូរ ហើយចង់ឲ្យនាងដាក់ពាក្យប្ដឹងចោទលើម្ចាស់រោងចក្រ។ ក៏ប៉ុន្តែ ស ពិតជាមានភាពក្រៀមក្រំខ្លាំងណាស់ចំពោះអ្វីដែលបានកើតឡើងលើរូបនាង ហើយវាជារឿងអាម៉ាស់ណាស់ដែលនិយាយអំពីរឿងនេះ  ដូច្នេះ នាងសម្រេចចិត្តត្រឡប់ទៅផ្ទះ គ្រួសាររបស់នាងវិញ។




៨. ក បានរត់គេចពីរោងចក្រមួយកន្លែង ជាទីដែលនាងត្រូវបានគេបង្ខំឲ្យធ្វើការដោយមិនបានកម្រៃ និងមិនអាចចាកចេញបាន។ នាងបានឃើញមណ្ឌលជនអន្តោប្រវេសន៍មួយ ហើយគេបានឲ្យនាងទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលជួយជនរងគ្រោះដោយការជួញដូរ។ អង្គការ NGO សហការជាមួយប៉ូលីស ដើម្បីឃាត់ខ្លួនអ្នកជួញដូរមនុស្ស ហើយបានបិទរោងចក្រ ហើយ ក បានផ្តល់ភស្តុតាងជូនដល់សំណុំរឿង។




៥. ល បានរត់គេចពីផ្ទះបនមួយកន្លែងនៅក្នុងប្រទេសក្រៅ ហើយបានទូរស័ព្ទទៅឪពុកម្ដាយរបស់នាងឲ្យជួយ។ ពួកគេមិនដឹងធ្វើដូចម្ដេចទេដើម្បីជួយនាង។ នាងបានទៅកាន់ប៉ុស្ដិ៍ប៉ូលីសដើម្បីរាយការណ៍ពីអ្វីដែលបានកើតឡើង។ គេគិតថា នាងគ្រាន់តែជាស្ត្រីពេស្យាម្នាក់ ហើយគេមិនចង់ជួយដល់នាងទេ។ ប៉ូលីសក៏បានទទួលប្រាក់ពីម្ចាស់ផ្ទះបននោះជារៀងរាល់ខែផងដែរ ដូច្នេះគេមិនចង់ស្ដាប់នាងទេ។

ចម្លើយជាឧទាហរណ៍ ៖

១. ដោយសារតែខ្ញុំមិនមានឯកសារស្របច្បាប់ ខ្ញុំមិនមានសិទ្ធិទទួលបានការងារស្របច្បាប់ទេ។ ខ្ញុំមិនចង់ទៅប៉ុស្តិ៍ប៉ូលីសទេ ពីព្រោះខ្ញុំអាចនឹងជួបបញ្ហាច្រើនជាងនេះ។

២. វាជាកំហុសរបស់ខ្ញុំ ដែលគេឃុំខ្លួនខ្ញុំ នៅប្រទេសម៉ាឡេស៊ី ពីព្រោះខ្ញុំបានធ្វើការងារដោយខុសច្បាប់។ ខ្ញុំមិនចង់ប្រាប់គ្រួសាររបស់ខ្ញុំទេ ពីព្រោះគេមិនយល់ទេ។

៣. ខ្ញុំមិនយល់អំពីសិទ្ធិ ដែលខ្ញុំមាន ដើម្បីប្តឹងចោទអ្នកជួញដូរនោះទេ។ ខ្ញុំនឿយហត់ និងទទួលនូវស្លាកស្នាមទុរយសច្រើនពេកហើយពីបទពិសោធន៍នេះ ខ្ញុំគ្រាន់តែចង់ទៅផ្ទះវិញ ហើយបំភ្លេចចោលអ្វីទាំងអស់ដែលបានកើតឡើង។

៤. ខ្ញុំដឹងអំពីសិទ្ធិដែលខ្ញុំមាន ដើម្បីប្តឹងចោទអ្នកជួញដូររូបខ្ញុំ ពីព្រោះអ្វីដែលគេបានធ្វើមកលើរូបខ្ញុំជាអំពើខុសច្បាប់។ ខ្ញុំមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ច។

៥. ខ្ញុំមានអារម្មណ៍ថា ក្បត់ខ្លួនឯង ដោយសារខ្ញុំប្រព្រឹត្តផ្ទុយពីឆន្ទៈរបស់ខ្លួន ដោយត្រូវធ្វើការបម្រើភ្ញៀវជារៀងរាល់យប់។ ខ្ញុំដឹងថា ខ្ញុំមានសិទ្ធិទទួលបានការការពារពីការរំលោភបំពានទាំងនេះ។

# ១២ មេរៀនទី១២ ៖ ការធ្វើចំណាកស្រុក ដែលមានឯកសារស្របច្បាប់

## ទស្សនៈ

អ្នកចូលរួមនឹងយល់អំពីភាពខុសគ្នាអំពីការធ្វើចំណាកស្រុកដែលមានឯកសារត្រឹមត្រូវ និងខុសច្បាប់ និងយល់ច្បាស់ថា ការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់គឺ ជាជម្រើសដែលមានសុវត្ថិភាព។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ក្រដាសផ្ទាំងធំ និងប៊ិច
- រូបថតលិខិតឆ្លងដែន និងទិដ្ឋាការ
- ឯកសារយោង "IS ១២ក ៖ តារាងឧទាហរណ៍នៃការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់/មិនស្របច្បាប់" សម្រាប់សកម្មភាព

## ការត្រៀម

ពិនិត្យមើលអាយុស្របច្បាប់ ដើម្បីធ្វើការងារនៅក្នុងប្រទេសរបស់អ្នក ដើម្បីឲ្យអ្នកអាចចែករំលែក ជាមួយនឹងអ្នកចូលរួមផ្សេងទៀតក្នុងមេរៀននេះ។

## សេចក្តីផ្តើម

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតគ្នានូវបញ្ជីឈ្មោះចុះវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ជ្រើសរើសល្បែងថាមពលនៅក្នុងតារាង។ (មិនត្រូវជ្រើសរើសយកល្បែងបោះបាល់ចងចាំទេ ព្រោះល្បែងបោះនេះត្រូវលេងនៅចុងបញ្ចប់នៃមេរៀននេះ។

**ការរំឭកមេរៀន**

តើអ្នកធ្លាប់ដឹងរឿងថា មានអ្នកដែលត្រូវគេជួញដូរពីក្នុងសហគមន៍របស់យើងដែរទេ?

### ការធ្វើចំណាកស្រុក

ពន្យល់ថា យុវជនធ្វើចំណាកស្រុកតាមមធ្យោបាយផ្សេងគ្នា។

**ការធ្វើចំណាកស្រុកក្នុងប្រទេស** មានន័យថា មនុស្សធ្វើចំណាកស្រុកនៅក្នុងប្រទេសរបស់ខ្លួន។ ពន្យល់ថា មិនមានតម្រូវអាយុដោយច្បាប់ទេសម្រាប់ការធ្វើចំណាកស្រុកក្នុងប្រទេសរបស់ខ្លួន ប៉ុន្តែមានអាយុតម្រូវដោយច្បាប់សម្រាប់ការងារ។ អ្នកសម្របសម្រួលគួរប្រាប់ដល់អ្នកចូលរួមអំពីអាយុស្របច្បាប់សម្រាប់ការងារនៅក្នុងប្រទេសរបស់ខ្លួន។

**ការធ្វើចំណាកស្រុកក្រៅប្រទេស** មានន័យថា មនុស្សធ្វើចំណាកស្រុកទៅប្រទេសដទៃ។ ជាអន្តរជាតិ វាជាការមិនស្របច្បាប់ទេសម្រាប់ការធ្វើចំណាកស្រុកទៅធ្វើការងារក្រោមអាយុ ១៨ ឆ្នាំនោះ។

ប្រាប់អ្នកចូលរួមថា គ្រប់ប្រទេសទាំងអស់សុទ្ធតែមានច្បាប់ដែលនិយាយអំពី អ្នកដែលអាចធ្វើចំណាកស្រុកចូលទៅកាន់ប្រទេសខ្លួន។ ច្បាប់ទាំងនេះបរិយាយអំពីអ្វីដែលបុគ្គលម្នាក់ត្រូវធ្វើ ដើម្បីធ្វើចំណាកស្រុកចូលដោយស្របច្បាប់ ។

ពន្យល់ថា ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ (ឬ ហៅថា ការធ្វើចំណាកស្រុកស្របច្បាប់/ប្រក្រតី) មានន័យថា ជនចំណាកស្រុកត្រូវអនុវត្តតាមច្បាប់ដែលគ្រប់គ្រងលើអ្នកដែលចូលទៅក្នុង និងធ្វើការងារនៅប្រទេសដទៃនោះ។ គេហៅថា ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ពីព្រោះ ជនចំណាកស្រុកត្រូវមានឯកសារស្របច្បាប់ដូចជាលិខិតឆ្លងដែន និងទិដ្ឋាការការងារមុននឹងធ្វើចំណាកស្រុក។ មានប្រទេសជាច្រើនដែលនិយាយអំពីការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ចូលទៅក្នុងគ្រប់ប្រទេសផ្សេងទៀត ដែលមិនអាចដាក់ចូលអស់ទៅក្នុងឯកសារកម្រងនេះ។ ប៉ុន្តែវាជាការល្អដែលត្រូវដឹងថា ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ជាធម្មតា តម្រូវឲ្យធ្វើដំណើរជាមួយនឹងលិខិតឆ្លងដែន និងទិដ្ឋាការមួយ ហើយប្រហែលជាតម្រូវឲ្យមានឯកសារផ្សេងទៀតផងដែរ។

ប្រាប់អ្នកចូលរួម លិខិតឆ្លងដែន គឺជាឯកសារស្របច្បាប់មួយ ដែលចេញដោយប្រទេសកំណើតរបស់បុគ្គលអ្នកកាន់វាដែលគេប្រើដើម្បីចូល និងចេញពីប្រទេសដោយស្របច្បាប់។ បង្ហាញអ្នកចូលរួមនូវរូបថតលិខិតឆ្លងដែនមួយ។

ប្រាប់អ្នកចូលរួមថា ទិដ្ឋាការ គឺជាត្រា ឬក្រដាសស្អិតបិទជាប់ស្របច្បាប់មួយដែលគេដាក់លើសន្លឹកលិខិតឆ្លងដែន ដោយតំណាងរដ្ឋាភិបាលនៃប្រទេសដទៃដែលអនុញ្ញាតិអ្នកកាន់អាច ចូលប្រទេស នោះបាន។ មានប្រភេទទិដ្ឋាការខុសៗគ្នា។ ទិដ្ឋាការការងារ អនុញ្ញាតឲ្យបុគ្គលអាចធ្វើការងារ ដោយស្របច្បាប់នៅក្នុងប្រទេសផ្សេង។ ទិដ្ឋាការទេសចរណ៍ អនុញ្ញាតិឲ្យបុគ្គលអាចទស្សនាបាន ប៉ុន្តែមិនអាចធ្វើការបានទេ។

បង្ហាញសិស្សពីរូបថតទិដ្ឋាការមួយ។

ប្រាប់សិស្សថា គេមិនអាចចូលទៅក្នុងប្រទេសណាមួយបានដោយស្របច្បាប់ដោយមិនមានលិខិតឆ្លងដែន ក៏ដូចជាទិដ្ឋាការពីប្រទេសដែលគេនឹងទៅនោះបានទេ។

ពន្យល់ប្រាប់ថា ប្រសិនបើគេមានបំណងចង់ធ្វើចំណាកស្រុកចូលទៅកាន់ប្រទេសដទៃ ពួកគេគួរតែសាកសួរក្រុមគ្រួសារ ឬអាជ្ញាធរមូលដ្ឋានរបស់ខ្លួនថា តើឯកសារសំអាងប្រភេទណាដែលត្រូវការដើម្បីធ្វើចំណាកស្រុកទៅកាន់ប្រទេសនោះ។

ប្រាប់អ្នកចូលរួមថា មនុស្សជាច្រើនអ្នកដែលធ្វើចំណាកស្រុកមិនមានឯកសារបញ្ជាក់ទេ។ បុគ្គលទាំងនេះរកមធ្យោបាយផ្សេងទៀតដើម្បីចូលទៅដល់ប្រទេសដទៃ។ អ្នកខ្លះត្រូវបានរត់ពន្ធឆ្លងកាត់ព្រំដែនខុសច្បាប់។ (សួរថា តើមាននរណាអាចពន្យល់បានថាអ្វីជាការរត់ពន្ធមនុស្សខុសច្បាប់)។ អ្នកខ្លះចូលទៅក្នុងប្រទេសផ្សេងដោយនិយាយថា គេគ្រាន់តែស្នាក់នៅមួយថ្ងៃ ឬមួយរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងគេមានបំណងស្នាក់នៅរយៈពេលច្រើនឆ្នាំ។ នេះគេហៅថា ការធ្វើចំណាកស្រុកដោយមិនមានឯកសារស្របច្បាប់ ។ (ឬអាចហៅ បានម៉្យាងទៀតថា ការធ្វើចំណាកស្រុកខុសច្បាប់ ឬ មិនប្រក្រតី)។

ពន្យល់ទៀតថា ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ ជាធម្មតាតែងតែមានការពិបាកក្នុងការរៀបចំជាងការធ្វើចំណាកស្រុកគ្មានឯកសារស្របច្បាប់។ ជាទូទៅវាតម្រូវឲ្យជនចំណាកស្រុកត្រូវឆ្លងកាត់ការបំពេញបែបបទវែងឆ្ងាយដោយការដាក់ពាក្យសុំឯកសារផ្សេងៗ ប៉ុន្តែការ

ការធ្វើចំណាក

ស្រុកមានឯកសារស្របច្បាប់មានសុវត្ថិភាពជាង។ ពន្យល់ពួកគេថា ការធ្វើចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់គឺជាការរំលោភច្បាប់ ដូច្នេះពួកគេព្យាយាមនៅឆ្ងាយពីប៉ូលីសនៅក្នុងប្រទេសដែលគេបានចូលទៅនោះ។ វាមានសុវត្ថិភាពច្រើនជាងសម្រាប់ជនចំណាកស្រុកដែលមានឯកសារស្របច្បាប់ ពីព្រោះគេអាចទាក់ទងទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើគេជួបជួបប្រទះនឹងបញ្ហាអ្វី។

ឲ្យអ្នកចូលរួមគិតអំពីអ្នកដែលគេធ្លាប់ស្គាល់ ហើយអ្នកនោះធ្លាប់ចាកចេញពីសហគមន៍របស់គេ និងបានទៅរស់នៅក្នុងប្រទេសដទៃ។ សួរថា “តើគេបានធ្វើចំណាកស្រុកដោយមានឯកសារស្របច្បាប់ ឬគ្មានឯកសារស្របច្បាប់។”

## ការពិភាក្សា

បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី ៤-៨ នាក់ និងផ្តល់ក្រដាសផ្ទាំងធំមួយសន្លឹកទៅឲ្យក្រុមនីមួយៗ។ ឲ្យអ្នកចូលរួមពិភាក្សាលើសំណួរខាងក្រោម ហើយសរសេរចម្លើយរបស់គេនៅលើក្រដាសផ្ទាំងធំនេះ។ ឧទាហរណ៍មានបញ្ចូលទៅក្នុង “IS ១២ក ៖ តារាងឧទាហរណ៍នៃការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់/មិនស្របច្បាប់”។

- តើរបៀបដែលគេធ្វើចំណាកស្រុកដោយមានឯកសារមានលក្ខណៈដូចម្តេច?
- តើរបៀបដែលគេធ្វើចំណាកស្រុកដោយគ្មានឯកសារមានលក្ខណៈដូចម្តេច?
- ហេតុអ្វីបានជាគេជ្រើសរើសយកការធ្វើចំណាកស្រុកដោយមានឯកសារ?
- ហេតុអ្វីបានជាគេជ្រើសរើសយកការធ្វើចំណាកស្រុកដោយគ្មានឯកសារ?
- តើអ្វីខ្លះជាការទទួលខុសត្រូវរបស់ជនចំណាកស្រុកចំពោះប្រទេសដែលគេចូលទៅ?
- តើអាយុប៉ុន្មានដែលអ្នកគិតថា វាសមស្របសម្រាប់ការធ្វើចំណាកស្រុក?

## សំណួរខ្លី

លេងល្បែង បោះបាល់ចងចាំ នៅក្នុងទំព័រទី ១០។

**សង្ខេបមេរៀន**

- ការធ្វើចំណាកស្រុកក្នុងប្រទេស៖ មនុស្សធ្វើចំណាកស្រុកនៅក្នុងប្រទេសរបស់ខ្លួន។
- ការធ្វើចំណាកស្រុកក្រៅប្រទេស៖ មនុស្សធ្វើចំណាកស្រុកទៅប្រទេសដទៃ។
- ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់៖ ជនចំណាកស្រុកត្រូវអនុវត្តតាមច្បាប់ដែលគ្រប់គ្រងលើអ្នកដែលចូលទៅ និងធ្វើការងារនៅប្រទេសដទៃ។ ការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់ តម្រូវឲ្យជនចំណាកស្រុកធ្វើដំណើរជាមួយនឹងលិខិតឆ្លងដែន និងទិដ្ឋាការការងារ ហើយប្រហែលជាតម្រូវឲ្យមានឯកសារផ្សេងទៀតផងដែរ។
- ការធ្វើចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់ ៖ មនុស្សធ្វើដំណើរទៅប្រទេសដទៃដោយមិនគោរពតាមច្បាប់ ឬ គ្មានលិខិតឆ្លងដែន និង ទិដ្ឋាការ។ ការធ្វើចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់ គឺជារបៀបធ្វើចំណាកស្រុកដែលគេនិយមធ្វើ។
- ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់មានសុវត្ថិភាពជាងការធ្វើចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់។

**ការបិទវគ្គ**

ប្រាប់ឲ្យអ្នកចូលរួមសសរសេរ ឬសួរសំណួរ ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នា ដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញ អំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។ ឲ្យសិស្សសួរឪពុកម្តាយរបស់គេ តើពួកគាត់ធ្លាប់ដឹងថា មានអ្នកធ្វើចំណាកស្រុកក្នុងប្រទេស ឬ ក្រៅប្រទេសដែរ ឬទេ។ តើគេធ្វើចំណាកស្រុកដោយមានឯកសារស្របច្បាប់ ឬគ្មានឯកសារស្របច្បាប់"?

# ១២ IS ១២ក ៖ តារាងឧទាហរណ៍នៃការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់/មិនស្របច្បាប់

| ការធ្វើចំណាកស្រុកដែលមានឯកសារស្របច្បាប់ | ការធ្វើចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់ |
|---|---|
| • ប័ណ្ណឆ្លងកាត់ព្រំដែន (បីថ្ងៃ –ខេត្ត ទៅខេត្ត)<br>• ប័ណ្ណជនអន្តោប្រវេសន៍ (៦ខែ –ពីស្រុកទៅស្រុក)<br>• លិខិតឆ្លងដែន<br>• ទិដ្ឋាការ<br>• លិខិតអនុញ្ញាតឲ្យធ្វើការងារ (ក្រសួងការងារ)<br>• ទីភ្នាក់ងារជ្រើសរើសពលករ | • មេខ្យល់<br>• សាច់ញាតិ<br>• ឆ្លងកាត់ព្រំដែនដោយខ្លួនឯង<br>• មិត្តភក្តិ<br>• អ្នកមិនដែលស្គាល់គ្នា |
| **ហេតុអ្វី ?**<br>• ការងារសុវត្ថិភាពជាង<br>• ការងារជាក់លាក់ ៖ ល្អជាង អចិន្ត្រៃយ៍<br>• មានជំនាញ | **ហេតុអ្វី ?**<br>• មិនចំណាយពេលច្រើន<br>• ងាយស្រួលទៅ<br>• ចំណាយប្រាក់ធ្វើដំណើរតិចជាង<br>• ងាយស្រួលក្នុងការគេចខ្លួន |